# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# កម្មវិធីគ្រប់គ្រង
# ឧទ្យានជាតិ ព្រះជ័យវរ្ម័ន-នរោត្តម «ភ្នំគូលែន»
# ២០១៨-២០២៧



**កម្មវិធីគ្រប់គ្រងឧទ្យានជាតិ ព្រះជ័យវរ្ម័ន-នរោត្តម <ភ្នំគូលែន>
២០១៨-២០២៧**

រក្សាសិទ្ធដោយ៖ អគ្គនាយកដ្ឋានរដ្ឋបាលការពារនិងអភិរក្សធម្មជាតិ នៃក្រសួងបរិស្ថាន
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៧

ឯកសារនេះបោះពុម្ពដោយ៖ អគ្គនាយកដ្ឋានរដ្ឋបាលការពារនិងអភិរក្សធម្មជាតិ
ដោយមានការគាំទ្រពីមូលនិធិភាពជាដៃគូកាបូនព្រៃឈើ និងអង្គការកម្មវិធីអភិវឌ្ឍន៍
សហប្រជាជាតិប្រចាំនៅកម្ពុជា តាមរយៈគម្រោងរេដបូកកម្ពុជា។

# កម្មវិធីគ្រប់គ្រងឧទ្យានជាតិ
# ព្រះជ័យវរ្ម័ន-នរោត្តម "ភ្នំគូលែន"
# ២០១៨-២០២៧



# សារលិខិត

ជាបឋមក្នុងនាមក្រសួងបរិស្ថាន ខ្ញុំបាទសូមសម្តែងការគោរពដ៏ខ្ពង់ខ្ពស់ និងកត្តវេទិតាដ៏ស្មោះត្រង់បំផុតចំពោះ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ដែលតែងតែណែនាំផ្តល់ការគាំទ្រនិងយកចិត្តទុកដាក់ខ្ពស់លើវិស័យបរិស្ថាននិងការគ្រប់គ្រងតំបន់ការពារធម្មជាតិនៅក្នុងប្រទេសកម្ពុជា ហើយក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ** ព្រះរាជាណាចក្រកម្ពុជា បាននិងកំពុងអនុវត្ត **«យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣»** ដោយចាត់ទុកការគ្រប់គ្រងធនធានធម្មជាតិ គឺជាវិស័យអាទិភាពមួយក្នុងចំណោមវិស័យអាទិភាពដទៃទៀតនៃមុំរបស់យុទ្ធសាស្ត្រចតុកោណនេះ។

កម្មវិធីគ្រប់គ្រងឧទ្យានជាតិព្រះជ័យវរ្ម័ន-នរោត្តម «ភ្នំគូលែន» គឺជាគោលដៅយុទ្ធសាស្ត្រមួយក្នុងចំណោមគោលដៅជាយុទ្ធសាស្ត្រដទៃទៀត សម្រាប់ការគ្រប់គ្រងតំបន់ការពារធម្មជាតិ និងរបៀងអភិរក្សជីវៈចម្រុះ ដែលបច្ចុប្បន្នគ្របដណ្តប់លើផ្ទៃដីប្រមាណ ៤១% នៃផ្ទៃដីសរុបរបស់ព្រះរាជាណាចក្រកម្ពុជា ហើយក៏ជាផ្នែកមួយក្នុងការធានាឱ្យមានចីរភាពសម្រាប់កិច្ចការពារ ថែរក្សា និងគ្រប់គ្រងទាំងធនធានព្រៃឈើ និងឧទ្យានជាតិ «ភ្នំគូលែន» ដែលជាបេតិកភណ្ឌវប្បធម៌ មានអាយុកាលយូរអង្វែងមកហើយ សម្រាប់ជាប្រយោជន៍ដល់មនុស្សជំនាន់បច្ចុប្បន្ន និងជំនាន់ក្រោយៗទៀត។

ការរៀបចំកម្មវិធីគ្រប់គ្រងឧទ្យានជាតិព្រះជ័យវរ្ម័ន-នរោត្តម «ភ្នំគូលែន» គឺជាឯកសារយុទ្ធសាស្ត្រក្នុងការកសាងសមត្ថភាពស្ថាប័ន និងចំណេះដឹង ដើម្បីពង្រឹងប្រសិទ្ធភាពគ្រប់គ្រងលើការងារអភិរក្សធនធានធម្មជាតិ និងបុរាណស្ថានឱ្យមានចីរភាព តាមរយៈការកំណត់ និងបែងចែកតំបន់គ្រប់គ្រង ពង្រឹងការអនុវត្តច្បាប់ ការរៀបចំតំបន់អេកូទេសចរណ៍ និងការពង្រីកឱកាសបង្កើនមុខរបរចិញ្ចឹមជីវិតរបស់សហគមន៍មូលដ្ឋាន។ ដើម្បីឱ្យការអនុវត្តកម្មវិធីគ្រប់គ្រងឧទ្យានជាតិព្រះជ័យវរ្ម័ន-នរោត្តម «ភ្នំគូលែន» ២០១៨-២០២៧ សម្រេចបានជោគជ័យ ខ្ញុំសូមអំពាវនាវដល់គ្រប់ស្ថាប័ន ជាតិ អន្តរជាតិ និងប្រជាសហគមន៍មូលដ្ឋានបណ្តាភាគីពាក់ព័ន្ធទាំងអស់ បន្តគាំទ្រ និងផ្តល់កិច្ចសហការបន្ថែមទៀត ដើម្បីឱ្យការអនុវត្តកម្មវិធីគ្រប់គ្រងឧទ្យានជាតិព្រះជ័យវរ្ម័ន-នរោត្តម «ភ្នំគូលែន» ទទួលបានជោគជ័យប្រកបដោយផ្លែផ្កា ។

ជាថ្មីម្តងទៀត ខ្ញុំសូមសម្តែងនូវអំណរគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និងសូមកោតសរសើរចំពោះ ឯកឧត្តម លោកជំទាវ លោក លោកស្រី ពីគ្រប់អង្គភាព-ស្ថាប័នពាក់ព័ន្ធ គ្រឹះស្ថានឧត្តមសិក្សា អង្គការមិនមែនរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍នានា ដែលបានផ្តល់កិច្ចសហការ និងចូលរួមរៀបចំកម្មវិធីគ្រប់គ្រងឧទ្យានជាតិព្រះជ័យវរ្ម័ន-នរោត្តម «ភ្នំគូលែន» ដ៏មានតម្លៃនេះ ឱ្យសម្រេចបានជាឯកសារគ្រឹះដ៏ល្អប្រសើរមួយ សម្រាប់បម្រើឱ្យវិស័យបរិស្ថាន និងគ្រប់គ្រងធនធានធម្មជាតិនៅកម្ពុជា។

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ តុលា ឆ្នាំ២០១៧

**រដ្ឋមន្ត្រី**

**សាយ សំអាល់**

# អារម្ភកថា

ក្រោមបរិយាកាសសន្តិភាពពេញលេញនៃព្រះរាជាណាចក្រកម្ពុជា នៃនយោបាយ «ឈ្នះ-ឈ្នះ» នាឆ្នាំ១៩៩៨ របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ប្រទេសកម្ពុជាបានប្រែក្លាយពីសង្គ្រាមរ៉ាំរ៉ៃមកជាប្រទេសមានសន្តិភាព ឯកភាពជាតិ ឯកភាពទឹកដី និង ការអភិវឌ្ឍលើគ្រប់វិស័យ និងមានឱកាសគ្រប់គ្រាន់ក្នុងការរៀបចំកិច្ចការពារ គ្រប់គ្រងធនធានធម្មជាតិ និងអភិរក្សជីវៈចម្រុះដែលខ្លួនមាន។ រហូតមកដល់ពេលនេះ ព្រះរាជាណាចក្រកម្ពុជាមានផ្ទៃដីប្រព័ន្ធតំបន់ ការពារធម្មជាតិ និងរបៀងអភិរក្សជីវៈចម្រុះប្រមាណ៤១% នៃផ្ទៃដីសរុបប្រទេស ដែលច្បាប់ស្តីពី **"តំបន់ការពារធម្មជាតិ"** ឆ្នាំ២០០៨ បានបែងចែកប្រភេទតំបន់ការពារធម្មជាតិ រួមមាន៖ ១.តំបន់ឧទ្យានជាតិ ២.តំបន់ដែនជម្រកសត្វព្រៃ ៣.តំបន់ការពារទេសភាព ៤.តំបន់ប្រើប្រាស់ច្រើនយ៉ាង ៥.តំបន់រ៉ាមសារ ៦.តំបន់ស្នូលនៃបបនីយជីវមណ្ឌល ៧.តំបន់បេតិកភណ្ឌធម្មជាតិ ៨.តំបន់ឧទ្យានជាតិសមុទ្រ និង៩.របៀង អភិរក្សជីវៈចម្រុះប្រព័ន្ធតំបន់ការពារធម្មជាតិ ដែលរាជរដ្ឋាភិបាលកម្ពុជាបានកំណត់នាពេលថ្មីៗនេះ។ ក្នុង ចំណោមឧទ្យានជាតិទាំង១២ តំបន់**ឧទ្យានជាតិ ព្រះជ័យវរ្ម័ន-នរោត្តម «ភ្នំគូលែន»** ដែលមានចំនួនផ្ទៃដី ៣៧.៥០០ហិកតា គឺជាឧទ្យានជាតិមួយដែលសម្បូរទៅដោយបេតិកភណ្ឌវប្បធម៌ និងធនធានធម្មជាតិ។ តាមប្រវត្តិសាស្ត្រ ភ្នំគូលែនគឺសម្បូរទៅដោយប្រាង្គបាសាទបុរាណជាច្រើន និងត្រូវបានគេជឿថា ជាកន្លែង កំណើតនៃអាណាចក្រខ្មែរ ដែលព្រះបាទជ័យវរ្ម័នទី២ បានឡើងគ្រងរាជ្យជាស្តេចនៅតំបន់នេះ ហើយក៏ ត្រូវបានប្រជាជនកម្ពុជាចាត់ទុកជាតំបន់ពិសិដ្ឋ និងស័ក្តិសិទ្ធសម្រាប់គោរពបូជាផងដែរ។ ឧទ្យានជាតិនេះ ក៏មានប្រព័ន្ធអេកូឡូស៊ីព្រៃឈើល្អ ជាទីជម្រកសំខាន់សម្រាប់ប្រភេទសត្វកម្រជាច្រើន ដែលកំពុងរងការ គំរាមកំហែងលើពិភពលោក និងជាប្រភពទឹកចម្បងសម្រាប់ប្រើប្រាស់នៅទីក្រុងសៀមរាប និងល្អាងទឹក ក្រោមដីសម្រាប់ថែរក្សាគ្រឹះប្រាង្គប្រាសាទនានានៅតំបន់អង្គរ។ ផ្អែកលើសក្តានុពលទាំងនេះហើយ បានជា តំបន់ឧទ្យានជាតិ«ភ្នំគូលែន» មានការទាក់ទាញភ្ញៀវទេសចរជាតិ-អន្តរជាតិយ៉ាងច្រើនមកទស្សនាកម្សាន្ត និងសិក្សាស្វែងយល់ពីអរិយធម៌ វប្បធម៌ និងធនធានធម្មជាតិ ដែលកត្តាទាំងនេះបានធ្វើឱ្យតំបន់ឧទ្យាន ជាតិនេះទទួលរងផលប៉ះពាល់វិជ្ជមានផង និងអវិជ្ជមានផង ក្រោមហេតុផលបង្កើន និងពង្រីកការអភិវឌ្ឍ សេដ្ឋកិច្ច-សង្គម ដែលធ្វើឱ្យធនធានធម្មជាតិ និងគម្របព្រៃឈើក្នុងឧទ្យានជាតិបានថយចុះនាពេល បច្ចុប្បន្ននេះ។

ក្រោមការយកចិត្តទុកដាក់ខ្ពស់ និងការផ្តល់អនុសាសន៍របស់ **ឯកឧត្តម សាយ សំអាល់** រដ្ឋមន្ត្រី ក្រសួងបរិស្ថាន អគ្គនាយកដ្ឋានរដ្ឋបាលការពារ និងអភិរក្សធម្មជាតិ ដែលជាសេនាធិការឱ្យក្រសួង និង មានតួនាទីទទួលខុសត្រូវលើការគ្រប់គ្រងតំបន់ការពារធម្មជាតិ តែងតែគិតគូរ និងយកចិត្តទុកដាក់អនុវត្ត ទៅតាមគោលការណ៍ច្បាប់ និងគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា ពិសេសបាននិងកំពុងចូលរួម ជំរុញការអភិវឌ្ឍប្រទេសឱ្យមានចីរភាព ដោយឈរលើទស្សនៈ **អភិរក្សសម្រាប់ការអភិវឌ្ឍ និងអភិវឌ្ឍត្រូវ គិតលើការអភិរក្ស។** ក្នុងន័យនេះ ដើម្បីរក្សាបាននូវតុល្យភាពទាំងការអភិរក្សធនធានធម្មជាតិ និងការលើក កម្ពស់ជីវភាពរស់នៅរបស់ប្រជាសហគមន៍មូលដ្ឋាន ការរៀបចំផែនការកម្មវិធីគ្រប់គ្រងសម្រាប់ឧទ្យានជាតិ ព្រះជ័យវរ្ម័ន-នរោត្តម «ភ្នំគូលែន» គឺជាកត្តាសំខាន់ និងចាំបាច់សម្រាប់ជាផែនទីបង្ហាញផ្លូវដល់គ្រប់បណ្តា ភាគីពាក់ព័ន្ធទាំងអស់ ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ឱ្យចូលរួមអនុវត្តក្នុងគោលដៅរួមគ្នា ដើម្បីជានា

ឱ្យបានទាំងការអភិវឌ្ឍ និងការអភិរក្សសម្រាប់ការគ្រប់គ្រងតំបន់ការពារធម្មជាតិក្នុងព្រះរាជាណាចក្រកម្ពុជាឱ្យមានចីរភាព។

ដើម្បីសម្រេចបាននូវគោលដៅខាងលើ កម្មវិធីគ្រប់គ្រងឧទ្យានជាតិ ព្រះជ័យវរ្ម័ន-នរោត្តម «ភ្នំគូលែន» សម្រាប់រយៈពេល ១០ឆ្នាំ (២០១៨-២០២៧) ត្រូវបានរៀបចំឡើងដោយក្រុមការងារបច្ចេកទេស នៃក្រសួងបរិស្ថាន ក្រោមកិច្ចសហការពីអង្គការ UNDP ប្រចាំកម្ពុជា និងភាគីពាក់ព័ន្ធនៅថ្នាក់ក្រោមជាតិ ក្នុងគោលដៅរួម ដើម្បីកាត់បន្ថយការបាត់បង់និងរេចរឹលព្រៃឈើ ការលើកកម្ពស់មុខរបរចិញ្ចឹមជីវិតសម្រាប់ប្រជាសហគមន៍មូលដ្ឋាន ការធ្វើឱ្យបរិស្ថានមាននិរន្តរភាព និងការអភិរក្សធនធានធម្មជាតិ និងបេតិកភណ្ឌវប្បធម៌នៅក្នុងឧទ្យានជាតិភ្នំគូលែនទទួលបានភាពល្អប្រសើរ។ ដើម្បីសម្រេចបានគោលដៅទាំងនេះ ក្រសួងបរិស្ថានក៏បានដាក់ចេញនូវកម្មវិធីយុទ្ធសាស្ត្រសំខាន់ៗចំនួន ៤ គឺ៖ ១.ពង្រឹងកិច្ចការពារ និងការអភិរក្សធនធានធម្មជាតិ និងវប្បធម៌ ២.ពង្រីកការចូលរួម និងអត្ថប្រយោជន៍របស់សហគមន៍មូលដ្ឋាន ៣.ពង្រឹងសមត្ថភាពស្ថាប័ន និងកិច្ចសហការ និង ៤.ធានានិរន្តរភាពហិរញ្ញប្បទានសម្រាប់គ្រប់គ្រងឧទ្យានជាតិភ្នំគូលែន។

យុទ្ធសាស្ត្រខាងលើនេះ គឺត្រូវបានរៀបចំឡើង ដោយមានការពិគ្រោះយោបល់យ៉ាងទូលំទូលាយ ដើម្បីធានាការឯកភាពគ្នាលើលក្ខណៈគោលនយោបាយ យុទ្ធសាស្ត្រ និងបច្ចេកទេស ក្នុងគោលបំណងឱ្យកម្មវិធីគ្រប់គ្រងឧទ្យានជាតិ «ភ្នំគូលែន» ទទួលបានភាពជាម្ចាស់ តម្លាភាព ប្រសិទ្ធភាព និងប្រសិទ្ធផល និងបង្កើតជាចក្ខុវិស័យរួមសំដៅធានាឱ្យការគ្រប់គ្រង ការអភិរក្សជីវៈចម្រុះ និងការប្រើប្រាស់ធនធានក្នុងតំបន់ឧទ្យានជាតិនេះ ទទួលបានអត្ថប្រយោជន៍ទាំងលើផ្នែក បរិស្ថាន សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌។

ហេតុនេះ តាងនាមឱ្យ អគ្គនាយកដ្ឋានរដ្ឋបាលការពារ និងអភិរក្សធម្មជាតិ និងក្រុមការងាររៀបចំកម្មវិធីគ្រប់គ្រង **ឧទ្យានជាតិព្រះជ័យវរ្ម័ន-នរោត្តម «ភ្នំគូលែន» (២០១៨-២០២៧)** ខ្ញុំបាទសូមសម្តែងនូវការគោរព និងកត្តវេទិតាដ៏ស្មោះចំពោះ **ឯកឧត្តម សាយ សំអាល់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន** ដែលតែងជួយជំរុញ ណែនាំ គាំទ្រ និងយកចិត្តទុកដាក់លើវិស័យបរិស្ថាន និងការគ្រប់គ្រងតំបន់ការពារធម្មជាតិ ហើយខ្ញុំបាទក៏សូមថ្លែងអំណរគុណចំពោះ ឯកឧត្តម លោកជំទាវ លោក លោកស្រី ក្នុងក្រសួងបរិស្ថាន និងមកពីក្រសួងស្ថាប័នពាក់ព័ន្ធ ដៃគូអភិវឌ្ឍន៍ សង្គមស៊ីវិល គ្រឹះស្ថានឧត្តមសិក្សា វិស័យឯកជន សហគមន៍មូលដ្ឋាន និងអ្នកពាក់ព័ន្ធនានា ដែលបានចូលរួម និងផ្តល់កិច្ចសហប្រតិបត្តិការយ៉ាងល្អ ក្នុងការផ្តល់ធាតុចូលសម្រាប់ឱ្យឯកសារដ៏មានតម្លៃនេះ សម្រេចបានជារូបរាងឡើង។ ខ្ញុំក៏មានជំនឿ និងសង្ឃឹមទុកជាមុនថា អ្នកពាក់ព័ន្ធទាំងអស់នឹងនៅតែបន្តចូលរួមគាំទ្រ សហការ និងអនុវត្ត ដើម្បីរួមគ្នាលើកកម្ពស់សម្បត្តិធម្មជាតិ វប្បធម៌ក្នុងឧទ្យានជាតិនេះ ឱ្យទទួលបានកិត្យានុភាពបន្ថែមទៀត។

រាជធានីភ្នំពេញ ថ្ងៃទី១៧ ខែតុលា ឆ្នាំ២០១៧

**អគ្គនាយក**

**ជា សំអាង**

# សេចក្តីថ្លែងអំណរគុណ

ក្រសួងបរិស្ថាន សូមសម្តែងនូវអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ ក្រសួង-ស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍន៍ អង្គការមិនមែនរដ្ឋាភិបាល គ្រឹះស្ថានឧត្តមសិក្សា វិស័យឯកជន និងអ្នកពាក់ព័ន្ធទាំងអស់ ដែលបានរួមចំណែកផ្តល់ជាតុចូលដ៏មានសារៈប្រយោជន៍ នៅក្នុងការរៀបចំកម្មវិធីគ្រប់គ្រងឧទ្យានជាតិព្រះជ័យវរ្ម័ន-នរោត្តម «ភ្នំគូលែន» ក្រោមការដឹកនាំ និងសម្របសម្រួលពីប្រធានក្រុមការងារអន្តរក្រសួងដែលមានសមាសភាពៈ

| ល.រ | នាម និងគោត្តនាម | | ស្ថាប័ន |
|---|---|---|---|
| ១ | ឯកឧត្តម ជា សំអាង | ប្រធាន | ក្រសួងបរិស្ថាន |
| ២ | ឯកឧត្តម គឹម ឆៃហៀង | អនុប្រធាន | សាលាខេត្តសៀមរាប |
| ៣ | លោក សេង សោត | អនុប្រធានអចិន្ត្រៃយ៍ | ក្រសួងបរិស្ថាន |
| ៤ | ឯកឧត្តម កែន សេរីរដ្ឋា | សមាជិក | អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាអភិវឌ្ឍន៍ដោយចីរភាព |
| ៥ | ឯកឧត្តម គឹម ណុង | សមាជិក | ក្រសួងបរិស្ថាន |
| ៦ | ឯកឧត្តម ហែម សុចិត្រ | សមាជិក | ក្រសួងបរិស្ថាន |
| ៧ | ឯកឧត្តម ព្រហ្ម សួនប្រសិទ្ធិ | សមាជិក | មជ្ឈមណ្ឌលកំចាត់មីនកម្ពុជា |
| ៨ | លោកបណ្ឌិត ហេង សុផាឌី | សមាជិក | ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ |
| ៩ | លោកបណ្ឌិត គុំ វាសនា | សមាជិក | ក្រសួងបរិស្ថាន |
| ១០ | លោកបណ្ឌិត JB Chevance | សមាជិក | ADF |
| ១១ | លោកបណ្ឌិត ឡៅ គឹមលាង | សមាជិក | សាកលវិទ្យាល័យសូហ្វីយ៉ា |
| ១២ | លោក ជុក ជំនោរ | សមាជិក | ក្រសួងទេសចរណ៍ |
| ១៣ | លោក ហុង តាំវុធ | សមាជិក | ក្រសួងបរិស្ថាន |
| ១៤ | លោក ហេង គឹមលេង | សមាជិក | អាជ្ញាធរជាតិអប្សរា |
| ១៥ | លោក ហាន វិត្ថា | សមាជិក | ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ |
| ១៦ | លោក ហ៊ុយ ជីវិត | សមាជិក | ក្រសួងអភិវឌ្ឍន៍ជនបទ |
| ១៧ | លោក អេវ សម្បត្តិ | សមាជិក | ក្រសួងអភិវឌ្ឍន៍ជនបទ |
| ១៨ | លោក ភួង លីណា | សមាជិក | មន្ទីរបរិស្ថានខេត្តសៀមរាប |
| ១៩ | លោក សួរ សុន | សមាជិក | សាលាស្រុកបន្ទាយស្រី |
| ២០ | លោក នាក់ ណារ៉ុន | សមាជិក | សាលាស្រុកវ៉ារិន |
| ២១ | លោក ស៊ិក ប៊ុនស៊ិន | សមាជិក | សាលាស្រុកស្វាយលើ |
| ២២ | លោក មាស សុធនវឌ្ឍនៈ | សមាជិក | ន/ជួ ជីវភាពសហគមន៍ ក្រសួងបរិស្ថាន |
| ២៣ | លោក ម៉ន សំអាត | សមាជិក | សាលាខេត្តសៀមរាប |
| ២៤ | លោក លុក សុខឡេង | សមាជិក | អាជ្ញាធរជាតិអប្សរា |
| ២៥ | លោក សន ចាន់ថន | សមាជិក | អាជ្ញាធរជាតិអប្សរា |
| ២៦ | លោក រ៉េន ប៊ុនថង | សមាជិក | អាជ្ញាធរជាតិអប្សរា |
| ២៧ | លោក មាឃ បុ៉ា | សមាជិក | អាជ្ញាធរជាតិអប្សរា |
| ២៨ | កញ្ញា កែវ នាទី | សមាជិក | នាយកដ្ឋានបេតិកណ្ឌ |
| ២៩ | លោក ភឹង វុត្ថា | សមាជិក | សាលាខេត្តសៀមរាប |
| ៣០ | លោក ស៊ូ សុជាតិ | សមាជិក | អង្គការអប់រំស្តីពីការរស់នៅជាមួយបរិស្ថាន |
| ៣១ | លោក សាខឿន សក្តា | សមាជិក | ADF |
| ៣២ | ឯកឧត្តម នេត្រ ភក្ត្រា | អ្នកសម្រួលអត្ថបទ | ជំនួយការក្រសួងបរិស្ថាន |
| ៣៣ | លោកបណ្ឌិត ងួន ភក្តី | ទីប្រឹក្សា | UNDP |
| ៣៤ | លោកបណ្ឌិត Kent Jingfors | ទីប្រឹក្សា | UNDP |

# ពាក្យបំព្រួញ

| | | |
|---|---|---|
| ACCB | Angkor Center for Conservation of Biodiversity | មជ្ឈមណ្ឌលអង្គរសម្រាប់អភិរក្សជីវៈចម្រុះ |
| ADF | Archaeology and Development Foundation | អង្គការមូលនិធិបូរាណវិទ្យានិងអភិវឌ្ឍន៍ |
| APAs | Archaeological Protected Areas | តំបន់ការពារបុរាណវត្ថុ |
| APSARA | APSARA Authority | អាជ្ញាធរអប្សរា |
| CPAs | Community Protected Areas | សហគមន៍តំបន់ការពារធម្មជាតិ |
| FA | Forestry Administration | រដ្ឋបាលព្រៃឈើ |
| GDANCP | General Directorate of Administration for Nature Conservation and Protection | អគ្គនាយកដ្ឋានរដ្ឋបាលការពារនិងអភិរក្សធម្មជាតិ |
| GDEKI | General Directorate of Environmental Knowledge and Information | អគ្គនាយកដ្ឋានចំណេះដឹងនិងព័ត៌មានបរិស្ថាន |
| GDLC | General Directorate of Local Community | អគ្គនាយកដ្ឋានសហគមន៍មូលដ្ឋាន |
| GIZ | Deutsche Gesellschaft für Internationale Zusammenarbeit | ទីភ្នាក់ងារអាល្លឺម៉ង់ដើម្បីសហប្រតិបត្តិការអន្តរជាតិ |
| ha | Hectare | ហិកតា |
| IUCN | International Union for the Conservation of Nature and Natural Resources | សហភាពអន្តរជាតិដើម្បីអភិរក្សធម្មជាតិនិងធនធានធម្មជាតិ |
| MAFF | Ministry of Agriculture, Forestry and Fisheries | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |
| MEF | Ministry of Economy and Finance | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ |
| MoE | Ministry of Environment | ក្រសួងបរិស្ថាន |
| MoT | Ministry of Tourism | ក្រសួងទេសចរណ៍ |
| MoU | Memorandum of Understanding | អនុស្សរណៈនៃការយោគយល់ |
| NCSD | National Council for Sustainable Development | ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព |
| NCSD-S | General Secretariat of the National Council for Sustainable Development | អគ្គលេខាធិការក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព |
| NGO | Non-Governmental Organization | អង្គការមិនមែនរដ្ឋាភិបាល |
| NPASMP | National Protected Area Strategic Management Plan | ផែនការយុទ្ធសាស្ត្រជាតិគ្រប់គ្រងតំបន់ការពារធម្មជាតិ |
| NTFPs | Non-Timber Forest Products | អនុផលព្រៃឈើ |
| PA | Protected Area | តំបន់ការពារធម្មជាតិ |
| PDoE | Provincial Department of Environment | មន្ទីរបរិស្ថានខេត្ត |
| PKNP | Phnom Kulen National Park | ឧទ្យានជាតិភ្នំគូលែន |
| PES | Payment for Ecosystem Services | ការទូរទាត់សេវាកម្មបរិស្ថាន |
| PMC | Park Management Committee | គណៈកម្មការគ្រប់គ្រងឧទ្យាន |
| REDD+ | Reducing Emissions from Deforestation and Forest Degradation and the role of conservation, sustainable management and enhancement of forest carbon stocks | កាត់បន្ថយការបំភាយឧស្ម័នពីការបាត់បង់ និងរេចរឹលព្រៃឈើ តួនាទីអភិរក្ស និងការគ្រប់គ្រងដោយនិរន្តរភាព និងពង្រីកស្តុកកាបូនព្រៃឈើ |
| RGC | Royal Government of Cambodia | រាជរដ្ឋាភិបាលកម្ពុជា |
| SMART | Spatial Monitoring and Reporting Tool | ឧបករណ៍តាមដាននិងរាយការណ៍រូបវន្ត |
| SO | Strategic Objective | គោលបំណងជាយុទ្ធសាស្ត្រ |
| USD | US Dollars | ដុល្លាអាមេរិក |



# មាតិកា

សេចក្តីសង្ខេប.....១
១ .សេចក្តីផ្តើម.....៨
២. សេចក្តីអធិប្បាយអំពីឧទ្យានជាតិភ្នំគូលែន.....៨
២.១ .តម្លៃនៃធនធានធម្មជាតិ.....៨
២.២ .តម្លៃនៃបេតិកភណ្ឌវប្បធម៌.....១០
២.៣ .ប្រជាជន និងការប្រើប្រាស់ដី.....១០
២.៤ .តួនាទីស្ថាប័ន និងអង្គភាព.....១៣
២.៥. ហេដ្ឋារចនាសម្ព័ន្ធឧទ្យានជាតិ និងទេសចរណ៍.....១៤
៣. បញ្ហាប្រឈមចំពោះការគ្រប់គ្រង.....១៦
៣.១ ការរេចរឹល និងការបាត់បង់ព្រៃឈើ.....១៦
៣.២ កសិកម្ម.....១៧
៣.៣ ការល្បាត និងការអនុវត្តច្បាប់.....១៨
៣.៤ ការអភិវឌ្ឍទេសចរណ៍.....១៩
៣.៥. យុត្តាធិការត្រួតគ្នា.....២០
៤. កម្មវិធីគ្រប់គ្រង.....២១
៤.១ .ទស្សនៈវិស័យ បេសកកម្ម និងគោលដៅ.....២១
៤.២កម្មវិធីជាយុទ្ធសាស្រ្ត.....២១
កម្មវិធីទី១៖ ពង្រឹងកិច្ចការពារនិងអភិរក្សធនធានធម្មជាតិ និងបេតិកភណ្ឌវប្បធម៌.....២៣
កម្មវិធីទី២៖ ពង្រីកការចូលរួម និងផលប្រយោជន៍របស់សហគមន៍.....២៩
កម្មវិធីទី៣៖ ពង្រឹងសមត្ថភាពស្ថាប័ន និងកិច្ចសហការ.....៣៤
កម្មវិធីទី៤៖ ធានានិរន្តរភាពហិរញ្ញប្បទាន.....៣៦
៥.ការស្រាវជ្រាវ ពិនិត្យ និងតាមដាន.....៣៨
៦. ឯកសារយោង.....៤០
ឧបសម្ព័ន្ធ១. ផែនទីឧទ្យានជាតិភ្នំគូលែន.....៤១
ឧបសម្ព័ន្ធ២. សំណើតំបន់គ្រប់គ្រងសម្រាប់ឧទ្យានជាតិភ្នំគូលែន.....៤២
ឧបសម្ព័ន្ធ៣. សកម្មភាពដែលអាចអនុញ្ញាត និងសម្បទាសម្រាប់តំបន់គ្រប់គ្រងនីមួយៗ.....៤៣
ឧបសម្ព័ន្ធ ៤. សង្ខេបសន្ទស្សន៍ថវិកាសម្រាប់កម្មវិធីរយៈពេល ៥ ឆ្នាំ (២០១៨-២០២២).....៤៤
ឧបសម្ព័ន្ធ ៥. សង្ខេបគ្រោងថ្លៃចំណាយលើប្រតិបត្តិការ និងកម្មវិធីប្រចាំឆ្នាំ (២០១៨-២០២២).....៥០

## សេចក្តីសង្ខេប

ឧទ្យានជាតិព្រះជ័យវរ្ម័ន-នរោត្តម «ភ្នំគូលែន» មានភាពល្បីល្បាញដោយសារជាទីតាំងប្រវត្តិសាស្ត្រ ជាតំបន់បេតិកភណ្ឌវប្បធម៌ និងជាប្រភពទឹកដ៏មានសារសំខាន់សម្រាប់ខេត្តសៀមរាប។ ភ្នំគូលែននិយាយដោយឡែក ជាកន្លែងពេញនិយមសម្រាប់ការគោរពបូជា ដែលត្រូវបានប្រជាជនខ្មែរចាត់ទុកថាជាភ្នំពិសិដ្ឋបំផុតនៅកម្ពុជា និងជាដែនដីកំណើតនៃព្រះរាជាណាចក្រកម្ពុជា។ ប្រាសាទបុរាណ និងទីតាំងសក្ការៈជាច្រើនកន្លែង ដែលមានវ័យចំណាស់ចាប់ពីសតវត្សរ៍ទី៨ និងទី៩ មក ត្រូវបានរកឃើញនៅលើខ្នងភ្នំគូលែន។ ទីតាំងទឹកធ្លាក់ វត្តព្រះអង្គធំ បដិមាព្រះពុទ្ធចូលនិពាន្វដ៏ធំ និងស្ទឹង «លឹង្គមួយពាន់» រួមទាំងទីតាំងបុរាណស្ថានក្បាលស្ពាន សុទ្ធសឹងជាទីកន្លែងទាក់ទាញភ្ញៀវទេសចរច្រើនពាន់នាក់ មកទស្សនាជារៀងរាល់ថ្ងៃ ជាពិសេសនៅថ្ងៃបុណ្យចូលឆ្នាំ។

ប្រព័ន្ធអេកូឡូស៊ីព្រៃឈើក្នុងឧទ្យានជាតិភ្នំគូលែន ទោះបីនៅជាច់ដោយដុំ ស្ថិតនៅច្រើនកន្លែងក៏ដោយ ក៏វាបានផ្តល់ជាទីជម្រកសំខាន់សម្រាប់ពូជសត្វ និងរុក្ខជាតិច្រើនប្រភេទ ដែលកំពុងទទួលរងការគំរាមកំហែងនៅលើពិភពលោក។ សេវាប្រព័ន្ធអេកូឡូស៊ីសំខាន់ៗ ដែលផ្តល់ដោយឧទ្យានជាតិនេះ ផ្តោតលើព្រៃឈើ ដែលមានតួនាទីស្នូលប្រកបដោយវិសាលភាពធំធេងក្នុងខេត្តសៀមរាប និងមានតួនាទីជាប្រភពទឹកដ៏ចម្បងសម្រាប់ទីក្រុងសៀមរាប តាមរយៈប្រព័ន្ធទឹកក្រោមដី ដែលជួយរក្សាស្ថិរភាពនៃគ្រឹះប្រាសាទនានានៅតំបន់អង្គរផងដែរ។ ផ្លូវទឹកចំនួន ៣៦ ស្ថិតក្នុងខេត្ត ស្ទឹងសៀមរាបមានប្រភពពីឧទ្យានជាតិភ្នំគូលែន។ នៅរដូវប្រាំង ព្រៃឈើដើរតួនាទីជាកន្លែងស្រូបយកទឹកមករក្សាទុក ដើម្បីបញ្ចេញទៅបំពេញឱ្យប្រភពទឹកក្រោមដី។ គម្របព្រៃឈើក្នុងឧទ្យានជាតិភ្នំគូលែន បានថយចុះយ៉ាងច្រើនក្នុងទសវត្សរ៍កន្លងទៅនេះ ចាប់ពី ៨៦,៩% នៅឆ្នាំ២០០៣ មកត្រឹម ៥៥,៥% ក្នុងពេលបច្ចុប្បន្ន (កម្រងទិន្នន័យបម្រែបម្រួលគម្របព្រៃឈើនៃប្រពន្ធតំបន់ការពារធម្មជាតិ)។ ប្រសិនជាស្ថានភាពបែបនេះចេះតែបន្តទៅទៀត ព្រៃធម្មជាតិនៃឧទ្យានជាតិភ្នំគូលែន អាចបាត់បង់ក្នុងរយៈពេលពី ៥ឆ្នាំ ទៅ១០ឆ្នាំខាងមុខទៀត។

ការបាត់បង់ព្រៃឈើនៅក្នុងពេលថ្មីៗចុងក្រោយនេះ បានកើតមានឡើងដោយសារការធ្វើកសិកម្មរបស់ប្រជាពលរដ្ឋក្នុងសហគមន៍ កំណើនប្រជាពលរដ្ឋដែលមានចំនួនកើនឡើងខ្លាំងពុំធ្លាប់មានពីមុនមក និងការកើតមានការទន្ទ្រានកាន់កាប់ដីធ្លី។ ប្រជាពលរដ្ឋចំណូលស្រុកបានកើតមានយ៉ាងច្រើននៅក្នុងប៉ុន្មានឆ្នាំចុងក្រោយនេះ ភាគច្រើនដោយសារតែមានការអភិវឌ្ឍទេសចរណ៍។ ទម្លាប់តាមប្រពៃណីនៃការធ្វើដំណាំចំការពនេចរ សម្រាប់ដាំស្រូវនៅទីខ្ពស់ដែលពឹងផ្អែកលើទឹកភ្លៀង និងដំណាំដទៃទៀត ត្រូវបានជំនួសយ៉ាងឆាប់រហ័សដោយចំការដំណាំអចិន្ត្រៃយ៍ដូចជា ស្វាយចន្ទី ដែលបានបំប្លែងដីព្រៃ ទៅជាដីកសិកម្ម។ ការកាប់ឈើល្មើសច្បាប់ ដូចជា ការកាប់ឈើប្រណិត កាប់ឈើធ្វើអុសសម្រាប់ឡឥដ្ឋ និងអុសសម្រាប់ផលិតធ្យូង នៅតែបន្តកើតមាន ទោះបីជាមានវត្តមានមន្ត្រីល្បាតនៃក្រសួងបរិស្ថាន ឆ្មាំរបស់អាជ្ញាធរអប្សរា នគរបាលការពារបេតិកភណ្ឌ និងនគរបាលមូលដ្ឋាននៅក្នុងឧទ្យានជាតិនេះក៏ដោយ។ បញ្ហាខាងលើនេះអាចកើតមានឡើងដោយសារកត្តាកង្វះការកំណត់និងការបែងចែកតំបន់គ្រប់គ្រង ដែលអាចជួយបញ្ជាក់ឱ្យបានច្បាស់លាស់អំពីទីតាំងជាក់លាក់ ដែលត្រូវបានអនុញ្ញាត ឬមិនអនុញ្ញាតឱ្យប្រើប្រាស់ដីធ្លី។

ភ្ញៀវទេសចរចូលក្នុងឧទ្យានជាតិនេះ ភាគច្រើនពុំត្រូវបានកំណត់ចំនួនឡើយ ដែលនាំឱ្យកើតមានបញ្ហានៃកំណើនហួសកម្រិតនៃចំនួនមនុស្ស ដែលធ្វើឱ្យប៉ះពាល់ និងខូចខាតទីតាំងបុរាណស្ថាន ដែល

ងាយរងគ្រោះ កើតមានការចោលសំរាម និងការបំពុល ដែលមិនត្រឹមតែធ្វើឱ្យប៉ះពាល់ដល់អារម្មណ៍របស់ភ្ញៀវទេសចរប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងអាចធ្វើឱ្យខូចខាតហេដ្ឋារចនាសម្ព័ន្ធឧទ្យានជាតិនេះថែមទៀតផង។ បច្ចុប្បន្ននេះ ផលចំណូលដែលក្រុមហ៊ុនឯកជនទទួលបានពីកម្រៃសម្រាប់ការចូលកម្សាន្តនៅទីតាំងព្រះអង្គធំ ត្រូវបានប្រើប្រាស់តិចតួចប៉ុណ្ណោះ (ប្រសិនបើមាន) សម្រាប់ការវិនិយោគលើកិច្ចការពារនិងការគ្រប់គ្រងឧទ្យាននេះ។ លើសពីនេះ ភូមិបុរាណនានាដែលស្ថិតនៅតាមទីតាំងដាច់ស្រយាលក្នុងឧទ្យានជាតិនេះពុំទាន់បានទទួលផលចំណូលសមស្រប ពីភ្ញៀវទេសចរនាពេលបច្ចុប្បន្នឡើយ។ សមត្ថកិច្ចគ្រប់គ្រងរួមសម្រាប់ឧទ្យានជាតិនេះ ស្ថិតនៅក្រោមក្រសួងបរិស្ថាន ដែលមានអគ្គនាយកដ្ឋានរដ្ឋបាលការពារនិងអភិរក្សធម្មជាតិ និងអគ្គនាយកដ្ឋានសហគមន៍មូលដ្ឋានជាអ្នកប្រតិបត្តិ ដោយបានសហការជាមួយអាជ្ញាធរខេត្ត និងអាជ្ញាធរមូលដ្ឋាន។ អាជ្ញាធរជាតិអប្សរា ដែលស្ថិតនៅចំណុះក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ទទួលបន្ទុកការពារនិងគ្រប់គ្រងទីតាំងស្ថានីយបុរាណក្នុងឧទ្យានជាតិនេះ។ ទោះជាយ៉ាងណាក៏ដោយ កិច្ចសហការ និងភាពច្បាស់លាស់នៃ តួនាទីរបស់ស្ថាប័នរៀងៗខ្លួននៅក្នុងការគ្រប់គ្រងឧទ្យានជាតិនេះ នៅពុំទាន់មានបញ្ជាក់ច្បាស់នៅឡើយ ជាពិសេស ទាក់ទងនឹងការរៀបចំ និងការថែទាំ សម្រាប់បម្រើឱ្យវិស័យទេសចរណ៍ធម្មជាតិ និងវប្បធម៌។

ផលប៉ះពាល់នៅតំបន់ខ្សែទឹកខាងក្រោម បណ្តាលពីការបាត់បង់ព្រៃឈើនៅក្នុងឧទ្យានជាតិនេះ ដែលអាចមានកម្រិតធ្ងន់ធ្ងរមកលើសក្តានុពលនៃការអភិវឌ្ឍខេត្តសៀមរាបទៅថ្ងៃអនាគត និងការគំរាមកំហែងធ្ងន់ធ្ងរចំពោះគ្រឹះប្រាង្គ ប្រាសាទនានានៅក្នុងតំបន់បេតិកភណ្ឌពិភពលោកនេះ។ ដូច្នេះកិច្ចការពារ ការស្តារព្រៃឈើឡើងវិញ និងការងារថែទាំត្រូវតែជាកិច្ចការអាទិភាពនៃការគ្រប់គ្រងឧទ្យានជាតិនេះ។

កម្មវិធីគ្រប់គ្រងឧទ្យានជាតិព្រះជ័យវរ្ម័ន-នរោត្តម «ភ្នំគូលែន» (២០១៨-២០២៧) ផ្តោតលើកិច្ចការពារធនធានព្រៃឈើដែលនៅសេសសល់ ការអភិរក្សបេតិកភណ្ឌវប្បធម៌ ការពង្រីក និងការបង្កើនជម្រើសមុខរបរចិញ្ចឹមជីវិត រួមទាំងការពង្រឹងសមត្ថភាពស្ថាប័ន និងកិច្ចសហការ ដោយមាន ទស្សនៈវិស័យគ្រប់គ្រងធម្មជាតិ និងបេតិកភណ្ឌវប្បធម៌ក្នុងឧទ្យានជាតិភ្នំគូលែនឱ្យមាននិរន្តរភាព ក្រោមភាពជាដៃគូសកម្មជាមួយសហគមន៍មូលដ្ឋាន និងអ្នកពាក់ព័ន្ធដើម្បីជាប្រយោជន៍នៃប្រជាពលរដ្ឋកម្ពុជាជានិរន្តរ បេសកកម្មពង្រឹងតួនាទី និងសមត្ថភាពស្ថាប័ននៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ សម្រាប់ការអនុវត្តគោលនយោបាយច្បាប់ និងបទប្បញ្ញត្តិនានាឱ្យមានប្រសិទ្ធភាព ឱ្យមានសុក្រឹតភាពនៃការគ្រប់គ្រងធនធានធម្មជាតិ និងបេតិកភណ្ឌវប្បធម៌ក្នុងឧទ្យានជាតិភ្នំគូលែន គោលដៅរួម កាត់បន្ថយការបាត់បង់ និងការរេចរឹលព្រៃឈើ និងលើកកម្ពស់របរចិញ្ចឹមជីវិតសហគមន៍មូលដ្ឋាន ដែលនាំឱ្យបរិស្ថានមាននិរន្តរភាព និងសម្រេចបានការអភិរក្សធនធានធម្មជាតិ និងបេតិកភណ្ឌវប្បធម៌នៅក្នុងឧទ្យានជាតិភ្នំគូលែន ហើយមានកម្មវិធីជាយុទ្ធសាស្ត្រចំនួន បួន គឺ៖

**កម្មវិធីទី១ ៖** ពង្រឹងកិច្ចការពារ និងអភិរក្សធនធានធម្មជាតិ និងបេតិកភណ្ឌវប្បធម៌

**កម្មវិធីទី២ ៖** ពង្រីកការចូលរួម និងអត្ថប្រយោជន៍របស់សហគមន៍

**កម្មវិធីទី៣ ៖** ពង្រឹងសមត្ថភាពស្ថាប័ន និងកិច្ចសហការ

**កម្មវិធីទី៤ ៖** ធានានិរន្តរភាព ហិរញ្ញប្បទានសម្រាប់ឧទ្យានជាតិភ្នំគូលែន

ការកំណត់ព្រំប្រទល់ខាងក្រៅនៃឧទ្យានជាតិនេះនឹងត្រូវធ្វើឱ្យច្បាស់ ហើយផ្លាកសញ្ញាធំៗនឹងត្រូវដាក់នៅតាមច្រកធំៗនៃផ្លូវចូលទៅក្នុងឧទ្យានជាតិ។ តំបន់ការពារធម្មជាតិក្នុងឧទ្យានជាតិ នឹងត្រូវបែងចែកជាបួនតំបន់៖ តំបន់ស្នូល តំបន់អភិរក្ស តំបន់ប្រើប្រាស់ដោយចីរភាព និងតំបន់សហគមន៍ យោងតាមច្បាប់ស្តីពីតំបន់ការពារធម្មជាតិឆ្នាំ២០០៨។ តំបន់ស្នូល មានវិសាលភាពគ្របដណ្តប់លើព្រៃធម្មជាតិភាគច្រើន ដែលនៅសេសសល់លើភ្នំ ដែលត្រូវការពារដាច់ខាតដោយកំហិតលើការចេញចូល។ តំបន់អភិរក្សត្រូវប្រើប្រាស់ជា ទ្រនាប់ នៃតំបន់ស្នូល ដោយរួមបញ្ចូលតំបន់សហគមន៍ ការពារធម្មជាតិ (CPAs) ដែលមានស្រាប់ និងតំបន់ការពារបុរាណស្ថាន (APAs) ហើយត្រូវបានប្រើប្រាស់ជាកន្លែងសម្រាប់ការប្រមូលផលអនុផលព្រៃឈើ ដើម្បីប្រជាពលរដ្ឋក្នុងមូលដ្ឋានប៉ុណ្ណោះ។ កាលានុវត្តិភាពសម្រាប់ការបង្កើតសហគមន៍តំបន់ការពារធម្មជាតិ និងតំបន់ការពារបុរាណស្ថាន គួរតែបានសិក្សាស្វែងយល់ផងដែរ។ សម្រាប់តំបន់សហគមន៍គឺរាប់បញ្ចូលភូមិករ និងដីដាំដំណាំចាស់ នៅលើភ្នំគូលែនរបស់ពួកគាត់ រីឯកម្មសិទ្ធិដីសមូហភាពនឹងត្រូវពិចារណាសម្រាប់ភូមិទាំងនោះ។ ចំណែកឯតំបន់ប្រើប្រាស់ដោយចីរភាពនឹងរាប់បញ្ចូលសម្រាប់ការប្រើប្រាស់ក្នុងគោលដៅពាណិជ្ជកម្មជាទ្រង់ទ្រាយតូច (រួមទាំងចំការស្វាយចន្ទី) និងរបៀងទេសចរណ៍សម្រាប់ភ្ញៀវទេសចរធ្វើដំណើរទៅរមណីយដ្ឋានក្បាលស្ពាន និងព្រះអង្គធំ។

ការប្តូរទីលំនៅនឹងត្រូវអនុវត្តចំពោះប្រជាពលរដ្ឋចំនួន ៤១៥គ្រួសារ ដែលរស់នៅក្នុងភូមិកកើតថ្មីៗស្ថិតនៅទីតាំងព្រះអង្គធំ និងតាមច្រកចូលទៅកាន់ទីតាំងព្រះអង្គធំ។ ដីទំហំ ១៧៥ហិកតា នៅខាងក្រៅឧទ្យានជាតិនេះ ត្រូវបានអាជ្ញាធរខេត្តកំណត់ ត្រៀមផ្តល់ប័ណ្ណកម្មសិទ្ធិដី ផ្ទះសំបែង និងសេវាកម្មផ្សេងៗសម្រាប់គ្រួសារដែលប្តូរទីតាំង។ មុននឹង ប្តូរទីតាំង អាជ្ញាធរខេត្តត្រូវធានាឱ្យមានសេវា និងហេដ្ឋារចនាសម្ព័ន្ធគ្រប់គ្រាន់។ ការធ្វើជំរឿនប្រជាពលរដ្ឋ គឺជាកត្តាចាំបាច់ ដើម្បីឱ្យដឹងពីចំនួន ទីតាំង និងរយៈពេលតាំងទីលំនៅនៃគ្រួសារនានា ដែលកំពុងរស់នៅក្នុងឧទ្យានជាតិនេះ។

កិច្ចការពារ ការស្តារព្រៃឈើឡើងវិញ និងការថែទាំ នឹងត្រូវធ្វើឡើងដោយការពង្រឹងការអនុវត្តច្បាប់ការលើកទឹកចិត្តឱ្យមានការដាំដុះដើមឈើឡើងវិញតាមលក្ខណៈធម្មជាតិ ដោយធ្វើឡើងនៅតាមកន្លែងព្រៃរេចរឹលនានា នៅជិតព្រៃដែលមានស្រាប់ និងតាមរយៈការវិនិយោគលើការស្តារព្រៃឈើឡើងវិញ ដោយប្រើប្រាស់ពូជឈើក្នុងស្រុក នៅតាមទីតាំងអាទិភាពសំខាន់ៗ។ យ៉ាងហោចណាស់ដីទំហំ ១.០០០ហិកតានឹងត្រូវស្តារព្រៃឈើឡើងវិញឱ្យបានមុនឆ្នាំ២០២២។ សកម្មភាពដាំដុះព្រៃឈើឡើងវិញក្រោមការគាំទ្រនៃគម្រោងនានានៅក្នុងឧទ្យានជាតិនេះ នឹងទទួលបានការលើកទឹកចិត្ត ដូចជា គម្រោងមូលនិធិបន្សាំការប្រែប្រួលអាកាសធាតុ និងគម្រោងរេដបូកសាកល្បង។ ម៉្យាងទៀត ប្រភពទឹកលើភ្នំនេះ ក៏នឹងត្រូវបានថែរក្សាការពារផងដែរ ដែលជាផ្នែកមួយនៃកម្មវិធីនេះ។

ការអភិរក្សសត្វព្រៃនឹងត្រូវពង្រឹង ដោយការពង្រីកមូលដ្ឋានចំណេះដឹង កាត់បន្ថយការបរបាញ់ខុសច្បាប់ និងការនាំយកពូជសត្វក្នុងស្រុកមកចិញ្ចឹមឡើងវិញ។

ទីតាំងបេតិកភណ្ឌវប្បធម៌ នឹងស្ថិតក្រោមការតាមដាន និងការពារ ដោយសហការជិតស្និទ្ធជាមួយអាជ្ញាធរអប្សរា និងអង្គការ ADF។ ការគ្រប់គ្រង និងការការពារតំបន់បុរាណស្ថានប្រកបដោយសក្តានុពលនឹងទទួលបាននូវការឧបត្ថម្ភគាំទ្រ។ ប្រសិនបើចាំបាច់ តំបន់ការពារជុំវិញប្រាសាទបុរាណអាចត្រូវបានបង្កើត

ឡើងដោយផ្អែកលើមូលដ្ឋានច្បាប់ និងបទប្បញ្ញត្តិដែលមានស្រាប់ ដើម្បីការពារពីការទន្រ្ទាន ឬការធ្វើឱ្យខូចខាតបន្ថែមទៀតចំពោះតំបន់បេតិកភណ្ឌទាំងនោះ។

អាទិភាពសម្រាប់ការគ្រប់គ្រង និងការគាំទ្រប្រជាសហគមន៍នឹងត្រូវផ្តល់ទៅឱ្យភូមិចាស់ចំនួនប្រាំនៅក្នុងឃុំខ្នងភ្នំ (អន្លង់ធំ តាពេញ សង្កែឡាក់ ខ្លាឃ្មុំ និងថ្មជ្រួញ) ដែលកំពុងគ្រប់គ្រងសហគមន៍តំបន់ការពារធម្មជាតិ។ ការរៀបចំផែនការតាមបែបចូលរួមនឹងត្រូវធ្វើឡើង ដើម្បីកែសម្រួលព្រំប្រទល់នៃតំបន់ការពារធម្មជាតិនីមួយៗ ដែលបានស្នើឡើង ដោយជំរុញការយល់ដឹងអំពីច្បាប់ និងបទប្បញ្ញត្តិនានា ដែលទាក់ទងនឹងការប្រើប្រាស់ធនធានធម្មជាតិតាមប្រពៃណី និងស្វែងយល់ ក្នុងការបង្កើតឱកាសសម្រាប់ការល្បាតរួមគ្នាជាមួយមន្រ្តីល្បាត ការចូលរួមក្នុងសកម្មភាពស្តារព្រៃឈើឡើងវិញ និងការអភិវឌ្ឍទេសចរណ៍។ ការគាំទ្រជាបន្តដល់សហគមន៍តំបន់ ការពារធម្មជាតិដែលមានស្រាប់ ជាអាទិ៍ ការជួយដល់ការបង្កើយផែនការគ្រប់គ្រងសហគមន៍តំបន់ការពារធម្មជាតិ និងការធ្វើសមាហរណកម្មផែនការទាំងនេះទៅក្នុងផែនការវិនិយោគឃុំ។ គណៈកម្មការមូលដ្ឋានមួយសម្រាប់ជួយដល់ការគ្រប់គ្រងឧទ្យានជាតិនឹងត្រូវបង្កើតឡើងដើម្បីអនុវត្តកម្មវិធីសហការគ្រប់គ្រងនៅតាមមូលដ្ឋាន។

កិច្ចប្រឹងប្រែងនឹងត្រូវធ្វើជាបន្តក្នុងការកែប្រែពីការធ្វើកសិកម្មពនេចរ និងការកាត់បន្ថយការពឹងផ្អែកលើចំការស្វាយចន្ទី ដោយការណែនាំវិធីសាស្រ្តកសិ-រុក្ខកម្មថ្មីៗ ដែលអាចផ្តល់ផលិតផលចម្រុះជាងមុន ចំណេញជាងមុន និងដែលមានមេត្រីភាពជាមួយបរិស្ថាន។ ការងារដែលបានធ្វើដោយអង្គការ ADF ជាមួយកសិករនៅមូលដ្ឋានគឺការកាត់បន្ថយផលប៉ះពាល់មកលើព្រៃឈើ ដោយការកែប្រែទម្លាប់តាមប្រពៃណីក្នុងការធ្វើកសិកម្មទៅរកសកម្មភាពដែលផ្តល់ទិន្នផលខ្ពស់ និងទទួលបានការគាំទ្រ។ សហគមន៍មូលដ្ឋានក៏នឹងពាក់ព័ន្ធកាន់តែផ្ទាល់ជាងមុននៅក្នុងកិច្ចការពារ ការស្តារព្រៃឈើឡើងវិញ និងការថែទាំ (រួមទាំងការបង្កើត និងការថែទាំថ្នាលបណ្តុះកូនឈើ)។

យុទ្ធសាស្រ្តគ្រប់គ្រងទេសចរណ៍នឹងត្រូវរៀបចំឡើងដោយក្រសួងបរិស្ថាន ដោយសហការជាមួយអាជ្ញាធរខេត្ត អាជ្ញាធរមូលដ្ឋាន ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និងក្រសួងទេសចរណ៍ ដើម្បីបង្កើតបទពិសោធដល់ភ្ញៀវទេសចរ និងសម្បទានទេសចរណ៍នៅក្នុងឧទ្យានជាតិនេះ។ យុទ្ធសាស្រ្តនេះនឹងចែងពីលក្ខខណ្ឌសម្រាប់ភ្ញៀវទេសចរទូទៅ ដោយផ្តោតលើការទស្សនាទីកន្លែងដែលមានភាពទាក់ទាញខាងផ្នែកវប្បធម៌ និងទេសចរណ៍ដែលប្រតិបត្តិការដោយអ្នកនៅក្នុងមូលដ្ឋាន។ អាជ្ញាធរខេត្តក៏នឹងសម្របសម្រួលចុះបញ្ជី និងតាមដានប្រតិបត្តិករទេសចរណ៍ផងដែរ ដើម្បីធានាសុវត្ថិភាពសម្រាប់ភ្ញៀវទេសចរជាតិ និងអន្តរជាតិ។ សកម្មភាពនេះមានជាអាទិ៍៖ ការរៀបចំសម្ភារៈសម្រាប់ការផ្តល់ព័ត៌មានអំពីឧទ្យានជាតិ (កូនសៀវភៅ/ផែនទី/មណ្ឌលព័ត៌មាន) មគ្គុទ្ទេសក៍ និងស្លាកសញ្ញា ព្រមទាំងការបណ្តុះបណ្តាលអ្នកភូមិនៅក្នុងសហគមន៍ឱ្យមានការចូលរួមកាន់តែសកម្ម និងទទួលផលពីទេសចរណ៍ផងដែរ។ សម្បទានទេសចរណ៍ឯកជននឹងត្រូវផ្ទេរមកឱ្យក្រសួងបរិស្ថានវិញ ហើយផលចំណូលពីការលក់សំបុត្រចូលនឹងត្រូវវិនិយោគឡើងវិញលើការគ្រប់គ្រង និងការអភិរក្សឧទ្យានជាតិ។ ការគ្រប់គ្រងសំណល់ត្រូវធ្វើឡើងដោយការផ្តល់មធ្យោបាយគ្រប់គ្រាន់សម្រាប់ការទុកដាក់ ការយកចេញ ទាំងសំណល់រាវ និងរឹង ដែលកើតមាននៅក្នុងឧទ្យានជាតិ។

បន្ថែមលើការពង្រឹងសមត្ថភាពការអនុវត្តច្បាប់ (តាមរយៈវគ្គបណ្ដុះបណ្ដាល និងការបង្កើនគុណភាពបរិក្ខារនានា) ទាំងមន្ត្រីល្បាត និងអាជ្ញាធរ ថ្នាក់ខេត្ត ស្រុក និងឃុំនឹងទទួលបានការបណ្តុះបណ្តាលអំពីវិធីចូលរួម ដើម្បីអាចឱ្យសហគមន៍មូលដ្ឋានចូលរួមនៅក្នុងការរៀបចំផែនការ និងការគ្រប់គ្រងតំបន់ការពារធម្មជាតិ។ សមត្ថភាពបច្ចេកទេសនៃមន្ទីរបរិស្ថានខេត្តនឹងត្រូវពង្រីក ដើម្បីត្រួតពិនិត្យ និងគាំទ្រដល់ការអនុវត្តកម្មវិធីគ្រប់គ្រងឧទ្យានជាតិនេះ ហើយនឹងមានការពិចារណាផងដែរចំពោះការបង្កើនចំនួនមន្ត្រីល្បាតនាអនាគតដើម្បីអាចគ្រប់គ្រង និងទទួលខុសត្រូវប្រកបដោយ ប្រសិទ្ធភាព បន្ទាប់ពីការផ្ទេរសម្បទានឯកជនលើកិច្ចការទេសចរណ៍មកក្រសួងបរិស្ថានវិញ។

កិច្ចសហការជិតស្និទ្ធជាមួយអាជ្ញាធរអប្សរា រដ្ឋបាលព្រៃឈើ ក៏ដូចជាអង្គការអភិរក្សនានា ដែលបាននឹងកំពុងធ្វើការនៅក្នុងឧទ្យាននេះជាច្រើនឆ្នាំមកហើយ (អង្គការADF និងអង្គការACCB) មានសារៈសំខាន់ខ្លាំងណាស់ ទន្ទឹមនឹងការអនុវត្តកម្មវិធីគ្រប់គ្រងនេះនៅតាមកន្លែងនានា។ ការវាយតម្លៃពេញលេញមួយអំពីគុណតម្លៃនៃទីជម្រាលក្នុងឧទ្យានជាតិនេះ និងគុណតម្លៃខាងសេដ្ឋកិច្ចចំពោះខេត្តសៀមរាប គួរតែបានធ្វើឡើងផងដែរ ដើម្បីស្វែងយល់ឱ្យបានពេញលេញអំពីតម្លៃនៃធនធានធម្មជាតិ ក៏ដូចជាផលវិបាកនានា និងថ្លៃខូចខាតបណ្តាលមកពីការខកខានមិនបានការពារធនធានធម្មជាតិទាំងនោះ។

ថ្លៃប៉ាន់ស្មានសម្រាប់ការអនុវត្តកម្មវិធីគ្រប់គ្រងឧទ្យានជាតិ សម្រាប់រយៈពេល ៥ឆ្នាំ (២០១៨-២០២២) គឺប្រមាណ ២,៨លានដុល្លាអាមេរិក ដែលហួសកម្រិតសមត្ថភាពថវិកាបច្ចុប្បន្នរបស់រាជរដ្ឋាភិបាលដែលច្រើនតែសម្រាប់ចំណាយលើប្រាក់បៀវត្សរ៍ និងថ្លៃចំណាយប្រតិបត្តិការជាមូលដ្ឋានខ្លះៗប៉ុណ្ណោះ។ ច្រើនជាង ៥០% នៃថ្លៃចំណាយសម្រាប់កម្មវិធីនេះ ត្រូវបានវិភាជន៍សម្រាប់សកម្មភាពដាំព្រៃឈើឡើងវិញដើម្បីដាំស្តារគម្របព្រៃឈើ ធម្មជាតិឡើងវិញជាបន្តបន្ទាប់នៅក្នុងឧទ្យានជាតិ។ ដើម្បីរក្សានិរន្តរភាពនៃការវិនិយោគលើឧទ្យានជាតិ ចាំបាច់ត្រូវឱ្យមានហិរញ្ញប្បទាន ពីប្រភពផ្សេងៗ ដែលរួមទាំងការបង្កើតគណនីថវិកាដោយឡែកសម្រាប់ឧទ្យានជាតិនេះ ផលចំណូលពីថ្លៃលក់សំបុត្រដល់ភ្ញៀវទេសចរ ដែលអាចយកមកវិនិយោគឡើងវិញដោយផ្ទាល់សម្រាប់ការគ្រប់គ្រងឧទ្យានជាតិ ការស្រាវជ្រាវ និងការរចនានៃគម្រោងហិរញ្ញប្បទានបន្ថែមទៀត ដោយផ្អែកលើតម្លៃទីជម្រាល និងការបន្តឧបត្ថម្ភពីដៃគូអភិវឌ្ឍន៍នានាផងដែរ។

ការអនុវត្តកម្មវិធីគ្រប់គ្រងឧទ្យានជាតិភ្នំគូលែន នឹងស្ថិតក្រោមការចាត់ចែង និងសម្របសម្រួលដោយក្រុមការងារភ្នំគូលែន និងមានគណៈកម្មការគ្រប់គ្រងឧទ្យានជាតិនេះនៅក្នុងមូលដ្ឋាន ជាស្ថាប័នប្រតិបត្តិ។ ការតាមដានវឌ្ឍនភាពនៃការអនុវត្តកម្មវិធីគ្រប់គ្រងឧទ្យានជាតិភ្នំគូលែននឹងត្រូវធ្វើឡើងប្រចាំឆ្នាំដោយមន្ទីរបរិស្ថាន និងរាយការណ៍មកក្រសួងបរិស្ថាន។ ការត្រួតពិនិត្យវាយតម្លៃពេញលេញមួយនឹងត្រូវធ្វើឡើងនៅក្រោយរយៈពេល ៥ឆ្នាំ (ឆ្នាំ២០២២) ហើយកម្មវិធីនេះនឹងត្រូវកែសម្រួលឡើងវិញតាមការចាំបាច់ និងបន្តសម្រាប់រយៈពេល ៥ ឆ្នាំទៀត។





# កម្មវិធីគ្រប់គ្រងឧទ្យានជាតិ ព្រះជ័យវរ្ម័ន-នរោត្តម "ភ្នំគូលែន" ២០១៨-២០២៧

## ១ .សេចក្តីផ្តើម

ឧទ្យានជាតិព្រះជ័យវរ្ម័ន-នរោត្តម «ភ្នំគូលែន» ត្រូវបានកំណត់ដោយព្រះរាជក្រឹត្យនៅឆ្នាំ១៩៩៣។ ក្នុងឆ្នាំ២០០៣ ក្រសួងបរិស្ថានបានបោះពុម្ពផែនទីផ្លូវការ ដោយបញ្ជាក់ថា ឧទ្យានជាតិនេះមានទំហំផ្ទៃដីសរុបចំនួន ៣៧.៣៧៥ហិកតា។ ព័ទ្ធជុំវិញដោយទំនាបលិចទឹកបឹងទន្លេសាប ជួរភ្នំគូលែនកកើតឡើងដោយថ្មភក់ ដែលមានរយៈកម្ពស់អតិបរមា ៤៩៨ម៉ែត្រ ធៀបនឹងកម្ពស់ទឹកសមុទ្រ។ ឧទ្យានជាតិនេះស្ថិតនៅក្នុងស្រុកចំនួនបី (ស្វាយលើ បន្ទាយស្រី និងវ៉ារិន) នៃខេត្តសៀមរាប និងស្ថិតនៅចម្ងាយប្រមាណ ៤៨គីឡូម៉ែត្រ ពីទីរួមខេត្តសៀមរាប។ ពលរដ្ឋខ្មែរបានចាត់ទុកភ្នំគូលែនជាភ្នំសក្តិសិទ្ធជាងគេនៅកម្ពុជា និងជាកន្លែងពេញនិយមសម្រាប់ការគោរពបូជានៅចុងសប្តាហ៍ និងនៅពេលបុណ្យម្តងៗ។ ភ្នំគូលែនបានដើរតួនាទីសំខាន់ក្នុងប្រវត្តិសាស្ត្រនៃចក្រភពខ្មែរ ដោយនៅឆ្នាំ៨០២ នៃគ្រឹះសករាជ ព្រះបាទជ័យវរ្ម័នទី២ បានប្រកាសខ្លួនជាស្តេចទេវរាជ (ស្តេចចក្រពត្តិ) នៅទីនោះ។ ភ្នំគូលែន ក៏ជាជំរុំចុងក្រោយនៃទ័ពខ្មែរក្រហមផងដែរ ដែលបានបោះបង់ចោលនៅឆ្នាំ១៩៩៨។

កម្មវិធីគ្រប់គ្រងឧទ្យានជាតិព្រះជ័យវរ្ម័ន-នរោត្តម «ភ្នំគូលែន» សម្រាប់រយៈពេលដប់ឆ្នាំខាងមុខ (២០១៨-២០២៧) នឹងផ្តល់ការណែនាំសម្រាប់ការងារការពារការគ្រប់គ្រង និងការប្រើប្រាស់ឧទ្យានជាតិដោយនិរន្តរភាព។ កម្មវិធីនេះត្រូវបានផ្តួចផ្តើមឡើងដោយ **ឯកឧត្តម សាយ សំអាល់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន** និងរៀបចំចងក្រងដោយក្រុមការងារកម្មវិធីគ្រប់គ្រងឧទ្យានជាតិព្រះជ័យវរ្ម័ន-នរោត្តម «ភ្នំគូលែន» ដែលបានបង្កើតជាផ្លូវការនៅខែតុលា ឆ្នាំ២០១៦ ដោយមានអគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាលការពារ និងអភិរក្សធម្មជាតិ (GDANCP) ជាប្រធាន។ ក្រុមការងារនេះមានសមាជិកចំនួន ៣១រូប ដែលតំណាងឱ្យក្រសួង និងស្ថាប័នពាក់ព័ន្ធនានានៃរាជរដ្ឋាភិបាលកម្ពុជា អង្គការជាតិនិងអន្តរជាតិ និងអាជ្ញាធរមូលដ្ឋាន។ គោលដៅចម្បងនៃក្រុមការងារឧទ្យានជាតិភ្នំគូលែន គឺរៀបចំកម្មវិធីយុទ្ធសាស្ត្រគ្រប់គ្រង ដើម្បីធ្វើការអភិរក្សធនធានធម្មជាតិ ការការពារបេតិកភណ្ឌវប្បធម៌ និងការពង្រីកបរិបញ្ញើមជីវិតរបស់ប្រជាសហគមន៍មូលដ្ឋាននៅក្នុងឧទ្យានជាតិនេះ។

## ២. សេចក្តីអធិប្បាយអំពីឧទ្យានជាតិភ្នំគូលែន

### ២.១. តម្លៃនៃធនធានធម្មជាតិ

ឧទ្យានជាតិភ្នំគូលែន ត្រូវបានចាត់ទុកថាមានតម្លៃខ្ពស់សម្រាប់ការអភិរក្ស ដោយផ្អែកលើទិដ្ឋភាពចម្បងៗចំនួនបី៖ លក្ខខណ្ឌប្រព័ន្ធអេកូឡូស៊ី សេវាកម្មប្រព័ន្ធអេកូឡូស៊ី និងមុខងារសង្គម (Hayes et al., 2013)។ គម្របព្រៃឈើភាគច្រើនផ្សំដោយប្រភេទព្រៃស្រោង ព្រៃពាក់កណ្តាលស្រោង និងព្រៃល្បោះ។ ឧទ្យានជាតិភ្នំគូលែន ជាតំបន់ព្រៃឈើមួយផ្នែកនៅកម្ពុជា ដែលមាននៅសល់ព្រៃស្រោងហើយស្ថិតនៅភាគខាងជើងនៃប្រទេស។ ឧទ្យានជាតិនេះមានប្រភេទរុក្ខជាតិដែលរងការគំរាមកំហែងចំនួន ១០ប្រភេទ

ក្នុងចំណោមពូជរុក្ខជាតិ ៤០ប្រភេទ ដែលទទួលរងនូវការគំរាមកំហែងនៅកម្ពុជា ដែលមានឈ្មោះនៅក្នុងបញ្ជីក្រហមនៃអង្គការ IUCN។ ប្រភេទឈើ ដែលមានឈ្មោះថា គូលែន (Litchi chinensis) មានដុះតែនៅក្នុងតំបន់នេះ នាំឱ្យអ្នកស្រុកដាក់ឈ្មោះថា ភ្នំគូលែន។

មកទល់បច្ចុប្បន្ន ការស្រាវជ្រាវពីជីវៈចម្រុះក្នុងឧទ្យានជាតិនេះបានរកឃើញ ប្រភេទរុក្ខជាតិសរុបចំនួន ២៨ប្រភេទ ដែលមានចុះក្នុងបញ្ជីអង្គការ IUCN ជាប្រភេទដែលត្រូវផ្តោតការយកចិត្តទុកដាក់ជាអន្តរជាតិ។ ប្រព័ន្ធអេកូឡូស៊ីព្រៃឈើនៃឧទ្យានជាតិនេះ ទោះបីនៅដាច់ដោយដុំៗទៅតាមទីកន្លែងជាច្រើនក៏ដោយ ក៏បានផ្តល់ទីជម្រកសំខាន់ៗសម្រាប់ប្រភេទរុក្ខជាតិដែលប្រឈមហានិភ័យដូចបានរៀបរាប់ខាងលើ និងអាចមានតួនាទីជាប្រភពហ្សែន សម្រាប់ការអភិរក្សជីវៈចម្រុះ។ ប្រភេទឈើចំនួន ១០ ក្នុងចំណោមឈើចំនួន ៣២ប្រភេទ ដែលបានចុះក្នុងបញ្ជីក្រហមនៃអង្គការ IUCN មានវត្តមាននៅក្នុងឧទ្យានជាតិភ្នំគូលែននេះ ហើយប្រភេទទាំងនោះភាគច្រើនមានដោយកម្របំផុត ដោយសារតែសកម្មភាពកាប់ឈើល្មើសច្បាប់ពីអតីតកាល និងក្នុងបណ្តាឆ្នាំកន្លងទៅថ្មីៗ។ ទាក់ទងនឹងសត្វនៅទីនេះមាន ថលជលិក និងល្មូនជាច្រើនប្រភេទ ក៏ដូចជា សត្វប្រចៀវដែលមានកំណត់ត្រាចំនួន ២៥ប្រភេទ។ ឧទ្យានជាតិនេះ មានប្រមាណ ៤០% នៃប្រភេទសត្វប្រចៀវដែលត្រូវបានគេទទួលស្គាល់នៅកម្ពុជា (២៥ប្រភេទក្នុងចំណោម ៦៨ប្រភេទ) ហើយមាននៅកន្លែងផ្សេងទៀតមួយចំនួនតូចប៉ុណ្ណោះ ដែលគេស្គាល់ថាមានប្រចៀវច្រើនប្រភេទជាងនេះ (Hayes et al., 2013)។

សេវាប្រព័ន្ធអេកូឡូស៊ីសំខាន់ៗដែលមាននៅក្នុងឧទ្យានជាតិ ដើរតួនាទីស្នូលដល់ជួរភ្នំ ដែលតំបន់នោះគ្របដោយគម្របកើតពីថ្មភក់ ព្រៃឈើ និងជាប្រភពទឹកដ៏សំខាន់សម្រាប់ក្រុងសៀមរាប ព្រមទាំងប្រព័ន្ធទឹកក្រោមដីដែលរក្សាស្ថិរភាពនៃ គ្រឹះប្រាសាទនានាក្នុងតំបន់អង្គរ ហើយមានបណ្តាញផ្លូវទឹកចំនួន ៣៦ នៅខេត្តសៀមរាបមានប្រភពនៅក្នុងឧទ្យានជាតិនេះ។ នៅរដូវប្រាំង ព្រៃឈើដើរតួជាអេប៉ុង រក្សាស្តុកទឹកទុក និងទឹកក្រោមដី។ ឧទ្យានជាតិនេះជាកន្លែងដែលបានថែរក្សាការពារព្រៃឈើក្នុងវិសាលភាពធំជាងតំបន់ផ្សេងៗទៀតនៃខេត្តសៀមរាប និងរក្សានិយ័តភាពសំខាន់សម្រាប់ផ្តល់ទឹកគ្រប់រដូវ តាមរយៈស្ទឹង និងអូរនានា ក៏ដូចជាទឹកក្រោមដីផងដែរ។ ទីជម្រាលស្ទឹងសៀមរាបត្រូវបានចាត់ជាទីជម្រាលសំខាន់មួយក្នុងចំណោមទីជម្រាលចំនួនបួននៅកម្ពុជា ដែលបានសិក្សាដោយគម្រោងគ្រប់គ្រងទីជម្រាលនៃ MRC-GTZ (Kalyan et al., 2004)។ ទឹកដែលហូរពីឧទ្យានជាតិនេះ ត្រូវបានចាត់ទុកថាជាទឹកមន្ត ឬទឹកអម្រឹត។

ក្នុងន័យសេដ្ឋកិច្ច ប្រព័ន្ធអេកូឡូស៊ីព្រៃឈើ ផ្តល់គុណតម្លៃពិសេសដល់ប្រជាពលរដ្ឋក្នុងមូលដ្ឋានតាមរយៈការអភិវឌ្ឍអេកូទេសចរណ៍ និងការទាញយកធនធានធម្មជាតិសម្រាប់ការប្រើប្រាស់ផ្ទាល់ក្នុងគ្រួសារ និងសម្រាប់ពាណិជ្ជកម្មអនុផលព្រៃឈើជាទ្រង់ទ្រាយតូច (មានដូចជា រុក្ខជាតិឱសថ និងគ្រឿងក្រអូប ផ្លែឈើព្រៃ និងជ័រទឹក)។

គម្របព្រៃក្នុងឧទ្យានជាតិ បានថយចុះជាខ្លាំងក្នុងទសវត្សរ៍កន្លងទៅ។ ក្នុងបណ្តាឆ្នាំកន្លងមកនេះ គម្របព្រៃឈើត្រូវបានអគ្គនាយកដ្ឋានរដ្ឋបាលការពារនិងអភិរក្សធម្មជាតិ វាយតម្លៃមានប្រមាណ ៥៥,៥% យោងតាមសៀវភៅកម្រងទិន្នន័យបម្រែបម្រួលគម្របព្រៃឈើ នៃប្រព័ន្ធតំបន់ការពារធម្មជាតិឆ្នាំ២០០៦-២០១៦។ ដីព្រៃក្រៅពីនេះនៅក្នុងឧទ្យានជាតិត្រូវបានប្រែក្លាយជាដីកសិកម្ម (ឧបសម្ព័ន្ធ ១)។

## ២.២. តម្លៃនៃបេតិកភណ្ឌវប្បធម៌

ភ្នំគូលែន ធ្លាប់តែមានសារៈសំខាន់ខាងបុរាណវិទ្យា វប្បធម៌ និងសាសនា ហើយបច្ចុប្បន្នក៏នៅតែជាទីតាំងគោរពបូជាសម្រាប់ប្រជាជនកម្ពុជា។ ទឹកធ្លាក់យ៉ាងធំមួយកន្លែង វត្តព្រះអង្គធំ ដែលមានព្រះពុទ្ធបដិមាយ៉ាងធំក្នុងទម្រង់ចូលនិពា្វន ស្ទឹង «លឹង្គមួយពាន់» និងរមណីយដ្ឋានក្បាលស្ពាន ជាទីកន្លែងទាក់ទាញភ្ញៀវជាច្រើនរយនាក់ក្នុងមួយថ្ងៃៗ និងរហូតដល់ច្រើនពាន់នាក់ នៅពេលមានពិធីបុណ្យប្រចាំឆ្នាំ។ នៅជិតផ្នែកខាងលើនៃតំបន់ទឹកធ្លាក់មានបុរាណស្ថានមួយកន្លែងហ៊ុំព័ទ្ធដោយព្រៃដែលមានឈ្មោះថា ប្រាសាទក្រោលរមាស សង់នៅសតវត្សរ៍ទី១២។ ប្រាសាទពេងចិន មានរាងជាពីរ៉ាមីត ឬប្រាសាទភ្នំ ត្រូវបានសាងសង់នៅសម័យអង្គរ។ នៅទីជាច់ស្រយាលជាងនេះ មានរូបសំណាកសត្វយ៉ាងធំធ្វើពីថ្មភ្នំ ដែលមានឈ្មោះថា ស្រះដំរី។

អង្គការ ADF បានឱ្យដឹងអំពីវត្តមានយ៉ាងច្រើននៃទីតាំងបុរាណស្ថាន ដែលកើតមានឡើងមុនសម័យអង្គរ ស្ថិតនៅខ្ពង់រាបខាងកើតនៃខ្នងភ្នំគូលែន បង្ហាញពីរបកគំហើញខាងបុរាណវិទ្យាធំជាងគេបង្អស់នៅកម្ពុជា ក្នុងរយៈពេល៥០ឆ្នាំចុងក្រោយនេះ។ ដោយប្រើប្រាស់បច្ចេកវិទ្យាស្កេន LIDAR ប្រាសាទ និងទីតាំងពិសិដ្ឋចំនួន ៥០កន្លែង ត្រូវបានរកឃើញ ដោយមានស្ថានភាពខុសៗគ្នា មានទាំងបណ្តាញទីក្រុង ដែលត្រូវបានសាងសង់ចាប់តាំងពី សតវត្សរ៍ទី៩ (Evans et al., 2013)។ នៅខែធ្នូ ឆ្នាំ២០១២ អង្គការយូណេស្កូ បានលើកសំណើឱ្យមានការពិចារណាសម្រាប់ដាក់បញ្ចូលភ្នំគូលែនទៅក្នុងបញ្ជីបេតិកភណ្ឌពិភពលោកដោយភ្ជាប់ជាមួយតំបន់អង្គរ (Phnom Penh Post 2016)។

## ២.៣. ប្រជាជន និងការប្រើប្រាស់ដី

នាឆ្នាំកន្លងទៅថ្មីៗ ប្រជាពលរដ្ឋចំណូលស្រុកបានមកតាំងទីលំនៅយ៉ាងច្រើនក្នុងតំបន់នេះ ដោយបច្ចុប្បន្ន អាចមានប្រជាពលរដ្ឋរហូតដល់ ២.០០០គ្រួសារ (ឬច្រើនជាង ៨.០០០នាក់) រស់នៅក្នុងព្រំប្រទល់នៃឧទ្យានជាតិនេះ (S. Sakhan, Deputy Park Manager, pers. comm.)។ ប្រជាពលរដ្ឋមានចំនួនច្រើនជាងគេនៅជុំវិញទីកន្លែងអភិវឌ្ឍន៍ទេសចរណ៍ ដែលគ្រប់គ្រងដោយក្រុមហ៊ុនឧគរគោកធ្លក[1]។ ឧទាហរណ៍បច្ចុប្បន្ននេះ យ៉ាងហោចណាស់ មានប្រជាពលរដ្ឋ ២១៨ គ្រួសារ រស់នៅព្រះអង្គធំ (ជិតកន្លែងទឹកធ្លាក់) ដែលប្រជាពលរដ្ឋត្រឹម ២៩គ្រួសារប៉ុណ្ណោះ បានមករស់ក្នុងឆ្នាំ២០០២ (Wildlife Alliance, 2013)។ គ្មានការផ្តល់កម្មសិទ្ធិដីជាផ្លូវការឡើយដល់ភូមិនានា ឬការប្រើប្រាស់ដីនាពេលបច្ចុប្បន្ន។

កន្លែងសំខាន់ៗចំនួនពីរក្នុងឧទ្យានជាតិ ដែលប្រជាពលរដ្ឋបានប្រមូលផ្តុំគឺ នៅខ្ពង់រាបខាងកើត (ឃុំខ្នងភ្នំ) ដែលមានភូមិចំនួន ៩ បានការទទួលស្គាល់ដោយអាជ្ញាធរឃុំ និងតាមដងផ្លូវលេខ ៦៧ (ឃុំឃុនរាម) ដែលមានភូមិចំនួនមួយ (ខ្នារង្វាស) ដែលស្ថិតនៅជិតក្បាលស្ពាន។ ក្នុងចំណោមភូមិទាំង ៩ ដែលមានការទទួលស្គាល់នៅលើខ្ពង់រាបខាងកើត ភូមិចំនួន ៥ ត្រូវបានចាត់ទុកជា «ភូមិចាស់» (អន្លង់ធំ តាពេញ សង្កែឡាក់ ខ្លាឃ្មុំ និងថ្មជ្រួញ) ដែលមានប្រជាពលរដ្ឋសរុបចំនួន ៥៧២គ្រួសារ (២.៨១២នាក់)

---

[1] *ថ្មីៗនេះ ក្រុមហ៊ុននេះបានប្តូរឈ្មោះជា ក្រុមហ៊ុនទេសចរណ៍អាស៊ីយ៉ាណា (ដែលមានការិយាល័យនៅសណ្ឋាគារក្រុងអង្គរ នៅសៀមរាប) ទោះបីបុគ្គលិកនៅបញ្ជរបង់ប្រាក់ នៅតែមានឯកសណ្ឋានរូបឧគរគោកធ្លកក៏ដោយ។*

នេះបើយោងតាមឯកសាររបស់ក្រសួងមហាផ្ទៃ ក្នុងខែមេសា ឆ្នាំ២០១៧ (តារាង១)។ ចំណែកភូមិបួនផ្សេងទៀត ត្រូវបានបង្កើតឡើងក្នុងរយៈពេល១៥ឆ្នាំកន្លងទៅនេះ (ពពេល ព្រះអង្គធំ ភូមិថ្មី និងតាហាន) ដែលមានប្រជាពលរដ្ឋប្រមាណ ៤១៨គ្រួសារ (១.៧៥៣នាក់)។

*តារាង១. ទិន្នន័យចំនួនប្រជាជននៅលើខ្ពង់រាបខាងកើតនៃឧទ្យាននេះ*

| ភូមិ | ចំនួនគ្រួសារ | ចំនួនប្រជាជន |
|---|---|---|
| ក. ឃុំខ្នងភ្នំ –ភូមិចាស់ | | |
| ១. អន្លង់ធំ | ២១៨ | ១.១៤២ |
| ២. តាពេញ | ១២៧ | ៦០៧ |
| ៣. សង្កែឡាក់ | ៨៧ | ៤១៣ |
| ៤. ខ្លាំឃ្មុំ | ៦៨ | ៣១០ |
| ៥. ថ្មជ្រួញ | ៧២ | ៣៤០ |
| សរុប | **៥៧២** | **២.៨១២** |
| ខ. ឃុំខ្នងភ្នំ –ភូមិថ្មីៗ | | |
| ១. ពពេល | ៩៧ | ៤១២ |
| ២. ព្រះអង្គធំ | ២១៧ | ៨៥៣ |
| ៣. ភូមិថ្មី | ៥១ | ២៥៥ |
| ៤. តាហាន | ៥៣ | ២៣៣ |
| សរុប | **៤១៨** | **១.៧៥៣** |
| សរុបរួម | **៩៩០** | **៤.៥៦៥** |

*ប្រភព: ក្រសួងមហាផ្ទៃ (ខែមេសា ឆ្នាំ២០១៧)*

សម្រាប់ភូមិខ្នាវង្វាស (តាមដងផ្លូវលេខ៦៧) យើងពុំមានទិន្នន័យថ្មីៗអំពីចំនួនប្រជាពលរដ្ឋឡើយ ប៉ុន្តែយ៉ាងហោចណាស់ប្រជាពលរដ្ឋចំនួន ៧១៨គ្រួសារ បានមករស់នៅកាលពីខែមករា ឆ្នាំ២០១៣ (Wildlife Alliance, 2013)។ បច្ចុប្បន្ន ប្រជាពលរដ្ឋមានចំនួន ១.៦៩០គ្រួសារ កំពុងរស់នៅក្នុងឧទ្យានជាតិ។

អ្នករស់នៅម្តុំព្រះអង្គធំភាគច្រើនមានមុខរបរពាក់ព័ន្ធការផ្តល់ផលិតផល និងសេវាកម្មដល់ភ្ញៀវទេសចរ ក្រៅពីនោះជាកសិករតូចតាច ធ្វើស្រែនៅលើខ្នងភ្នំដោយពឹងលើទឹកភ្លៀង រួមទាំង ការដាំដំឡូងមី ដំឡូងជ្វា សណ្តែក និងដំណាំផ្សេងៗទៀត។ អ្នកស្រុកនៅតែបន្តធ្វើកសិកម្មបែបពនេចរ/ដំណាំផ្លាស់ (ចំការ) ដោយរានឆ្ការ និងដុតព្រៃយកដីដាំដំណាំរយៈពេលមួយឆ្នាំ បន្ទាប់មកបោះបង់ចោលដោយទុកឱ្យព្រៃដុះនៅលើដីនោះដុះឡើងវិញរយៈពេល ប្រមាណពី៥ទៅ១០ឆ្នាំ។ តាមធម្មតា ការរានឆ្ការនិងដុតព្រៃបានធ្វើឡើងលើចំណែកដី៥ឡូត៍ ដែលមានទំហំ ៣ហិកតា សម្រាប់ដំណាំពនេចរ។ ចាប់តាំងពីឆ្នាំ២០០៥ មកចំណែកដីភាគច្រើនដែលធ្លាប់បានប្រើប្រាស់សម្រាប់ដាំស្រូវ ត្រូវបានប្រែក្លាយជាចំការ អចិន្ត្រៃយ៍ ដោយការដាំស្វាយចន្ទី និងខ្លះទៀតសម្រាប់ដំណាំចេកផងដែរ។ ទម្លាប់ថ្មីក្នុងការដាំដំណាំបែបនេះ បានកើនមានឡើងនាបណ្តាឆ្នាំកន្លងទៅថ្មីៗ ដោយដីព្រៃឈើមួយចំណែកធំនៅលើខ្ពង់រាបខាងកើត ឥឡូវត្រូវបានប្រែក្លាយ

ជាចំការអចិន្ត្រៃយ៍ ដោយការដាំស្វាយចន្ទី។ បច្ចុប្បន្នយើងពុំមានទិន្នន័យជាក់លាក់អំពីទំហំដី (ឬម្ចាស់កម្មសិទ្ធិ) ដាំដំណាំទាំងនោះឡើយ។

ប្រជាពលរដ្ឋរស់នៅក្នុងភូមិនានានៃឧទ្យានជាតិនេះ បាននឹងកំពុងប្រតិបត្តិចំការពនេចរ និងចំការអចិន្ត្រៃយ៍ ដូចជាចំការស្វាយចន្ទី។ អង្គការសម្ព័ន្ធសត្វព្រៃបានប៉ាន់ស្មានថា ប្រជាពលរដ្ឋច្រើនជាង ១៥០ គ្រួសារ បានបំលាស់ទីមកពីតំបន់ក្រៅឧទ្យានជាតិចូលមកធ្វើកសិកម្ម ដូចបានបញ្ជាក់ជូនខាងលើនេះ។

បច្ចុប្បន្ន សហគមន៍តំបន់ការពារធម្មជាតិ មានចំនួន ៥ ដែលគ្រប់គ្រងលើផ្ទៃដីទំហំសរុបចំនួន ៩២៣ហិកតា (តំបន់នីមួយៗមានទំហំពី ៧៧ហិកតា ដល់៣០៦ហិកតា) នៅលើខ្ពង់រាបខាងកើត (តារាង ២) លើកលែងភូមិថ្មីជ្រួញ។ ទោះជាយ៉ាងណាភូមិពពែល ដែលជាភូមិថ្មី ក៏បានរៀបចំបង្កើតសហគមន៍តំបន់ការពារធម្មជាតិផងដែរ។ ទីតាំងទាំងនោះស្ថិតក្រោមការគ្រប់គ្រង និងការពារផ្ទាល់ដោយសហគមន៍មូលដ្ឋាន ដែលប្រមូលអនុផលព្រៃឈើ (NTFPs) ពីកន្លែងទាំងនោះតាមប្រពៃណីរបស់ខ្លួន។ សហគមន៍តំបន់ការពារធម្មជាតិទាំងនោះមានសារៈសំខាន់ណាស់សម្រាប់ជួយជម្រុញរបរចិញ្ចឹមជីវិតរបស់ប្រជាសហគមន៍មូលដ្ឋាន និងផ្តល់ទីកន្លែងសម្រាប់ការប្រមូលអនុផលព្រៃឈើ ដូចជា គូលែន (*Litchi chinensis)* ដែលជាផលិតផលចម្បង សម្រាប់លក់នៅក្នុងមូលដ្ឋាន និងជាប្រភពប្រាក់ចំណូល។ ដើមគូលែនត្រូវបានការពាររួមគ្នា ប៉ុន្តែផ្លែគូលែនត្រូវបានបេះ និងលក់តាមគ្រួសារនីមួយៗ។

*តារាង២. សហគមន៍តំបន់ការពារធម្មជាតិ នៅក្នុងឧទ្យានភ្នំគូលែន*

| ឈ្មោះសហគមន៍តំបន់ការពារធម្មជាតិ | ភូមិ | ចំនួនគ្រួសារពាក់ព័ន្ធ | ទំហំ (ហ.ត) |
|---|---|---|---|
| ១. ព្រៃភ្នំក្តួច | សង្កែឡាក់ | ៦៣ | ៧៧ |
| ២. ព្រៃភ្នំម្នាស់ | តាពេញ | ៩៩ | ៨២ |
| ៣. ព្រៃធំ | អន្លង់ធំ | ១៥៨ | ២៧០ |
| ៤. ព្រៃធំពពែល | ពពែល | ៥៩ | ១៨៨ |
| ៥. ជប់តាសុក | ខ្លាំឃ្មុំ | ៤៨ | ៣០៦ |
| | សរុប | **៤២៧** | **៩២៣** |

អង្គការ ADF បានធ្វើការជាមួយសហគមន៍មូលដ្ឋាន និងអាជ្ញាធរអប្សរា ដើម្បីបង្កើតតំបន់ការពារបុរាណស្ថាន លើផ្ទៃដីសរុបទំហំ ៨០០ហិកតា ដោយបានដាំបង្គោលព្រំប្រទល់ចំនួន ៤៦៩ដើម ព័ទ្ធជុំវិញទីតាំងបុរាណស្ថានមានចំនួន១១៩កន្លែង ***(ឧបសម្ព័ន្ធ១)***។ តំបន់ការពារបុរាណស្ថានក៏បានផ្តល់ជាទ្រនាប់នៅជុំវិញទីតាំងប្រវត្តិសាស្ត្រ ដោយជួយឱ្យព្រៃធម្មជាតិដុះលូតលាស់ឡើងវិញ និងជួយការពារទីតាំងនានាពីធាតុអាកាសមិនប្រក្រតី ការហូរច្រោះដី និងទម្លាប់កសិកម្មបែបបំផ្លាញ។ តំបន់ការពារបុរាណស្ថាន ត្រូវបានទទួលស្គាល់ជាផ្លូវការនៅខែឧសភា ឆ្នាំ២០១៥ ដោយក្រសួង បរិស្ថាន អាជ្ញាធរអប្សរា និងអាជ្ញាធរខេត្តសៀមរាប ព្រមទាំងស្ថិតក្រោមការល្បាតជាទៀងទាត់ដោយបុគ្គលិកអាជ្ញាធរអប្សរា។

## ២.៤. តួនាទីស្ថាប័ន និងអង្គភាព

ក្រសួងបរិស្ថានមានការទទួលខុសត្រូវរួមលើការគ្រប់គ្រងឧទ្យានជាតិភ្នំគូលែន តាមរយៈអង្គភាពជំនាញជាអ្នកអនុវត្តការងារ រួមមាន អគ្គនាយកដ្ឋានរដ្ឋបាលការពារអភិរក្សធម្មជាតិ និងអគ្គនាយកដ្ឋានសហគមន៍មូលដ្ឋាន ដែលទើបបង្កើតឡើងនាឆ្នាំ២០១៦។ នៅថ្នាក់ខេត្ត មន្ទីរបរិស្ថានខេត្ត ដែលមានមូលដ្ឋាននៅទីរួមខេត្តសៀមរាប ធ្វើការជាមួយអាជ្ញាធរមូលដ្ឋាន (ស្រុក/ឃុំ) ដើម្បីអនុវត្តសេចក្តីណែនាំ និងសកម្មភាពគ្រប់គ្រងដែលបានដាក់ចេញដោយក្រសួងបរិស្ថាន និងរដ្ឋបាលសាលាខេត្ត។ ជាផ្នែកមួយនៃកំណែទម្រង់វិមជ្ឈការនាពេលថ្មីៗនេះ អាជ្ញាធរថ្នាក់ក្រោមជាតិ បាននឹងកំពុងបង្កើនការទទួលខុសត្រូវលើផ្នែកមួយចំនួននៃការអនុវត្តកម្មវិធី បរិស្ថាន ដូចជា៖ ការគ្រប់គ្រងសំណល់ ការអភិរក្ស និងការប្រើប្រាស់តំបន់ការពារធម្មជាតិដោយនិរន្តរភាព ដោយបុគ្គលិកឧទ្យានជាតិត្រូវរាយការណ៍ផ្ទាល់មកមន្ទីរបរិស្ថាន។

អាជ្ញាធរអប្សរា ដែលជាអង្គភាពចំណុះឱ្យក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ទទួលបន្ទុកគ្រប់គ្រងទីតាំងបេតិកភណ្ឌពិភពលោកអង្គរ និងបុរាណស្ថាននានាក្នុងខេត្តសៀមរាប ដែលរួមទាំងទីតាំងនានាក្នុងឧទ្យានជាតិនេះផងដែរ។ សព្វថ្ងៃនេះ អាជ្ញាធរអប្សរាបានចាត់តាំងបុរាណវិទូ ៣រូប និងកម្មករ ៤៧នាក់ ឱ្យធ្វើការថែរក្សាបុរាណស្ថានក្នុងឧទ្យានជាតិនេះ។ រមណីយដ្ឋានក្បាលស្ពាន ដែលហៅផងដែរថា «ជ្រលងលឹង្គ ១.០០០» ស្ថិតក្រោមការគ្រប់គ្រងរបស់អាជ្ញាធរអប្សរា ហើយការចេញចូលតម្រូវឱ្យមានប័ណ្ណចូលទស្សនាអង្គរ។ ទីតាំងប្រហែលគ្នានេះមួយផ្សេងទៀត (ដែលហៅថា លឹង្គ ១.០០០) ស្ថិតនៅលើខ្នងរាបនៃភ្នំគូលែន។

រដ្ឋបាលព្រៃឈើនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ទទួលខុសត្រូវលើការគ្រប់គ្រងព្រៃឈើនៅក្រៅតំបន់ការពារធម្មជាតិ និងប្រតិបត្តិការកម្មវិធីដាំព្រៃឈើ និងថ្នាលបណ្តុះកូនឈើមួយចំនួន នៅក្នុងខេត្តសៀមរាប។ រដ្ឋបាលព្រៃឈើក៏ធ្លាប់គ្រប់គ្រងលើដីព្រៃឈើដែលស្ថិតនៅជាប់ផ្នែកពាយ័ព្យ នៃឧទ្យានជាតិនេះផងដែរ ហើយថ្មីៗនេះ ទីតាំងទាំងនោះត្រូវបានផ្ទេរមកឱ្យក្រសួងបរិស្ថានគ្រប់គ្រង ដែលជាផ្នែកមួយនៃកិច្ចផ្តួចផ្តើមបង្កើតរបៀងអភិរក្សជីវៈចម្រុះ ដែលបានអនុម័តដោយរាជរដ្ឋាភិបាលកម្ពុជា (អនុក្រឹត្យលេខ ០៧ ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០១៧)។ តំបន់នេះរួមបញ្ចូលទាំងសហគមន៍តំបន់ព្រៃឈើចង្រ្កានរយជាតំណសំខាន់ ដែលតភ្ជាប់ភ្នំគូលែន បង្កើតជាតំបន់ព្រៃឈើធំមួយ (៩.៥៤៤ ហិកតា) (Mould et al. ២០១៤)។

អង្គការ ADF ត្រូវបានរាជរដ្ឋាភិបាលកម្ពុជាទទួលស្គាល់ជាអង្គការមិនមែនរដ្ឋាភិបាល។ អង្គការនេះបានធ្វើការនៅក្នុងឧទ្យានជាតិភ្នំគូលែនតាំងពីឆ្នាំ២០០៨ ដោយមានទំនាក់ទំនងជិតស្និទ្ធជាមួយដៃគូមួយចំនួន ជាពិសេស អាជ្ញាធរអប្សរា នៅក្រោមអនុស្សរណៈនៃការយោគយល់មួយ។ បន្ថែមលើការបង្កើតតំបន់ការពារបុរាណស្ថាន និងការបន្តស្រាវជ្រាវខាងបុរាណវិទ្យា អង្គការ ADF ក៏មានគោលដៅពង្រឹងសហគមន៍មូលដ្ឋាន និងជួយកាត់បន្ថយភាពក្រីក្រផងដែរ ដោយផ្តោតលើប្រធានបទចំនួនបួន៖ សុខភាពអាហារូបត្ថម្ភ បង្កើនជម្រើសរបរចិញ្ចឹមជីវិត និងប្រាក់ចំណូលទូទៅ ការអប់រំ និងកិច្ចការពារបរិស្ថាន។

មជ្ឈមណ្ឌលអង្គការសម្រាប់ការអភិរក្សជីវៈចម្រុះ (ACCB) បានប្រតិបត្តិការមណ្ឌលបង្កាត់ពូជ និងសង្គ្រោះសត្វព្រៃ មានទីតាំងនៅក្បាលស្ពានចាប់តាំងពីឆ្នាំ២០០៣ នៅលើដី ដែលរដ្ឋបាលព្រៃឈើធ្លាប់បានប្រើសម្រាប់ជាថ្នាលបណ្តុះកូនឈើ។ មជ្ឈមណ្ឌល ACCB មានអនុស្សរណៈ (MoU) មួយជាមួយ

ក្រសួងបរិស្ថាន ដើម្បីផ្តល់សេវាសង្គ្រោះសត្វព្រៃ និងជួយបង្កើនការយល់ដឹងអំពីបរិស្ថាន និងការផ្តល់ព័ត៌មានអំពីបរិស្ថាន ដល់សាលារៀន និងភ្ញៀវទេសចរផងដែរ។ មជ្ឈមណ្ឌល ACCB បានផ្តល់វគ្គបណ្តុះបណ្តាលរយៈពេលខ្លីដល់មន្ត្រីឧទ្យានុរក្ស លើបច្ចេកទេសល្បាត ការប្រើប្រាស់ឧបករណ៍តាមដាន និងពិនិត្យទីតាំង និងរាយការណ៍ (SMART) និងជួយអភិរក្សសត្វព្រៃផងដែរ។

## ២.៥. ហេដ្ឋារចនាសម្ព័ន្ធឧទ្យានជាតិ និងទេសចរណ៍

ស្នាក់ការឧទ្យានជាតិ (ស្នាក់ការកណ្តាល) មានទីតាំងស្ថិតនៅជិតក្បាលស្ពាន តាមបណ្តោយផ្លូវជាតិលេខ៦៧ ដែលមានមន្ត្រីឧទ្យានុរក្សសរុបចំនួន ៤៨នាក់ កំពុងធ្វើការនៅតាមស្នាក់ការចំនួន ៧ ស្ថិតនៅឧទ្យានជាតិនិងខ្ពង់រាបភ្នំគូលែន។ ស្នាក់ការកណ្តាលពុំទាន់មានសេវាផ្តល់ព័ត៌មានអំពីធនធានធម្មជាតិ និងប៉ាណូ ឬស្លាកសញ្ញានៅតាមច្រកផ្លូវចូលឧទ្យានជាតិ សម្រាប់ឱ្យភ្ញៀវទេសចរបានដឹងថាពួកគេកំពុងចូលក្នុងឧទ្យានជាតិឡើយ។

នៅឆ្នាំ១៩៩៨ រាជរដ្ឋាភិបាលកម្ពុជាបានចុះហត្ថលេខាដើម្បីដាក់ផ្ទៃដីទំហំ ២.៤០០ហិកតា នៅម្តុំព្រះអង្គធំឱ្យស្ថិតនៅក្រោមការគ្រប់គ្រងនិងអភិវឌ្ឍដោយក្រុមហ៊ុននគរគោកធ្លក តាមការស្នើសុំពីមេបញ្ជាការយោធភូមិភាគ ៤។ ក្រុមហ៊ុននេះបានកសាងផ្លូវមួយខ្សែ តភ្ជាប់ឡើងដល់ខ្នងភ្នំ ដែលសម្រួលដល់រថយន្តទេសចរណ៍អាចទៅជិតទីតាំងទឹកធ្លាក់។ ដើម្បីជាការដោះដូរ ក្រុមហ៊ុននេះបានប្រមូលយកកម្រៃពីភ្ញៀវទេសចរបរទេស ក្នុង១នាក់២០ដុល្លាអាមេរិក សម្រាប់ការចូលទស្សនា។ យើងពុំឃើញមានរបាយការណ៍ផ្លូវការណាមួយ ដែលបញ្ជាក់អំពីចំនួនភ្ញៀវទេសចរចូលទស្សនាឧទ្យានជាតិនេះឡើយ។ នៅឆ្នាំ២០១២ ក្រុមហ៊ុននេះ បានរាយការណ៍ថា មានភ្ញៀវទេសចរចំនួន ៥០.០០០នាក់ ឆ្លងកាត់បញ្ជរយកប្រាក់ (ADF, pers. comm.)។ ភ្ញៀវទេសចរណ៍ចូលមកកម្សាន្តនៅរដូវប្រាំង (ពីខែវិច្ឆិកា ដល់ខែឧសភា) មានចំនួនជាមធ្យម ១៥០នាក់ក្នុងមួយថ្ងៃ ហើយមានអត្រាខ្ពស់ជាងនេះ នៅចុងសប្តាហ៍ និងថ្ងៃបុណ្យ (ពោលគឺរហូតដល់ ៥០០នាក់/ថ្ងៃ)។ ប្រាក់ចំណូលសរុបពីថ្លៃលក់សំបុត្រចូលលែងកម្សាន្តក្នុងឧទ្យានជាតិ ត្រូវបានប៉ាន់ប្រមាណក្រៅផ្លូវការថាមានចំនួនច្រើនជាង ២០០.០០០ដុល្លាអាមេរិក ក្នុងមួយឆ្នាំ។ ភោជនីយដ្ឋានមួយចំនួន និងតូបលក់អាហារ /សម្ភារៈនានាច្រើនមាននៅជុំវិញចំណតរថយន្តនៅជិតវត្តព្រះអង្គធំ និងជិតកន្លែងទឹកធ្លាក់។

ចំពោះកន្លែងដទៃទៀតនៃឧទ្យានជាតិភ្នំគូលែន ភ្ញៀវទេសចរច្រើនតែទៅទស្សនារមណីយដ្ឋានក្បាលស្ពាន ដែលមាន «ជ្រលងលីង្គ ១.០០០»។ នៅជាប់នឹងច្រកចូលរមណីយដ្ឋានក្បាលស្ពាន មានកន្លែងរក្សាទុកសត្វព្រៃមួយ កន្លែងនៅក្រោមការគ្រប់គ្រងរបស់អង្គការ ACCB។ នៅទីនោះ យើងឃើញមានសេវាផ្តល់ព័ត៌មានអំពីធនធានធម្មជាតិ ហើយភ្ញៀវទេសចរអាចបង់ប្រាក់តាមការស្ម័គ្រចិត្តជាវិភាគទាន។ លើសពីនេះ អង្គការ ACCB មានមណ្ឌលបណ្តុះ បណ្តាលតូចមួយ ដែលភ្ញៀវទេសចរ សិស្សសាលា និងក្រុមដទៃទៀត អាចទទួលបានព័ត៌មានបន្ថែមអំពីប្រភេទសត្វព្រៃក្នុងមណ្ឌលនេះ និងកម្មវិធីអភិរក្សដទៃទៀតរបស់ ACCB។

ក្រុមហ៊ុនទេសចរណ៍មួយចំនួនតូចផ្តល់សេវាអេកូទេសចរណ៍នៅក្នុងឧទ្យានជាតិនេះ មានដូចជាការដើរព្រៃ ការជិះកង់តាមភ្នំ និងការមើលសត្វព្រៃ។[2] អង្គការ ADF បានជួយបង្កើតផ្ទះស្នាក់នៅ ដែលបច្ចុប្បន្ន មានប្រជាជនចំនួន ៤គ្រួសារបានបង្កើតផ្ទះស្នាក់នៅក្នុងភូមិអន្លង់ធំ។



[2] *ឧទាហរណ៍មួយគឺច្រក Langur នៅភ្នំគូលែន ដែលវត់កាត់សហគមន៍តំបន់ការពារធម្មជាតិព្រៃធំពពេល – ទេសចរណ៍សង្កេតសត្វព្រៃជាមួយមគ្គុទេសក៍ ផ្តល់ដោយក្រុមហ៊ុន Indochinex Adventures (http://www.indochineex.com/phnom-kulen-langur-trail/)*



## ៣. បញ្ហាប្រឈមចំពោះការគ្រប់គ្រង

### ៣.១ ការរេចរឹល និងការបាត់បង់ព្រៃឈើ

របាយការណ៍ថ្មីៗបង្ហាញថា ភាគច្រើននៃការបាត់បង់ព្រៃឈើក្នុងឧទ្យានជាតិនេះ បានកើតមានឡើងនៅក្នុងអំឡុងទសវត្សរ៍មុនៗ ប៉ុន្តែប្រសិនបើស្ថានភាពរបៀបនេះចេះតែកើតមានជាបន្ត នុះព្រៃធម្មជាតិនៅក្នុងឧទ្យានជាតិនេះអាចប្រឈមនឹងការបាត់បង់នាពេលអនាគតខាងមុខនេះ។ បច្ចុប្បន្ន យើងឃើញសល់ព្រៃឈើធំពីរកន្លែងនៅក្នុងឧទ្យានជាតិនេះ នៅលើខ្ពង់រាបខាងលិច និងផ្នែកនានានៅលើខ្ពង់រាបជាប់គ្នាភាគខាងកើត។ ជ្រលងនៅភាគកណ្តាល ចន្លោះភ្នំគូលែន និងភ្នំហប់ ត្រូវបានបាត់បង់ព្រៃឈើទាំងស្រុងដោយការកាប់រាន **(ឧបសម្ព័ន្ធ១)**។ ដើម្បីការពារព្រៃដែលនៅសេសសល់លើភ្នំហប់ ត្រូវតែមានការចាត់វិធានការចាំបាច់ជាបន្ទាន់។

ការបាត់បង់ព្រៃឈើភាគច្រើននាពេលថ្មីៗនេះ បានបង្កឡើងដោយការធ្វើដំណាំកសិកម្ម និងកំណើនប្រជាពលរដ្ឋ ហើយកើតមានឡើងនៅក្នុងនិងជុំវិញឧទ្យានជាតិនេះ ដែលជាហេតុនាំឱ្យមានការទន្ទ្រានចូលក្នុងដីព្រៃ។ ដីពីមុនដែលធ្លាប់តែជាដីដាំស្រូវ និងចំការពនេចរ ត្រូវបានប្រែក្លាយជាចំការអចិន្ត្រៃយ៍ ដោយការដាំដំណាំស្វាយចន្ទី។ ចំការទាំងនោះត្រូវបានថែទាំ ដោយការកំចាត់ចោលរាល់រុក្ខជាតិផ្សេងៗទៀត ការប្រើប្រាស់ម៉ាស៊ីនកាត់ស្មៅ ដែលធ្វើឱ្យព្រៃឈើ ឬរុក្ខជាតិដទៃទៀត មានឱកាសតិចតួចណាស់ក្នុងការលូតលាស់ឡើងវិញតាមលក្ខណៈធម្មជាតិ នៅតាមទីតាំងទាំងនោះ។ ចំណែកឯអ្នកភូមិមួយចំនួនទៀត ក៏នៅតែបន្តធ្វើការកាប់ឆ្ការកន្លែងថ្មីៗទៀតសម្រាប់ធ្វើចម្ការពនេចរ។

ដូចនៅតាមកន្លែងជាច្រើននៃប្រទេសកម្ពុជាដែរ ភ្នំគូលែនក៏ទទួលរងការគំរាមកំហែងដោយសារការកាប់ឈើល្មើសច្បាប់។ ការគំរាមកំហែងមកលើដើមឈើធំៗ ដែលនៅសេសសល់ទាំងនោះ ច្រើនតែបណ្តាលមកពីតម្រូវការឈើប្រណិតនៅលើទីផ្សារអន្តរជាតិ និងទីផ្សារក្នុងស្រុក ដូចជាតម្រូវការគ្រឿងសង្ហារឹមក្នុងប្រទេស និងតម្រូវការសម្រាប់ឧស្សាហកម្មទេសចរណ៍ក្នុងខេត្តសៀមរាប។ សូម្បីតែនៅក្នុងឧទ្យានជាតិនេះក៏មានហាងលក់គ្រឿងសង្ហារឹមផងដែរ (នៅភូមិព្រះអង្គធំ)។ នៅឃុំឃុនរាម មានសិប្បកម្មឥដ្ឋចំនួន ១៣កន្លែង ស្ថិតតាមបណ្តោយផ្លូវជាតិលេខ៦៧ ជាប់ពីខាងក្រៅព្រំប្រទល់ឧទ្យានជាតិ ហើយគ្រួសារភាគច្រើនក្នុងតំបន់នោះ មានឡដុតធ្យូងនៅក្រោយផ្ទះ (Wildlife Alliance, 2013)។ តម្រូវការអុស និងធ្យូងមានកម្រិតខ្ពស់ដែលបង្កការគំរាមកំហែងជាបន្តមកលើព្រៃឈើក្នុងឧទ្យានជាតិ។ ទោះបីជាសហគមន៍ភាគច្រើននៅក្នុងស្រុកវ៉ារិន មានទីតាំងស្ថិតនៅក្រៅឧទ្យានជាតិនេះក៏ដោយ ប៉ុន្តែពួកគេក៏ពឹងផ្អែកលើធនធានព្រៃឈើពីឧទ្យានជាតិនេះផងដែរ។ ផ្អែកតាមការសម្ភាសន៍ជាមួយអ្នកភូមិដែលរស់នៅក្នុងឧទ្យានជាតិនេះ ភាគច្រើនបានប្រាប់ឱ្យដឹងថា ប្រជាពលរដ្ឋនៅក្រៅភូមិរបស់ពួកគាត់ គឺជាអ្នកដែលទាញយកផលអនុផលព្រៃឈើ (ភាគច្រើនជាឈើ និងអុស) មកពីឧទ្យានជាតិនេះ (Motzke et al., 2012)។

ការបាត់បង់គម្របព្រៃឈើនៅក្នុងឧទ្យានជាតិនេះ មានផលប៉ះពាល់អវិជ្ជមានមិនត្រឹមតែមកលើជីវៈចម្រុះ និងជម្រើសរបរចិញ្ចឹមជីវិតប៉ុណ្ណោះទេ (ដូចជាការប្រមូលអនុផលព្រៃឈើ) ប៉ុន្តែបានបង្កឱ្យមានការខ្វះខាតទឹកនៅរដូវប្រាំងសម្រាប់ខេត្តសៀមរាប ជាមួយនឹងកំណើនខ្លាំងនៃចំនួនភ្ញៀវទេសចរ។ ផលប៉ះពាល់ចំពោះនិយ័តភាពទឹកក្រោមដី បណ្តាលមកពីការបាត់បង់ព្រៃឈើនៅតំបន់ខ្សែទឹកខាងលើ អាចបង្កជាផលប៉ះពាល់មកលើសក្តានុពលនៃការអភិវឌ្ឍទៅអនាគតសម្រាប់ខេត្តសៀមរាប និងគំរាមកំហែងចំពោះគ្រឹះប្រាសាទនានាក្នុងតំបន់បេតិកភណ្ឌពិភពលោកអង្គរផងដែរ។ ដូច្នេះ កិច្ចការពារ និងការស្តារព្រៃឈើឡើងវិញជាសកម្មភាពអាទិភាពសម្រាប់កម្មវិធីគ្រប់គ្រងឧទ្យានជាតិភ្នំគូលែននេះ។

បរិមាណទឹកយ៉ាងច្រើនដែលមានប្រភពពីឧទ្យានជាតិភ្នំគូលែន កំពុងត្រូវបានប្រើប្រាស់កាន់តែច្រើនឡើងៗសម្រាប់ចំការដំណាំ ជាពិសេសចំការស្វាយចន្ទី ដែលមានកាន់តែច្រើននៅជុំវិញឧទ្យានជាតិ និងក្រុមហ៊ុនផលិតទឹកបរិសុទ្ធគូលែន ដែលមានរោងចក្រស្ថិតនៅជាប់ឧទ្យានជាតិនេះផងដែរ។

## ៣.២ កសិកម្ម

គ្រួសារនីមួយៗត្រូវការដីច្រើនកន្លែងដើម្បីធ្វើចម្ការពនេចរ ដោយការប្តូរវេន នៅពេលដីកន្លែងណាមួយបានបាត់បង់គុណភាព។ ការអនុវត្តបែបនេះអាចធ្វើទៅបានលុះត្រាតែនៅទីកន្លែងដែលមានព្រៃឈើធំៗ ស្ថិតនៅដាច់ស្រយាល ដែលមានដង់ស៊ីតេប្រជាជនទាប ប៉ុន្តែមិនអាចមាននិរន្តរភាពទេ ចំពោះទីកន្លែងដែលមានធនធានធម្មជាតិក្នុងកម្រិតកំណត់ និងមានចំនួនប្រជាជនកើនឡើងឆាប់រហ័ស ដូចជាឧទ្យានជាតិភ្នំគូលែនជាដើម (Hayes et al. 2013)។ ក្នុងអំឡុងទសវត្សរ៍កន្លងទៅ ការកែប្រែទម្លាប់ពីការដាំដំណាំប្រចាំឆ្នាំ និងពីរឆ្នាំម្តង (ដូចជា ស្រូវ ដំឡូងមី និងពោត) មកដាំស្វាយចន្ទី បានបង្ខំឱ្យអ្នកភូមិធ្វើការប្រែក្លាយដីព្រៃជាបន្ថែមទៀតសម្រាប់ធ្វើកសិកម្ម។ ការបង្វែរដីដែលមានដំណាំស្វាយចន្ទីមកធ្វើស្រែវិញ (ឬដាំស្តារព្រៃវិញ) គឺជាការលំបាក ដោយសារដីពុំសូវមានគុណភាព។ យោងរបាយការណ៍មួយបានបង្ហាញអំពីការប្រើប្រាស់ថ្នាំសម្លាប់ស្មៅនៅក្នុងចំការស្វាយចន្ទី ដែលបន្តបំផ្លាញរាល់រុក្ខជាតិទាំងឡាយដែលអាច

ដុះលូតលាស់ឡើងវិញ ព្រមទាំងអាចគំរាមកំហែងដល់គុណភាពទឹក ដែលមានកម្រិតកំណត់នៅក្នុងឧទ្យានជាតិនេះផងដែរ (ADF, pers. comm.)។

គេអាចចោទសួរថា តើចំការស្វាយចន្ទីនៅពេលថ្មីៗនេះពិតជាផ្តល់ផលចំណេញសម្រាប់បរចិញ្ចឹមជីវិតរបស់អ្នកភូមិនៅក្នុងឧទ្យានជាតិនេះដែរឬទេ? ការធ្វើចំការពនេចរ និងចំការបន្លែត្រូវការកម្លាំងពលកម្មច្រើន ចំណែកការធ្វើចំការស្វាយចន្ទីត្រូវការកម្លាំងតិច និងមានរយៈពេលឱ្យផលប្រមាណ៥ឆ្នាំ ប៉ុន្តែថ្លៃលក់ត្រូវបានកំណត់ដោយមានកម្រិតទាប (ប្រមាណ៤.០០០រៀល/គ.ក្រ) ធៀបនឹងថ្លៃជាមធ្យមលើទីផ្សារ។ ចំការស្វាយចន្ទីភាគច្រើនគឺជាកម្មសិទ្ធិរបស់វិនិយោគិននៅក្នុងខេត្តសៀមរាប ចំណែកអ្នកភូមិក្នុងមូលដ្ឋានបានត្រឹមតែធ្វើជាកម្មករប៉ុណ្ណោះ។ ផលិតផលត្រូវបានលក់ឱ្យឈ្មួញ កណ្តាល នៅក្នុងមូលដ្ឋាន ឬមកពីក្រៅភូមិ។

## ៣.៣ ការល្បាត និងការអនុវត្តច្បាប់

ទោះបីនៅឧទ្យានជាតិមានមន្ត្រីល្បាតនៃក្រសួងបរិស្ថាន ឆ្មាំរបស់អាជ្ញាធរអប្សរា នគរបាលការពារបេតិកភណ្ឌ និងនគរបាលមូលដ្ឋានហើយក៏ដោយ ក៏ការពង្រឹងការអនុវត្តច្បាប់ និងកិច្ចការពារ ការល្បាត និងការអនុវត្តច្បាប់ឱ្យមានប្រសិទ្ធភាពនៅតែខ្វះខាតនៅឡើយ ដូចមានភស្តុតាងតាមរយៈសកម្មភាពល្មើសច្បាប់ដែលនៅតែកើតមានជាបន្ត ក្នុងឧទ្យានជាតិនេះដូចជា៖ ការកាប់ឈើខុសច្បាប់ ការបរបាញ់សត្វ ការទន្ទ្រានកាប់រានយកដីព្រៃ និងការតាំងលំនៅស្ថានថ្មីៗជាដើម។ ការល្បាតប្រចាំថ្ងៃមិនបានចូលជ្រៅហួសបណ្តាញផ្លូវដឹកជញ្ជូនដែលមានស្រាប់ និងហួសឆ្ងាយពីភូមិនានាឡើយ ដោយបន្សល់ទុកកន្លែងជាច្រើននៅដាច់ស្រយាលក្នុងឧទ្យានជាតិ ដែលអាចជាកម្មវត្ថុនៃការកើតមានសកម្មភាពល្មើសច្បាប់។

ការអនុវត្តច្បាប់បច្ចុប្បន្ននេះត្រូវបានចាត់ទុកថាជាជម្រើសចុងក្រោយ ហើយមន្ត្រីល្បាត នៃក្រសួងបរិស្ថាន បានផ្តោតសកម្មភាពតែលើការបង្កើនការយល់ដឹងដល់ប្រជាពលរដ្ឋក្នុងសហគមន៍មូលដ្ឋាន។ ក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងទៅនេះ មានពាក្យបណ្តឹងចំនួន ៦ ត្រូវបានប្តឹងទៅតុលាការ ហើយសម្ភារៈល្មើសច្បាប់ខ្លះត្រូវបានរឹបអូស (ដែលរួមមាន អារុងថ្ងៃ១៨ដើម រណាយន្ត៦គ្រឿង និងទោចក្រយានយន្តចំនួន២គ្រឿងផងដែរ)។ បច្ចុប្បន្នមានការខ្វះខាតធនធានបម្រើឱ្យការល្បាត និងពង្រឹងការអនុវត្តច្បាប់ឱ្យមានប្រសិទ្ធភាព ជាអាទិ៍៖

- **ថវិកា៖** មន្ត្រី ១នាក់ អាចល្បាតត្រឹម៧ថ្ងៃ/ខែ ដែលមានន័យថា មន្ត្រីល្បាតត្រូវប្តូរវេនរៀងរាល់៧ថ្ងៃម្តង។ មន្ត្រីល្បាតទទួលប្រាក់ឧបត្ថម្ភ ១២.០០០រៀល/ថ្ងៃ (៣ដុល្លា/ថ្ងៃ) ក្នុងពេលចុះល្បាត ដើម្បីចំណាយលើប្រេង និងថ្លៃចំណាយដទៃទៀត
- **ហេដ្ឋារចនាសម្ព័ន្ធ៖** ប៉ុស្តិ៍យាមរងចំនួន ៧កន្លែង ត្រូវបានកសាង ដោយស្ថិតនៅរាយតាមកន្លែងនានាជុំវិញ ព្រំប្រទល់ឧទ្យានជាតិ (ក្នុងនោះប៉ុស្តិ៍យាមរងចំនួន៣ បច្ចុប្បន្នស្ថិតនៅក្នុងឧទ្យានជាតិ) គ្មានប៉ុស្តិ៍រងស្ថិតនៅតាមច្រកចូលឧទ្យានជាតិ នៅត្រង់បញ្ជរយកប្រាក់ ដែលក្រុមហ៊ុនឯកជនកំពុងប្រតិបត្តិការ ឬនៅតាមច្រកខាងកើតឡើយ

- **បរិក្ខារៈ** បុគ្គលិកឧទ្យានជាតិ (មន្ត្រីល្បាត ៤៨នាក់) មានរថយន្តចាស់មួយគ្រឿងប្រើប្រាស់រួមគ្នា ប៉ុន្តែពួកគេត្រូវប្រើប្រាស់ទោចក្រយានយន្តផ្ទាល់ខ្លួនសម្រាប់ល្បាត។ មន្ត្រីល្បាតប្រើប្រាស់អាវុធចាស់ៗដែលមានស្រាប់ជាប្រភេទអាវុធចាស់ហួសសម័យ (AK-47)។ បុគ្គលិកឧទ្យានជាតិមានឧបករណ៍ GPS ចំនួន ៣គ្រឿង ដែលបច្ចុប្បន្នខូចពុំដំណើរការ។ ទាំងបុគ្គលិកឧទ្យានជាតិនិងមន្ទីរបរិស្ថានគ្មានផែនទីថ្មីអំពីឧទ្យាននេះឡើយ។
- **ការទំនាក់ទំនងៈ** មន្ត្រីល្បាតទាំងអស់ប្រើប្រាស់ទូរស័ព្ទចល័តផ្ទាល់ខ្លួន ប៉ុន្តែពុំមានសេវាឡើយនៅក្នុងតំបន់ព្រៃជ្រៅនៃខ្ពង់រាបខាងលិច ឬផ្នែកខ្លះទៀតនៃខ្ពង់រាបខាងកើត។ គ្មានបរិក្ខារផ្សេងទៀតសម្រាប់ធ្វើការទំនាក់ទំនងឡើយសម្រាប់បុគ្គលិកឧទ្យានជាតិ
- **ខ្វះការកំណត់ព្រំប្រទល់ និងគោលការណ៍លើការប្រើប្រាស់ដីឱ្យបានច្បាស់លាស់ៈ** មានតែផ្នែកខ្លះៗនៃព្រំប្រទល់ខាងក្រៅនៃឧទ្យានជាតិនេះត្រូវបានបោះបង្គោលកំណត់ព្រំប្រទល់ ហើយក៏គ្មានការកំណត់និងការបែងចែកជាតំបន់គ្រប់គ្រងច្បាស់លាស់ ដើម្បីឱ្យដឹងថាតើសកម្មភាពណាដែលអាចអនុញ្ញាត ហើយនៅកន្លែងណាក្នុងឧទ្យាននេះឡើយ។ ស្ថានភាពនេះធ្វើឱ្យការអនុវត្តច្បាប់សម្រាប់មន្ត្រីល្បាតនៅក្នុងតំបន់ការពារធម្មជាតិនេះកាន់តែស្មុគស្មាញ។ ជាទូទៅមន្ត្រីល្បាតមានការអល់ឯកក្នុងការឃាត់ខ្លួនអ្នកកាប់ឈើល្មើសច្បាប់ឬ អ្នកបរបាញ់ ដោយសារតែកង្វល់ពីសុវត្ថិភាពផ្ទាល់ខ្លួន ព្រោះថា អ្នកទាំងនោះមានអាវុធ និងប្រតិបត្តិការនៅពេលយប់។

## ៣.៤ ការអភិវឌ្ឍទេសចរណ៍

ចំនួនភ្ញៀវទេសចរក្នុងឧទ្យាននេះបានកើនឡើងដោយគ្មានការកំហិត នៅថ្ងៃបុណ្យជាតិខ្លះអាចមានចំនួនភ្ញៀវច្រើនជាង ៥០០នាក់។ បញ្ហាអាចកើតមានឡើងដោយសារកត្តាមនុស្សច្រើនពេក ការចូលដោយគ្មានកម្រិតចំនួននៅក្នុងកន្លែងដែលងាយខូចខាត ការចោលសំរាម និងការបំពុលទឹក ដែលមិនត្រឹមតែប៉ះពាល់ដល់ភ្ញៀវទេសចរប៉ុណ្ណោះទេ ប៉ុន្តែធ្វើឱ្យហេដ្ឋារចនាសម្ព័ន្ធឧទ្យានជាតិនេះកាន់តែថយគុណភាពផងដែរ។

បច្ចុប្បន្ន ភាគច្រើននៃចំណូលដែលបានពីទេសចរណ៍ ជារបស់ក្រុមហ៊ុនទេសចរណ៍ឯកជន ដែលគ្រប់គ្រង និងយកកម្រៃ ២០ដុល្លារ ពីភ្ញៀវបរទេសម្នាក់សម្រាប់ការចូលក្នុងឧទ្យានជាតិ និងការចូលទៅកន្លែងទឹកធ្លាក់។ ក្រុមហ៊ុននេះក៏យកកម្រៃពីអ្នកលក់នៅជិតកន្លែងទឹកធ្លាក់ផងដែរ (ភោជនីយដ្ឋាន តូបលក់អាហារ សម្លៀកបំពាក់។ល។) និងបានយកកម្រៃប្រចាំខែសម្រាប់ផ្ទះនានាដែលសង់នៅក្នុងភូមិព្រះអង្គធំ។ ផលចំណូលត្រឹមតិចតួចប៉ុណ្ណោះ (ប្រសិនជាមាន) ត្រូវបានវិនិយោគលើការអភិរក្ស និងសកម្មភាពការពារឧទ្យានជាតិ (Bonheur et al., 2008)។ លើសពីនេះ ផលប្រយោជន៍បានពីទេសចរណ៍ មិនត្រូវបានបែងចែកដល់អ្នកភូមិចាស់ (ដូចជាភូមិអន្លង់ធំឡើយ ដែលពួកគេជួបការលំបាកក្នុងការនាំយកអាហារ និងសេវាមកទីផ្សារនៅព្រះអង្គធំ)។ ម៉្យាងវិញទៀត សហគមន៍មូលដ្ឋានត្រូវបង់ប្រាក់ ២០ដុល្លា/ខែ ទៅឱ្យក្រុមហ៊ុនឯកជន ដើម្បីអាចលក់ផលិតផលរបស់ខ្លួននៅទីតាំងដែលភ្ញៀវទេសចរមកកំសាន្ត។

នៅកន្លែងទឹកធ្លាក់ (ដែលរួមទាំង ចំណតរថយន្ត ភោជនីយដ្ឋាន និង កន្លែងលក់) មានសំរាម

កកស្ទះធ្វើឱ្យខូចខាតបរិស្ថានជាបណ្តើរៗរួមមាន៖ ការចោលសំរាម ការបំពុលទឹក និងសំឡេង។ រដ្ឋបាលខេត្តបានខិតខំផ្តួចផ្តើមឱ្យមានការសម្អាត និងដឹកចេញនូវសំណល់សំរាមចំនួន ៣តោន ពីកន្លែងនោះ។ សកម្មភាពនេះត្រូវតែធ្វើឱ្យបានទៀងទាត់។

ក្រុមហ៊ុន TripAdvisor បានដាក់ពិន្ទុឧទ្យានជាតិនេះក្នុងលំដាប់ទី៤៧ ក្នុងចំណោមកន្លែងដែលមានភាព ទាក់ទាញបំផុតចំនួន១៨៥ ក្នុងខេត្តសៀមរាប (ខែធ្នូ ឆ្នាំ២០១៦)។ ក្នុងចំណោមភ្ញៀវចំនួន ៤១៤នាក់ ដែលបានដាក់ពិន្ទុ ៨១% បានចាត់ទុកការកម្សាន្តរបស់ពួកគេថា «ល្អប្រសើរ/ល្អណាស់» ចំណែក ១១% ចាត់ទុកថា «គួរឱ្យខ្លាច/ខ្សោយ»។ ការដាក់ពិន្ទុ «ល្អ» បានកត់សម្គាល់ថា ឧទ្យានជាតិនេះផ្តល់ឱកាសសម្រាប់ការកម្សាន្តខុសគ្នា ពីអង្គរវត្ត មានជាអាទិ៍ ការដើរព្រៃ ការជិះកង់ និងការងូតទឹកនៅកន្លែងទឹកធ្លាក់។ ភាគច្រើននៃពិន្ទុ «ខ្សោយ» សំដៅលើភាពកកកុញនៃកន្លែង «លក់ដូរ» និងការចោលសំរាម ជាពិសេសនៅកន្លែងព្រះអង្គធំ។

អាជ្ញាធរខេត្ត ដែលរួមទាំងមន្ទីរបរិស្ថានខេត្ត មិនមានព័ត៌មានពិតប្រាកដស្តីពីចំនួនប្រតិបត្តិករទេសចរណ៍នៅឧទ្យានជាតិភ្នំគូលែនឡើយ។ នេះដោយសារប្រតិបត្តិករទេសចរណ៍ខ្លះ ធ្វើការជាមួយសហគមន៍មូលដ្ឋាន នគរបាលមូលដ្ឋាន ឬមន្ត្រីល្បាតនៅមូលដ្ឋានដោយផ្ទាល់ ដោយពុំបានជូនដំណឹងដល់អាជ្ញាធរខេត្តឡើយ។ ការសម្របសម្រួល និងចុះបញ្ជីប្រតិបត្តិករទេសចរណ៍ គឺជាការចាំបាច់ ដើម្បីធានាសុវត្ថិភាពភ្ញៀវទេសចរជាតិ និងអន្តរជាតិ ក៏ដូចជាធានាថា សកម្មភាពរបស់ពួកគេមានផលប៉ះពាល់ត្រឹមអប្បបរមាប៉ុណ្ណោះចំពោះធនធានធម្មជាតិ និងបេតិកភណ្ឌវប្បធម៌ក្នុងឧទ្យានជាតិភ្នំគូលែន ហើយអត្ថប្រយោជន៍នៃវិស័យទេសចរណ៍ត្រូវបានចែករំលែកជាមួយសហគមន៍មូលដ្ឋាន។

### ៣.៥. យុត្តាធិការត្រួតគ្នា

សមត្ថកិច្ចរួមលើការគ្រប់គ្រងឧទ្យានជាតិភ្នំគូលែន ស្ថិតក្រោមយុត្តាធិការរបស់ក្រសួងបរិស្ថាន ដែលមានអង្គភាពជំនាញជាអ្នកប្រតិបត្តិ រួមមាន៖ អគ្គនាយកដ្ឋានរដ្ឋបាលការពារនិងអភិរក្សធម្មជាតិ និងអគ្គនាយកដ្ឋានសហគមន៍មូលដ្ឋាន ដោយបានសហការជាមួយអាជ្ញាធរខេត្ត និងអាជ្ញាធរមូលដ្ឋាន។ អាជ្ញាធរអប្សរាមានតួនាទីការពារ និងគ្រប់គ្រងទីតាំងបេតិកភណ្ឌពិភពលោកអង្គរ និងប្រាសាទនៅជុំវិញ ក៏ដូចជាទីតាំងបុរាណស្ថាននានានៅក្នុងខេត្តសៀមរាប ដែលរួមទាំងបុរាណស្ថានដែលបានរកឃើញនៅក្នុងឧទ្យានជាតិនេះផងដែរ។ ទីបំផុត ក្រុមហ៊ុនឯកជន នគរគោកធ្លក បានទទួលកិច្ចសន្យាជួលនៅឆ្នាំ ១៩៩៨ សម្រាប់រយៈពេល ៣០ឆ្នាំ ដើម្បីអភិវឌ្ឍន៍លើផ្ទៃដីទំហំ ២.៤០០ហិកតា នៅជិតព្រះអង្គធំ សម្រាប់វិស័យទេសចរណ៍។ ក្រុមហ៊ុនឯកជនពុំមានទៀតទេបច្ចុប្បន្ន ប៉ុន្តែក្រុមហ៊ុនដដែលនេះ នៅតែបន្តប្រមូលយកប្រាក់កម្រៃពីភ្ញៀវទេសចរចូលមកកម្សាន្តក្នុងឧទ្យាននេះ ដោយហេតុថាការចរចារដើម្បីលុបកិច្ចព្រមព្រៀងជួល កំពុងធ្វើឡើងរវាងម្ចាស់ក្រុមហ៊ុន និងរាជរដ្ឋាភិបាល។

ប្រការសំខាន់គឺក្រសួងបរិស្ថាន និងអាជ្ញាធរអប្សរា ត្រូវគូសបញ្ជាក់ពីតួនាទី និងការទទួលខុសត្រូវរៀងៗខ្លួន នៅក្នុងការគ្រប់គ្រងឧទ្យានជាតិនេះទៅអនាគត ជាពិសេសវាទាក់ទងនឹងការអភិវឌ្ឍ និងការថែទាំសម្បទានទេសចរណ៍។ សេចក្តីសម្រេចថ្មីៗរបស់រដ្ឋាភិបាល ដែលបានដាក់បញ្ចូលអាជ្ញាធរអប្សរាឱ្យស្ថិតក្រោមក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ក៏ត្រូវតែលើកយកមកពិចារណាផងដែរ។ លើសពីនេះ រដ្ឋបាល

ព្រៃឈើមានតួនាទីសំខាន់ខាងបច្ចេកទេស នៅក្នុងការជួយគាំទ្រដល់កិច្ចប្រឹងប្រែងដាំព្រៃឡើងវិញនៅក្នុងឧទ្យានជាតិ និងការគ្រប់គ្រងតម្រូវការឈើ និងអុសនៅក្រៅព្រំប្រទល់ឧទ្យានជាតិនេះ។

## ៤. កម្មវិធីគ្រប់គ្រង

### ៤.១. ទស្សនៈវិស័យ បេសកកម្ម និងគោលដៅ

ការកំណត់ចាត់ជាឧទ្យានជាតិ រាជរដ្ឋាភិបាលកម្ពុជាបានធ្វើសេចក្ដីសម្រេចអំពីការប្រើប្រាស់ដីជាមួយនឹងគោលដៅបឋមនៃការគ្រប់គ្រងតំបន់បរិវេណឧទ្យានជាតិភ្នំគូលែន សម្រាប់ការអភិរក្សគុណតម្លៃខាងវិទ្យាសាស្ត្រ ការអប់រំ វប្បធម៌ និងការលំហែកម្សាន្ត។ ទស្សនៈវិស័យ បេសកកម្ម និងគោលដៅនានាដែលបានស្នើឡើង និងទទួលស្គាល់ពីសារៈសំខាន់នៃការគូសបញ្ជាក់អំពីអាណត្តិការងារព្រមទាំងកិច្ចសហការជាមួយសហគមន៍មូលដ្ឋាន នៅក្នុងការថែរក្សាគុណតម្លៃធនធានធម្មជាតិ និងបេតិកភណ្ឌវប្បធម៌សំខាន់ៗដែលមានក្នុងឧទ្យានជាតិភ្នំគូលែន សម្រាប់អនាគត គឺមានចែងដូចខាងក្រោម៖

**ទស្សនៈវិស័យ** ៖ គ្រប់គ្រងធម្មជាតិ និងបេតិកភណ្ឌវប្បធម៌ក្នុងឧទ្យានជាតិភ្នំគូលែនឱ្យមាននិរន្តរភាពក្រោមភាពជាដៃគូសកម្មជាមួយសហគមន៍មូលដ្ឋាន និងអ្នកពាក់ព័ន្ធដើម្បីជាប្រយោជន៍នៃប្រជាពលរដ្ឋកម្ពុជាជានិរន្តរ។

**បេសកកម្ម** ៖ ពង្រឹងតួនាទី និងសមត្ថភាពស្ថាប័ននៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ សម្រាប់ការអនុវត្តគោលនយោបាយ ច្បាប់ និងបទប្បញ្ញត្តិនានាឱ្យមានប្រសិទ្ធភាព ឱ្យមានសុក្រឹតភាពនៃការគ្រប់គ្រងធនធានធម្មជាតិ និងបេតិកភណ្ឌវប្បធម៌ក្នុងឧទ្យានជាតិភ្នំគូលែន។

**គោលដៅរួម** ៖ កាត់បន្ថយការបាត់បង់ និងការរេចរឹលព្រៃឈើ និងលើកកម្ពស់របរចិញ្ចឹមជីវិតសហគមន៍មូលដ្ឋាន ដែលនាំឱ្យបរិស្ថានមាននិរន្តរភាព និងសម្រេចបានការអភិរក្សធនធានធម្មជាតិ និងបេតិកភណ្ឌវប្បធម៌នៅក្នុងឧទ្យានជាតិភ្នំគូលែន។

### ៤.២. កម្មវិធីជាយុទ្ធសាស្ត្រ

ដើម្បីដោះស្រាយការគំរាមកំហែង និងការប្រឈមចំពោះឧទ្យានជាតិភ្នំគូលែន ឯកសារនេះត្រូវបានរៀបចំឡើងដោយមានការកំណត់កម្មវិធីចម្បងៗជាយុទ្ធសាស្ត្រ ចំនួនបួន ដូចតទៅ៖

- **កម្មវិធីទី១៖** ពង្រឹងកិច្ចការពារ និងការអភិរក្សធនធានធម្មជាតិ និងបេតិកភណ្ឌវប្បធម៌
- **កម្មវិធីទី២៖** ពង្រីកការចូលរួម និងអត្ថប្រយោជន៍របស់សហគមន៍
- **កម្មវិធីទី៣៖** ពង្រឹងសមត្ថភាពស្ថាប័ន និងកិច្ចសហការ និង
- **កម្មវិធីទី៤៖** ជានានិរន្តរភាពហិរញ្ញប្បទានសម្រាប់ឧទ្យានជាតិភ្នំគូលែន

ទំនាក់ទំនងរវាងការគំរាមកំហែង, យុទ្ធសាស្ត្រ និងសកម្មភាពដែលស្នើឡើង មានសង្ខេបដូចខាងក្រោម៖

| ការគំរាមកំហែង | កម្មវិធី | សកម្មភាពអាទិភាព |
|---|---|---|
| *កត្តាផ្ទាល់* | | |
| **ការបាត់បង់ និងរេចរឹលព្រៃឈើ** | ១, ២ | ➢ បង្កើយការដាក់បង្គោលព្រំប្រទល់ ការចុះបញ្ជីដីធ្លី និងការកំណត់ និងការបែងចែកតំបន់គ្រប់គ្រងក្នុងឧទ្យានជាតិឱ្យបានច្បាស់លាស់ ពិសេសទីតាំងតំបន់ស្នូលនិងតំបន់អភិរក្សសម្រាប់កិច្ចការពារ<br>➢ ជំរុញជម្រើសនៃការប្រើប្រាស់ដីដែលមាននិរន្តរភាពនិងតាមវិធីផ្សេង<br>➢ ផ្តួចផ្តើមសកម្មភាពដាំស្តារព្រៃឈើឡើងវិញ និងការពារលើដំណុះឈើឡើងវិញតាមធម្មជាតិ |
| **ការគំរាមកំហែងនិងការធ្វើឱ្យខូចខាតប្រាសាទបុរាណ និងបុរាណស្ថាន** | ១ | ➢ កំណត់ព្រំប្រទល់ការពារប្រាសាទបុរាណ និងកំណត់តំបន់ការពារបុរាណស្ថាន<br>➢ ស្រាវជ្រាវ និងធ្វើបញ្ជីសារពើភណ្ឌបុរាណស្ថាន<br>➢ រៀបចំផែនទីហានិភ័យ ដើម្បីឈានទៅធ្វើផែនការអភិរក្ស និងជួសជុល ប្រាសាទបុរាណ និងបុរាណស្ថាន |
| **ការកាប់ឈើ ការបរបាញ់ ការនេសាទ ឬការទន្ទ្រានចូលដោយល្មើសច្បាប់** | ១, ២ & ៣ | ➢ បង្កើនល្បឿននៃការបណ្តុះបណ្តាលលើការអនុវត្តច្បាប់សម្រាប់មន្ត្រីល្បាត និងអាជ្ញាធរមូលដ្ឋាន<br>➢ ផ្តល់ធនធានគ្រប់គ្រាន់សម្រាប់ការអនុវត្តច្បាប់ឱ្យមានប្រសិទ្ធភាព<br>➢ ពង្រឹងការចូលរួមរបស់សហគមន៍មូលដ្ឋានក្នុងការតាមដាន និង រាយការណ៍អំពីសកម្មភាពល្មើសច្បាប់ |
| *កត្តាប្រយោល* | | |
| **ការចូលរួមរបស់សហគមន៍ក្នុងកម្រិតកំណត់ក្នុងការគ្រប់គ្រងនិងតាមដានតំបន់ការពារធម្មជាតិ** | ២,៣ | ➢ ពង្រឹងសហគ្រប់គ្រង<br>➢ ពង្រីកការផ្សព្វផ្សាយដល់មូលដ្ឋាន និងយល់ដឹង<br>➢ គាំទ្រដល់ការកសាងសមត្ថភាពនិងការបណ្តុះបណ្តាលអាជ្ញាធរមូលដ្ឋាន និងសហគមន៍មូលដ្ឋានដើម្បីរ៉ាប់រងការទទួលខុសត្រូវច្រើនជាងមុនលើការគ្រប់គ្រងតំបន់ការពារធម្មជាតិ |
| **ឱកាសសម្រាប់របរចិញ្ចឹមជីវិតមានកំណត់** | ២ | ➢ ពង្រីកឱកាសក្នុងរបរចិញ្ចឹមជីវិតសម្រាប់សហគមន៍<br>➢ លើកកម្ពស់ការចែកផលពីប្រតិបត្តិការទេសចរណ៍ |
| **ការអភិវឌ្ឍទេសចរណ៍ដោយគ្មានការកំហិត** | ២ | ➢ បង្កើយការចរចាដើម្បីលប់ចោលសម្បទានទេសចរណ៍ឯកជន<br>➢ រៀបចំយុទ្ធសាស្ត្រគ្រប់គ្រងទេសចរណ៍ដោយសហការជាមួយអាជ្ញាធរអប្សរា និងក្រសួងទេសចរណ៍ |
| **កិច្ចសហការរវាងស្ថាប័នមានកម្រិតកំណត់** | ១, ២& ៣ | ➢ គូសបញ្ជាក់ពីតួនាទី និងពង្រីកកិច្ចសហការអន្តរស្ថាប័ន |
| **សមត្ថភាពនិងធនធានមានកម្រិតកំណត់** | ១, ២, ៣&៤ | ➢ វិនិយោគលើការបណ្តុះបណ្តាល និងបង្កើនគុណភាពបរិក្ខារ |
| **ខ្វះជម្រើសហិរញ្ញប្បទានដែលមាននិរន្តរភាព** | ៤ | ➢ ស្វែងយល់ពីជម្រើសសម្រាប់រកផលចំណូលផ្ទាល់ពីប្រតិបត្តិការទេសចរណ៍ ដើម្បីគ្រប់គ្រងឧទ្យានជាតិភ្នំគូលែន<br>➢ អនុវត្តសាកល្បងគុណតម្លៃសេដ្ឋកិច្ចនៃឧទ្យានជាតិភ្នំគូលែន (ដូចជា ការផ្តល់សេវាទឹកជម្រាលដល់ខេត្តសៀមរាប) |

## កម្មវិធីទី១៖ ពង្រឹងកិច្ចការពារនិងអភិរក្សធនធានធម្មជាតិ និងបេតិកភណ្ឌវប្បធម៌

ធនធានធម្មជាតិ និងបេតិកភណ្ឌវប្បធម៌ក្នុងឧទ្យានជាតិភ្នំគូលែន កំពុងស្ថិតក្រោមសម្ពាធគំរាមកំហែងកាន់តែច្រើនឡើងៗ ដោយសារការចូលទន្ទ្រានកាប់រានព្រៃ សកម្មភាពល្មើសច្បាប់ និងការអភិវឌ្ឍដែលគ្មាននិយ័តកម្ម។ ការពង្រឹងកិច្ចការពារជាអាទិភាពដំបូង ដើម្បីដោះស្រាយឱ្យបានឆាប់រហ័សនូវការគំរាមកំហែងទាំងនេះ និងការស្តារតម្លៃធនធានធម្មជាតិនៃឧទ្យានជាតិភ្នំគូលែនគឺជាគោលដៅចាំបាច់។ កម្មវិធីទី១ មាន ៥អនុកម្មវិធី ដូចខាងក្រោម៖

### អនុកម្មវិធី១.១ បង្កើតព្រំប្រទល់ឧទ្យានជាតិ និងតំបន់គ្រប់គ្រង

ដើម្បីកាត់បន្ថយការគំរាមកំហែងពីសកម្មភាពល្មើសច្បាប់នានា និងការទន្ទ្រានចូលកាន់កាប់ដីធ្លីប្រការចាំ បាច់គឺត្រូវកំណត់អត្តសញ្ញាណតំបន់ការពារធម្មជាតិឱ្យបានច្បាស់លាស់ និងកំណត់ព្រំប្រទល់ឧទ្យានជាតិ ជាមួយគ្នានោះត្រូវបញ្ជាក់ឱ្យដឹងអំពីទីកន្លែងណាដែលអាចអនុញ្ញាតឱ្យមានសកម្មភាព និងកន្លែងណាដែលមិនអនុញ្ញាត (ពោលគឺតាមរយៈការកំណត់ និងបែងចែកតំបន់គ្រប់គ្រង)។ បញ្ហាសកម្មភាពនឹងត្រូវអនុវត្តដោយមានការចូលរួមពីសហគមន៍មូលដ្ឋាន តាមលំដាប់នៃជំហានដែលទាក់ទងគ្នា ជាអាទិ៍៖

១. **ការបោះព្រំប្រទល់ឧទ្យានជាតិភ្នំគូលែន៖** ការបោះព្រំប្រទល់ព័ទ្ធជុំវិញឧទ្យានជាតិនេះនឹងត្រូវធ្វើឱ្យរួចរាល់ ហើយព្រំប្រទល់នឹងត្រូវចុះក្នុងបញ្ជីនៅក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។ បង្គោលព្រំត្រូវមានដាក់សញ្ញាសម្គាល់ ដោយប្រើប្រាស់បង្គោលបេតុងនៅត្រង់កន្លែងសមស្រប។ ស្លាកសញ្ញាឧទ្យានជាតិ ទាំងភាសាខ្មែរ និងអង់គ្លេសត្រូវដាក់នៅត្រង់ច្រកចូលឧទ្យានជាតិនេះ (ដែលរួមទាំង លើផ្លូវលេខ៦៧, ច្រកចូលនៅស្វាយលើ និងច្រកចូលឧទ្យាន ដែលបច្ចុប្បន្នជាបញ្ជរបង់ថ្លៃចូលកម្សាន្ត) ដើម្បីឱ្យប្រាកដថា អ្នកមូលដ្ឋាន និងភ្ញៀវទេសចរ បានដឹងថាពួកគេកំពុងដើរចូលក្នុងឧទ្យានជាតិ។

២. **ការកំណត់តំបន់៖** ការរៀបចំផែនទីប្រព័ន្ធអេកូឡូស៊ីចម្រុះ ត្រូវបានប្រើប្រាស់សម្រាប់កំណត់អត្តសញ្ញាណ ១.តម្លៃធនធានធម្មជាតិ និងវប្បធម៌ដែលមានស្រាប់ (រួមទាំង គម្របព្រៃឈើ និងបុរាណស្ថាន) និង ២.ការប្រើប្រាស់ដីក្នុងពេលបច្ចុប្បន្ន (ការតាំងទីលំនៅ ផ្លូវថ្នល់ កម្មសិទ្ធិដី ស្រែចំការ និងសម្បទាននានាក្នុងឧទ្យាន)។ ការងារកន្លងមក ត្រូវបានចាត់ទុកថាបានជួយកំណត់តំបន់គ្រប់គ្រង ដែលអាចដោះស្រាយការអភិរក្ស និងគោលដៅនៃការប្រើប្រាស់ឧទ្យានជាតិប្រកបដោយនិរន្តរភាព។

ផ្អែកតាមច្បាប់ស្តីពីតំបន់ការពារធម្មជាតិឆ្នាំ២០០៨ តំបន់នានាដូចមានរៀបរាប់ខាងក្រោមនេះនឹងត្រូវបានកំណត់ជាចម្បងសម្រាប់គ្រប់គ្រងនៅក្នុងឧទ្យានជាតិភ្នំគូលែន៖

ក. **តំបន់ស្នូល៖** កន្លែងគ្រប់គ្រងដែលមានតម្លៃខ្ពស់សម្រាប់ការអភិរក្ស ដែលគ្របដណ្តប់លើប្រភេទដែលរងការគំរាមកំហែង ជួបប្រទះគ្រោះថ្នាក់ និងជិតផុតពូជ ព្រមទាំងប្រព័ន្ធអេកូឡូស៊ីផុយស្រួយនានា។ ការចូលក្នុងតំបន់ស្នូលត្រូវហាមឃាត់ លើកលែងតែមន្ត្រីដែលបានទទួលការអនុញ្ញាតនិង អ្នកស្រាវជ្រាវដែលធ្វើការសិក្សាសម្រាប់គោលបំណងនៃការថែរក្សា

និងការពារធនធានជីវៈចម្រុះនិងវប្បធម៌ក្នុងឧទ្យានជាតិភ្នំគូលែន។ ជំពូកទាំងពីរចុងក្រោយនេះ ត្រូវមានការអនុញ្ញាតជាមុនពីក្រសួងបរិស្ថានទើបអាចចូលក្នុងតំបន់ស្នូលបាន។ ដោយសារតែគុណតម្លៃខាងជីវៈចម្រុះ និងទីជម្រាល ដែលផ្តល់ដោយព្រៃឈើក្នុងឧទ្យាននេះ និងអត្រាខ្ពស់នៃការបាត់បង់ព្រៃឈើនាបច្ចុប្បន្ន តំបន់ស្នូលរាប់បញ្ចូលតំបន់ព្រៃឈើដែលនៅសេសសល់ជាប់គ្នាលើខ្ពង់រាបខាងលិច និងលើខ្ពង់រាបខាងកើតដែលនៅជិតគ្នា។ កន្លែងទាំងនេះនឹងត្រូវហាមឃាត់ចំពោះការកាប់ព្រៃ និងការទន្ទ្រានចូលកាន់កាប់ណាមួយ និងស្ថិតក្រោមការល្បាតជាទៀងទាត់ដោយមន្ត្រីល្បាត និងមន្ត្រីពង្រឹងការអនុវត្តច្បាប់ដទៃទៀត។ ដោយគ្មានប្រភពទឹកអចិន្ត្រៃយ៍នៅក្នុងតំបន់ស្នូល ហេតុនេះមន្ត្រីល្បាតចាំបាច់ត្រូវនាំយកទឹកសម្រាប់ប្រើប្រាស់ផ្ទាល់ខ្លួននៅពេលល្បាត។

ខ. **តំបន់អភិរក្ស៖** ទីកន្លែងដែលមានតម្លៃខ្ពស់ខាងការអភិរក្ស មានជាអាទិ៍ ប្រព័ន្ធអេកូឡូស៊ីដែលងាយរងគ្រោះ ទីតាំងបេតិកភណ្ឌ និងទីជម្រាលនានា។ ការប្រើប្រាស់ឈើ អុស និងអនុផលព្រៃឈើជាទ្រង់ទ្រាយតូចសម្រាប់តម្រូវការក្នុងគ្រួសារ របស់អ្នកភូមិក្នុងសហគមន៍មូលដ្ឋានអាចអនុញ្ញាតទៅបាននៅក្រោមលក្ខខណ្ឌដែលកំណត់ដោយក្រសួងបរិស្ថានក្នុងករណី ដែលសកម្មភាពទាំងនោះមិនបង្កឱ្យមានការផលប៉ះពាល់ជាវិជ្ជមានធ្ងន់ធ្ងរលើការអភិរក្សជីវៈចម្រុះ និងគុណតម្លៃនៃប្រព័ន្ធអេកូឡូស៊ីនៅក្នុងតំបន់នោះ។ ក្នុងករណីសមស្រប ការស្តារព្រៃឈើឡើងវិញ ដោយមានការចូលរួមពីសហគមន៍មូលដ្ឋាននឹងត្រូវអនុវត្ត។ ការទន្ទ្រានចូលកាន់កាប់ និងការធ្វើកសិកម្ម នឹងមិនអាចអនុញ្ញាតឱ្យមានឡើយនៅក្នុងតំបន់នេះ។ តំបន់អភិរក្សមានជាអាទិ៍ ក) កន្លែងដែលនៅសេសសល់ ប៉ុន្តែនៅដាច់ដោយដុំៗ ព្រៃដែលស្ថិតនៅជាប់នឹងតំបន់ស្នូល ខ) ជម្រាលខាងក្រោមនៃឧទ្យានជាតិ ដើម្បីសម្រួលដល់ការស្តារព្រៃឈើឡើងវិញនិងទប់ស្កាត់ការរេចរឹល និងការហូរច្រោះបន្ថែមទៀត និង គ) សហគមន៍តំបន់ការពារធម្មជាតិ និងតំបន់ការពារបុរាណស្ថាន ត្រូវបានកំណត់ ដើម្បីទប់ស្កាត់ការទន្ទ្រានចូលបន្ថែមទៀត។

គ. **តំបន់សហគមន៍៖** ទីកន្លែងសម្រាប់ធ្វើការអភិវឌ្ឍសេដ្ឋកិច្ចសង្គមរបស់សហគមន៍មូលដ្ឋានដែលរួមមាន ដីលំនៅស្ថាន និងដីកសិកម្មដែលមានស្រាប់ នៅក្នុងតំបន់ជុំវិញភូមិ ការប្រមូលផលជាទ្រង់ទ្រាយតូច និងសកម្មភាពផលិតកម្ម (ដូចជា ថ្នាលបណ្តុះកូនឈើ និងការដាំប្រភេទអនុផលព្រៃឈើ) និងក្នុងករណីសមស្រប នឹងមានសកម្មភាពដាំស្តារព្រៃឈើឡើងវិញផងដែរ។ សកម្មភាពពាណិជ្ជកម្ម និងកសិ-អាជីវកម្មជាទ្រង់ទ្រាយធំនឹងមិនអនុញ្ញាតឡើយ។ កម្មសិទ្ធិដីសមូហភាព (មិនមែនបុគ្គល) នឹងត្រូវផ្តល់ជូនដល់ភូមិនានាដែលត្រូវបានចាត់ទុកថាជាផ្នែកមួយនៃតំបន់សហគមន៍ ដោយផ្តល់អាទិភាពដល់ភូមិចាស់ទាំង ៥ នៃឃុំខ្នងភ្នំ។ ការអនុវត្តតាមលក្ខណៈវិនិច្ឆ័យរបស់អង្គការ FAO ជាគោលការណ៍ណែនាំ គ្រួសារនីមួយៗ ត្រូវបានកំណត់ឱ្យប្រើប្រាស់ដីទំហំដី ៣ហិកតា សម្រាប់ធ្វើចម្ការពនេចរ នៅក្នុងតំបន់សហគមន៍សម្រាប់ភូមិនីមួយៗ។ នេះមានន័យថា តំបន់សហគមន៍ សម្រាប់ភូមិចាស់ទាំង ៥ នឹងរួម

បញ្ចូលទំហំផ្ទៃដី យ៉ាងហោចណាស់ ១.៧១៥ហិកតា សម្រាប់ការដាំដំណាំ (ដោយផ្អែកតាមស្ថិតិប្រជាជនចំនួន ៥៨៣គ្រួសារ)។ ចំការស្វាយចន្ទីដែលមានស្រាប់ នឹងមិនក្លាយជាផ្នែកមួយនៃតំបន់សហគមន៍ទេ ប៉ុន្តែក្នុងតំបន់ប្រើប្រាស់ដោយចីរភាព (អានខាងក្រោម)។ តំបន់សហគមន៍នៅក្នុងឧទ្យានជាតិនេះ មានដូចជា កន្លែងអភិវឌ្ឍន៍នៅជុំវិញភូមិចាស់លើខ្ពង់រាបខាងកើត និងជ្រលងភ្នំនៅភាគកណ្តាល រវាងខ្ពង់រាបខាងលិច និងខាងកើត (តាមផ្លូវលេខ២៦៧)។ ទីតាំងទាំងនេះមិនត្រូវបានអនុញ្ញាតឱ្យពង្រីកកសិដ្ឋាន ឬឡជ្បូងឡើយ។ អ្វីដែលត្រូវធ្វើគឺ ការរៀបចំទីតាំងលំនៅដ្ឋានថ្មី និងការប្តូរទីតាំងអាជីវកម្ម និងប្រជាពលរដ្ឋពីកណ្តាលជ្រលង ដែលត្រូវពិចារណា បន្ទាប់ពីមានការពិគ្រោះយោបល់ជាមួយសហគមន៍មូលដ្ឋាន។

**ឃ.តំបន់ប្រើប្រាស់ដោយចីរភាព៖** ទីកន្លែងដែលគាំទ្រដល់ការកែលម្អរបរចិញ្ចឹមជីវិតនៃសហគមន៍មូលដ្ឋាន និងរួមបញ្ចូលកន្លែងនានាដែលបច្ចុប្បន្នមានចំការដំណាំស្វាយចន្ទី និងចេកផងដែរ។ ចំការថ្មីមិនត្រូវអនុញ្ញាតឱ្យមានឡើយ ហើយចំការដែលមានស្រាប់គឺសម្រាប់តែសហគមន៍មូលដ្ឋានដែលរស់នៅទីនោះប៉ុណ្ណោះ ដែលត្រូវសុំលិខិតអនុញ្ញាតពីក្រសួងបរិស្ថាន។ ក្នុងករណីចាំបាច់ ត្រូវមានការដាំស្តារព្រៃឈើឡើងវិញ ដោយមានការចូលរួមពីសហគមន៍មូលដ្ឋាន ហើយត្រូវធ្វើឡើងដើម្បីបង្កើតជម្រើសផ្សេងទៀតសម្រាប់បង្កើនមុខរបរចិញ្ចឹមជីវិត ដោយការកែប្រែដីចំការដែលទុកចោល។ តំបន់នេះនឹងគ្របដណ្តប់ផ្នែកនានានៃដីដែលគ្មានព្រៃឈើនៅលើខ្ពង់រាបភាគខាងកើត។ តំបន់ប្រើប្រាស់ដោយចីរភាពនឹងត្រូវរាប់បញ្ចូលតំបន់ដែលបានកំណត់សម្រាប់ទេសចរណ៍ នៅតាមច្រកចូលព្រះអង្គធំ កន្លែងបញ្ចរយកប្រាក់ ភូមិថ្មីៗ ដែលបានបង្កើតឡើងនៅតាមច្រកចូល (តាវិរៈកាត់ និង តាហាន) និងច្រកទៅកាន់វិហារនានានៅតំបន់ក្បាលស្ពានផងដែរ។ អ្វីដែលអាចធ្វើបានគឺការរៀបចំការតាំងទីលំនៅឡើងវិញ និងការប្តូរទីតាំងអាជីវកម្ម និងប្រជាពលរដ្ឋពីច្រកទេសចរណ៍ទាំងនោះ បន្ទាប់ពីបានពិគ្រោះយោបល់ជាមួយសហគមន៍មូលដ្ឋាន។

សាលាខេត្តសៀមរាបបានកំណត់យកទីកន្លែងមួយ ដែលមានទំហំ ១៧៥ហិកតា ស្ថិតនៅក្រៅឧទ្យានជាតិ (បច្ចុប្បន្ននៅក្រោមការគ្រប់គ្រងរបស់ រដ្ឋបាលព្រៃឈើ) ដែលអាចប្រើប្រាស់សម្រាប់ការប្តូរទីលំនៅរបស់ប្រជាពលរដ្ឋចំនួន ៤១៥គ្រួសារ ពីភូមិថ្មីនានាស្ថិតនៅក្នុងឧទ្យានជាតិនេះ។ អាទិភាពដំបូងគ្រួសារទាំងឡាយដែលរស់នៅក្នុងភូមិព្រះអង្គធំ និងគ្រួសារដទៃទៀតដែលរស់នៅតាមដងផ្លូវទៅកាន់ទីតាំងព្រះអង្គធំ។ គ្រួសារដែលប្តូរទីតាំងអាចនឹងទទួលបាន ប័ណ្ណកម្មសិទ្ធិដី ផ្ទះសំបែង និងសេវានានាពីអាជ្ញាធរខេត្ត។ នៅមុនការផ្លាស់ប្តូរទីតាំង អាជ្ញាធរខេត្តត្រូវធានាថា មានសេវា និងហេដ្ឋារចនាសម្ព័ន្ធចាំបាច់គ្រប់គ្រាន់។ ការធ្វើជំរឿនប្រជាពលរដ្ឋគឺជាការចាំបាច់ ដើម្បីកំណត់អត្តសញ្ញាណឱ្យបានច្បាស់អំពីចំនួនមនុស្ស ទីតាំង និងរយៈពេលមកតាំងទីលំនៅរបស់គ្រួសារនីមួយៗ ដែលរស់នៅក្នុងឧទ្យានជាតិនេះ។ ការប្តូរទីតាំងបែបនេះត្រូវបានអនុវត្តរួចហើយជាគំរូ ដូចមានក្នុងតំបន់អប្សរា (រុនតាឯក) ដើម្បីប្តូរទីតាំងភូមិនានាចេញពីទីតាំង

បេតិកភណ្ឌពិភពលោកអង្គរ។ ឱកាសសម្រាប់ការប្តូរទីតាំងនៃគ្រួសារនានាបន្ថែមទៀតចេញពីឧទ្យានជាតិមកតំបន់នៃអាដ្ឋាធរជាតិអប្សរាក៏ត្រូវបានពិចារណាផងដែរ។

ផែនទី ដែលបានស្នើឡើងសម្រាប់តំបន់គ្រប់គ្រងមានបង្ហាញនៅក្នុង **ឧបសម្ព័ន្ធ២** ហើយតារាងសង្ខេបអំពីសកម្មភាពដែលអាចអនុញ្ញាតឱ្យបាននៅក្នុងតំបន់នីមួយៗនោះ ក៏មានបង្ហាញក្នុង **ឧបសម្ព័ន្ធ៣** ផងដែរ។ ព្រំប្រទល់តំបន់សហគមន៍ ដែលមានបង្ហាញក្នុងឧបសម្ព័ន្ធ២ គ្រាន់តែជាសន្ទស្សន៍ចង្អុលបង្ហាញប៉ុណ្ណោះ ដែលនឹងត្រូវរៀបចំឱ្យរួចរាល់ ដោយការពិគ្រោះយោបល់ជាមួយសហគមន៍មូលដ្ឋាន។ តំបន់គ្រប់គ្រងនីមួយៗនឹងត្រូវកំណត់ព្រំប្រទល់ ដោយផ្អែកលើស្ថានភាពព្រៃឈើ និងការពិគ្រោះយោបល់ជាមួយអាជ្ញាធរមូលដ្ឋាន និងភូមិនានា ដើម្បីធ្វើការផ្ទៀងផ្ទាត់ព្រំប្រទល់ ផ្អែកតាមចំណេះដឹងមូលដ្ឋាន និងការប្រើប្រាស់ដីក្នុងពេលបច្ចុប្បន្ន។

### អនុកម្មវិធី១.២. ការអភិរក្សព្រៃឈើ ការដាំស្តារព្រៃឈើឡើងវិញ និងការថែទាំ

ការអភិរក្ស ការដាំស្តារព្រៃឈើឡើងវិញ និងការថែរទាំ នឹងត្រូវពិចារណាសម្រាប់ការងារគ្រប់គ្រងជាអាទិភាពក្នុងឧទ្យានជាតិនេះ ដោយសារតែសេវាប្រព័ន្ធអេកូឡូស៊ីនៃព្រៃឈើដែលនៅសេសសល់ទាំងនោះសម្រាប់តួនាទីការពារទីជម្រកដែលមានសារៈសំខាន់ ការថែរក្សាជីវៈចម្រុះ និងការធ្វើពិពិធកម្មជម្រើសរបរចិញ្ចឹមជីវិតនៅមូលដ្ឋាន។ សកម្មភាពគ្រប់គ្រងនឹងផ្តោតលើតំបន់ស្នូល និងតំបន់អភិរក្ស និងរាប់បញ្ចូលនូវវិធានពីរបែបដើម្បី ក) កាត់បន្ថយការគំរាមកំហែងចំពោះព្រៃឈើដែលនៅសេសសល់ និង ខ) ស្តារគម្របព្រៃធម្មជាតិនៅកន្លែងរេចរឹល។

ការអភិរក្ស និងការពារធនធានទឹកសំខាន់ៗ ក៏នឹងត្រូវធ្វើឡើងផងដែរ នៅក្រោមអនុកម្មវិធីនេះ ដោយហាមឃាត់សកម្មភាពនានា ដូចជាការបំពុល បង្វែរ ឬគំរាមកំហែងចំពោះលំហូរទឹកស្អាតរបស់ធម្មជាតិ។ សកម្មភាពនេះនឹងរាប់បញ្ចូលបញ្ហាសំណល់រាវ(សូមអានផងដែរក្នុងកម្មវិធី២.៤) និងការបញ្ឈប់ទម្លាប់នៃការលាងរថយន្តតាមស្ទឹងនានាក្នុងឧទ្យាននេះ។

#### ***<u>កាត់បន្ថយការគំរាមកំហែង</u>***

ការអនុវត្តច្បាប់នឹងត្រូវពង្រឹង ដោយការតាមរក និងការបង្ក្រាបសកម្មភាពកាប់ឈើល្មើសច្បាប់ដែលកំពុងធ្វើនៅក្នុងតំបន់ស្នូល និងតំបន់អភិរក្ស (សូមអានកម្មវិធី១.៣)។ ការល្បាតនឹងធ្វើជាទៀងទាត់ដោយសហការជាមួយគណៈបញ្ជាការឯកភាពថ្នាក់មូលដ្ឋាន ក្នុងការអនុវត្តដើម្បីជួយកាត់បន្ថយការទន្ទ្រានចូលកាន់កាប់ក្នុងតំបន់ការពារធម្មជាតិ។ គ្មានការអនុញ្ញាតឱ្យធ្វើការរានឆ្ការដីព្រៃបន្ថែមទៀតឡើយ នៅក្នុងតំបន់ស្នូល និងតំបន់អភិរក្ស។ របៀបធ្វើកសិកម្មតាមប្រពៃណីនៅក្នុងតំបន់សហគមន៍ និងតំបន់ប្រើប្រាស់ដោយចីរភាពត្រូវពិនិត្យឡើងវិញ ដោយសហការជាមួយ សហគមន៍មូលដ្ឋាន ដើម្បីស្វែងយល់ពីជម្រើសមុខរបរដើម្បីបង្កើតទម្លាប់ដែលមាននិរន្តរភាព (សូមអានកម្មវិធី២.២)។ អន្តរាគមន៍ជាបន្ទាន់ដើម្បីបញ្ឈប់ការធ្វើឱ្យរេចរឹល និងការធ្វើឱ្យបាត់បង់ព្រៃឈើនៅតំបន់ភ្នំហប់។ លើសពីនេះ សហគមន៍មូលដ្ឋាននានាដែលស្ថិតក្នុងស្រុកវារិន ជាប់នឹងឧទ្យានជាតិនេះ គួរឱ្យមានការចូលរួមក្នុងសកម្មភាពជម្រើសមុខរបរចិញ្ចឹមជីវិតនេះផងដែរ ដើម្បីកាត់បន្ថយសម្ពាធមកលើព្រៃឈើដែលនៅសេសសល់លើខ្ពស់រាបខាងលិច។

## *ការដាំស្តារព្រៃឈើឡើងវិញនិងការថែទាំ*

ការស្តារព្រៃឈើឡើងវិញត្រូវអនុវត្តដោយៈ ក) ការលើកទឹកចិត្តឱ្យមានដំណុះឡើងវិញតាមធម្មជាតិនៅតាមកន្លែងជាប់នឹងព្រៃធម្មជាតិ និង ខ) អនុវត្តបច្ចេកទេសសុវ្ឌ្ឍិកម្មព្រៃឈើ ដោយប្រើប្រាស់ប្រភេទពូជឈើក្នុងស្រុក ពីថ្នាលបណ្តុះកូនឈើដែលបានបង្កើតឡើងសម្រាប់ឧទ្យានជាតិនេះ។ កន្លែងអាទិភាពនានាសម្រាប់ការដាំស្តារព្រៃឈើឡើងវិញមានជាអាទិ៍ៈ

- កន្លែងព្រៃរេចរឹលនៅក្នុងតំបន់ស្នូល និងតំបន់អភិរក្ស (ជាពិសេស នៅតាមជម្រាលភាគខាងក្រោមឧទ្យាន)
- កន្លែងព្រៃរេចរឹលក្នុងសហគមន៍តំបន់ការពារធម្មជាតិនិងតំបន់ការពារបុរាណស្ថាន [3] ស្ថិតក្នុងតំបន់ស្នូល
- កន្លែងព្រៃរេចរឹលក្នុងតំបន់សហគមន៍ ដែលអាចដើរតួជារបៀងសត្វព្រៃ រវាងព្រៃឈើដែលតភ្ជាប់គ្នា (ដូចជា រវាងខ្ពង់រាបខាងលិច និងខាងកើត រវាងភ្នំហប់ និងខ្ពង់រាបខាងកើត)
- កន្លែងនានាដែលនៅមានលក្ខខណ្ឌល្អ ដូចជា ក្បាលស្ពាន ភ្នំស្រួច និងភ្នំហប់ ដែលការដាំស្តារព្រៃឈើឡើងវិញ អាចផ្តល់ផលឆាប់រហ័ស និង
- កន្លែងនានាដែលនៅសេសសល់ព្រៃល្បោះឪបតេរ៉ូកាប (ដូចជា តំបន់ទន្សាយផ្អើល) ដែលអាចកំណត់ជា "តំបន់អភិរក្សប្រភពហ្សែន" ការទប់ស្កាត់ការទន្ទ្រានចូលកាន់កាប់បន្ថែមទៀតក្នុងកន្លែងទាំងនោះ។

ការដាំស្តារព្រៃឈើនឹងត្រូវបន្តដោយសកម្មភាពថែទាំដោយការប្រុងប្រយ័ត្ន និងត្រូវមានការចូលរួមវាយតម្លៃនិងត្រួតពិនិត្យលើតំបន់ដាំស្តារដោយសហគមន៍មូលដ្ឋាន ដើម្បីធានាឱ្យកូនឈើរស់រានមានជីវិត។

### អនុកម្មវិធី១.៣. លើកកម្ពស់ការអនុវត្តច្បាប់

ការវិនិយោគថ្មីៗនឹងត្រូវធ្វើឡើង សម្រាប់កិច្ចការពារធនធានក្នុងឧទ្យានជាតិ ព្រមទាំងមានការពង្រឹងការអនុវត្តច្បាប់ដែលពាក់ព័ន្ធ។ មន្ត្រីល្បាតក្រោមកិច្ចសហការជាមួយអាជ្ញាធរមូលដ្ឋាននិងសហគមន៍ ត្រូវទទួលការបណ្តុះបណ្តាល និងបំពាក់ឧបករណ៍ចាំបាច់ ដើម្បីកិច្ចប្រតិបត្តិការឱ្យមានប្រសិទ្ធភាពនៅតាមមូលដ្ឋាន។ កំណែលម្អបន្ថែមទៀតនឹងត្រូវធ្វើឡើងលើផ្នែកនានាដូចតទៅៈ

- ការរៀបចំវគ្គបណ្តុះបណ្តាលឯកទេសលើការអនុវត្តច្បាប់ ដល់មន្ត្រីល្បាត ដោយសហការជាមួយគណៈបញ្ជាការឯកភាពថ្នាក់មូលដ្ឋាន
- ការដាក់ពង្រាយក្រុមអ្នកអនុវត្តច្បាប់ចល័ត និងរហ័ស (រួមទាំងតំណាងមកពីអង្គភាពរដ្ឋបាលផ្សេងៗ) នឹងត្រូវរៀបចំឡើង ដើម្បីចុះល្បាតនៅតាមតំបន់ស្នូល និងតំបន់អភិរក្ស។ កិច្ចការនេះនឹងរួមបញ្ចូលការតាមដានយ៉ាងជិតដល់តាមច្រកចេញចូល ដែលត្រូវបានគេប្រើប្រាស់ច្រើន សម្រាប់ដឹកជញ្ជូនឈើចេញពីខ្ពង់រាបខាងលិចនាបច្ចុប្បន្ន

---

[3] *ឧទាហរណ៍ អង្គការ ADF បានចាប់ផ្តើមគម្រោងស្តារព្រៃឈើឡើងវិញ នៅក្នុងសហគមន៍APA ប្រាសាទអ្នកតា និងបានដាំដើមឈើ ៥.000 ដើម នៅក្នុងកសិដ្ឋានស្វាយចន្ទីចំនួន ១១កន្លែង ទន្ទឹមនឹងជម្រុញរបរជំនួសផងដែរ (ភាគច្រើនចិញ្ចឹមមាន់)។*

- បរិក្ខារទំនើបបំរើឱ្យការអនុវត្តច្បាប់នឹងត្រូវធ្វើលទ្ធកម្ម ដោយមានយ៉ាងហោចណាស់រថយន្ត 4WD មួយគ្រឿង និងទោចក្រយានយន្តសម្រាប់ចូលព្រៃចំនួន ១០គ្រឿង វិទ្យុទាក់ទង ឧបករណ៍ GPS និងម៉ាស៊ីនថតឌីជីតាល់ផងដែរ។ ម៉ាស៊ីនថតពីចម្ងាយ (ដែលប្រើប្រាស់ប្រព័ន្ធ GSM ឬគំរូដែលគ្មានខ្សែសម្រាប់ចម្លងទិន្នន័យ) នឹងត្រូវប្រើប្រាស់ដើម្បីតាមដានផ្លូវ និងច្រកចូលកាប់ឈើ
- ត្រូវផ្តល់ការលើកទឹកចិត្ត និងរង្វាន់ សម្រាប់ការចាប់ខ្លួន និងការរឹបអូសវត្ថុតាងបទល្មើស ដែលទាក់ទងនឹងសកម្មភាពល្មើសច្បាប់
- បង្គោលព្រំប្រទល់ និងប៉ាណូនឹងត្រូវដាក់នៅតាមកន្លែងនានាលើដងផ្លូវ និងច្រកចូល ដើម្បីបញ្ជាក់ពីទីកន្លែងក្នុងឧទ្យានជាតិ (បង្គោលព្រំប្រទល់) និងតំបន់ស្នូល/តំបន់អភិរក្ស (ប៉ាណូ)
- សកម្មភាពបង្កើនការយល់ដឹងអំពីការអនុវត្តច្បាប់នឹងត្រូវធ្វើក្នុងសហគមន៍មូលដ្ឋាន ដើម្បីអនុវត្តគោលដៅនានានៃការគ្រប់គ្រង និងសកម្មភាពអាទិភាពដែលទាក់ទងនឹងឧទ្យានជាតិនេះ
- ត្រូវពិចារណាអំពីកិច្ចសហការរវាងក្រសួង និងអាជ្ញាធរមូលដ្ឋានក្នុងការដកហូតរណាយន្តទាំងអស់ និងអាវុធកែច្នៃគ្រប់ប្រភេទ ដែលបច្ចុប្បន្នកំពុងមានការប្រើប្រាស់ក្នុងឧទ្យានជាតិនេះ លើកលែងតែបានទទួលការអនុញ្ញាតជាមុន ពីសមត្ថកិច្ចពាក់ព័ន្ធ។

ត្រូវវាយតម្លៃលើសកម្មភាពកាត់បន្ថយការគំរាមកំហែង ដោយការបង្កើតឱកាសសម្រាប់បង្កើតមុខរបរចិញ្ចឹមជីវិតប្រកបដោយនិរន្តរភាពសម្រាប់សហគមន៍មូលដ្ឋាន។ ការល្បាតដោយស្ម័គ្រចិត្តដោយសហគមន៍មូលដ្ឋាននឹងទទួលបានការលើកទឹកចិត្ត និងគាំទ្រជាថវិកាកម្រិតអប្បរមា។ របាយការណ៍ពីក្រុមអ្នកល្បាតទាំងនោះនឹងត្រូវដាក់បញ្ចូលទៅក្នុងប្រព័ន្ធគ្រប់គ្រង ដែលមន្ត្រីល្បាតបានប្រើប្រាស់សម្រាប់គោលដៅពង្រឹងការអនុវត្តច្បាប់។

### អនុកម្មវិធី១.៤. លើកកម្ពស់ការអភិរក្សសត្វព្រៃ

ការសិក្សាស្រាវជ្រាវជីវៈចម្រុះនៅក្នុងឧទ្យានជាតិនេះនឹងទទួលបានការលើកទឹកចិត្ត ហើយការប្រមូលចងក្រងជាឯកសារកាន់តែប្រសើរថែមទៀត ដែលនិយាយអំពីរបាយនិងភាពសំបូរនៃប្រភេទសត្វដោយផ្តោតលើប្រភេទសត្វព្រៃដែលងាយរងគ្រោះថ្នាក់ (សូមអានជំពូក៥ ផងដែរ)។ ការបរបាញ់ល្មើសច្បាប់ ជាពិសេស ការលក់សត្វព្រៃនៅក្នុងឧទ្យានជាតិនេះនឹងត្រូវលុបបំបាត់ តាមរយៈការអនុវត្តច្បាប់ឱ្យបានត្រឹមត្រូវ។

ការដាក់បញ្ចូលមកវិញនូវប្រភេទសត្វព្រៃដែលមានដើមកំណើតក្នុងឧទ្យានជាតិនេះ ក៏នឹងត្រូវសិក្សាស្វែងយល់ផងដែរ ដោយសហការជាមួយមជ្ឈមណ្ឌលអង្គរសម្រាប់ការអភិរក្សជីវៈចម្រុះ (ACCB)។

### អនុកម្មវិធី១.៥. ការពារទីតាំងបុរាណស្ថាន

ការថែរក្សា ការការពារ និងការអភិរក្សបេតិកភណ្ឌវប្បធម៌ជាគោលដៅសំខាន់មួយត្រូវកំណត់ឱ្យមានក្នុង កម្មវិធីគ្រប់គ្រងឧទ្យានជាតិ ព្រះជ័យវរ្ម័ន-នរោត្តម «ភ្នំគូលែន»។ ការងារខាងលើនេះផ្តោតសំខាន់លើៈ ការសិក្សាស្រាវជ្រាវនិងការធ្វើបញ្ជីសារពើភ័ណ្ឌប្រាសាទបុរាណនិងបុរាណស្ថាន ការរៀបចំនិងបោះ

បង្គោលកំណត់បរិវេណការពារប្រាសាទបុរាណនិងបុរាណស្ថាន ការរៀបចំ និងបោះបង្គោលកំណត់តំបន់ការពារបុរាណស្ថាន (APA) និងការរៀបចំបង្កើតផែនទីហានីភ័យ ដែលកំណត់យកប្រាសាទបុរាណកំពុងរងគ្រោះទាំងឡាយណា ដើម្បីធ្វើជាអាទិភាពសម្រាប់ឈានទៅរៀបចំផែនការគាំពារនិងជួសជុលបន្ទាន់។ ការងារខាងលើនេះត្រូវធ្វើឡើងដោយមានកិច្ចសហការជាមួយក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ដែលមានអាជ្ញាធរអប្សរាជាសេនាធិការ និងសហការជាមួយអង្គការពាក់ព័ន្ធ ដែលអនុវត្តការងារស្រាវជ្រាវខាងបុរាណវិទ្យាក្នុងឧទ្យានជាតិនេះ។

### កម្មវិធីទី២៖ ពង្រីកការចូលរួម និងផលប្រយោជន៍របស់សហគមន៍

ការចូលរួមជាសកម្មរបស់សហគមន៍មូលដ្ឋានមានសារៈសំខាន់ជាសារវន្តនៅក្នុង កិច្ចការពារ និងការអភិវឌ្ឍឧទ្យានជាតិនេះ។ ទន្ទឹមនឹងនេះ មិនត្រូវបន្តឱ្យកើតមានអ្នកចំណូលស្រុកយ៉ាងច្រើនមកតាំងទីលំនៅក្នុងឧទ្យានជាតិនេះឡើយ ដែលនាំឱ្យមានការទន្ទ្រានចូលកាន់កាប់ដី និងការបាត់បង់ព្រៃឈើបន្ថែមទៀត ដោយសារវាគំរាមកំហែងមិនត្រឹមតែមកលើសមត្ថភាពរបស់ឧទ្យានជាតិ ដែលមានតួនាទីជាអាងទឹកសម្រាប់ខេត្តសៀមរាបប៉ុណ្ណោះទេ ប៉ុន្តែមកលើមុខរបរចិញ្ចឹមជីវិតរបស់អ្នកភូមិចាស់ស្ថិតក្នុងឧទ្យានជាតិនេះផងដែរ។ ដូច្នេះ តម្រូវការជាបន្ទាន់គឺការបញ្ឈប់ប្រជាជនចំណូលស្រុកបន្ថែមទៀត និងពិចារណាអំពីការប្តូរទីតាំងលំនៅស្ថានសម្រាប់អ្នកមកតាំងទីលំនៅថ្មីៗ ទៅកន្លែងនានាខាងក្រៅឧទ្យានជាតិ។ កម្មវិធីទី២ មាន ៤អនុកម្មវិធីដូចខាងក្រោម៖

#### អនុកម្មវិធី២.១ ចាត់ជាអាទិភាពនូវការចូលរួមរបស់អ្នកមូលដ្ឋាននៅក្នុងការគ្រប់គ្រងឧទ្យានជាតិ

ជាផ្នែកមួយនៃកំណែទម្រង់វិមជ្ឈការថ្នាក់ក្រោមជាតិនាពេលថ្មីៗនេះ មន្ទីរបរិស្ថានខេត្ត និងការិយាល័យថ្នាក់ស្រុករបស់ខ្លួន មានភារៈកិច្ចទទួលខុសត្រូវលើការគ្រប់គ្រងឧទ្យានជាតិ (រួមទាំង ការបង្កើនការយល់ដឹង ការអភិវឌ្ឍមុខរបរចិញ្ចឹមជីវិត និងពង្រឹងការអនុវត្តច្បាប់) ទន្ទឹមនឹងនេះ ក្រុមប្រឹក្សាឃុំមានភារៈកិច្ចទទួលខុសត្រូវលើសហគមន៍ពាក់ព័ន្ធ និងអនុវត្តផែនការវិនិយោគឃុំ។

អាទិភាពសម្រាប់ការចូលរួម និងការគាំទ្រសហគមន៍ ត្រូវផ្តល់ជូនភូមិចាស់ចំនួន៥ នៅក្នុងឃុំខ្នងភ្នំ រួមមាន៖ ភូមិអន្លង់ធំ ភូមិតាពេញ ភូមិសង្កែឡាក់ ភូមិខ្លាឃ្មុំ និងភូមិថ្មជ្រួញ ដែលជាអ្នកគ្រប់គ្រងសហគមន៍តំបន់ការពារធម្មជាតិ។ អ្នកដទៃទៀតនៅក្នុងភូមិ៤ ផ្សេងទៀត ដែលបានបង្កើតឡើងក្នុងរយៈពេល១៥ ឆ្នាំមុននេះ (ពពេល ព្រះអង្គធំ ភូមិថ្មី និងតាហាន) នឹងត្រូវផ្តល់ឱកាសឱ្យតាំងទីលំនៅឡើងវិញនៅខាងក្រៅឧទ្យានជាតិនេះ។

ការរៀបចំផែនការតាមបែបចូលរួមនឹងត្រូវធ្វើឡើងជាមួយក្រុមប្រឹក្សាឃុំ និងភូមិគោលដៅនានា ដើម្បី៖

- កែលម្អព្រំប្រទល់នៃតំបន់គ្រប់គ្រងដែលបានស្នើឡើង ដោយផ្តោតលើតំបន់សហគមន៍
- បង្កើនការយល់ដឹងអំពីច្បាប់ និងបទប្បញ្ញត្តិនានាដែលចែងអំពីសិទ្ធិ/ការទទួលខុសត្រូវដែលពាក់ព័ន្ធនឹង ការប្រើប្រាស់ធនធានធម្មជាតិតាមប្រពៃណី

- ស្វែងរកឱកាសសម្រាប់ការល្បាតរួមគ្នាជាមួយមន្ត្រីល្បាត ការចូលរួមនៅក្នុងសកម្មភាពស្តារព្រៃឈើឡើងវិញ និងការអភិវឌ្ឍទេសចរណ៍។

ការបន្តគាំទ្រដល់សហគមន៍តំបន់ការពារធម្មជាតិដែលមានស្រាប់ មានជាអាទិ៍ ជំនួយក្នុងការរៀបចំផែនការសកម្មភាពងាយៗសម្រាប់គ្រប់គ្រងសហគមន៍តំបន់ការពារធម្មជាតិ និងការធ្វើសមាហរណកម្មផែនការទាំងនោះទៅក្នុងផែនការវិនិយោគឃុំ ជាមធ្យោបាយក្នុងការធានាឱ្យមានការគាំទ្រទាំងនយោបាយ និងហិរញ្ញវត្ថុសម្រាប់ពង្រឹងការចូលរួមរបស់សហគមន៍មូលដ្ឋាននៅក្នុងដំណើរការរៀបចំផែនការគ្រប់គ្រង។

គណៈកម្មការគ្រប់គ្រងឧទ្យានជាតិមួយ នៅមូលដ្ឋាននឹងត្រូវបង្កើតឡើង ដោយមានតំណាងមកពីអង្គភាពគ្រប់គ្រងឧទ្យានជាតិ (រួមទាំង មន្ត្រីល្បាត) ក្រុមប្រឹក្សាឃុំ នគរបាលមូលដ្ឋាន និងភូមិចាស់ទាំង ៥។ គណៈកម្មការ នេះមានតួនាទីសម្របសម្រួល និងអនុវត្តសកម្មភាពគ្រប់គ្រង ដែលគាំទ្រដល់កិច្ចការពារ និងអភិរក្សធនធានធម្មជាតិ/វប្បធម៌ ការអភិវឌ្ឍមុខរបរចិញ្ចឹមជីវិតដែលមាននិរន្តរភាព។

### អនុកម្មវិធី២.២ ពង្រីកឱកាសសម្រាប់មុខរបរចិញ្ចឹមជីវិតដែលមាននិរន្តរភាពបរិស្ថាន

កិច្ចខិតខំប្រឹងប្រែងនឹងត្រូវធ្វើឡើង ដើម្បីកែប្រែជាបណ្តើរៗពីទម្លាប់ការធ្វើកសិកម្មពនេចរ តាមប្រពៃណី និងកាត់បន្ថយការពឹងផ្អែកលើដំណាំស្វាយចន្ទី ដោយណែនាំឱ្យអនុវត្តវិធីថ្មីៗនៃកសិ-រុក្ខកម្មណាដែលអាចផ្តល់ផលិតផលច្រើនមុខ ផលចំណេញ និងមានមេត្រីភាពបរិស្ថានផងដែរ។ ភាពខ្លាំងរបស់ឧទ្យានជាតិនេះគឺការពឹងផ្អែកលើឈ្មោះរបស់ខ្លួន «ភ្នំគូលែន» ដែលមានការទទួលស្គាល់យ៉ាងទូលំទូលាយ និងពាក់ព័ន្ធជាមួយបរិស្ថាន «ស្អាត»។[4]

គម្រោង «ផលិតផលជីវៈចម្រុះ (BBP)» ដែលទទួលបានការឧបត្ថម្ភហិរញ្ញវត្ថុពីអង្គការ GIZ បានផ្តួចផ្តើមឡើងជាគម្រោងថ្នាក់តំបន់មួយនៅក្នុងឧទ្យានជាតិនេះ ដើម្បីកំណត់អត្តសញ្ញាណផលអនុផលព្រៃឈើ ដែលមានសក្តានុពល និងខ្សែសង្វាក់តម្លៃ ដែលអាចពង្រីកផលប្រយោជន៍ដល់មុខរបរចិញ្ចឹមជីវិតសម្រាប់សហគមន៍មូលដ្ឋាន។ ផ្អែកលើការវាយតម្លៃខ្សែសង្វាក់តម្លៃ ផលិតផលចំនួនបីពីអនុផលព្រៃឈើនៅក្នុងឧទ្យានជាតិនេះ ត្រូវបានផ្តល់អាទិភាពខ្ពស់៖ ប្រទាលថ្លើមផ្លែ (*Zingideraceae*) សិប្បកម្មឫស្សី និងផលិតផលទឹកឃ្មុំ។ តាមរយៈការពង្រីក និងការបង្កើនផលិតផលចេញពីមុខផលិតផលខាងលើនេះ គម្រោង BBP នឹងរួមចំណែកកែលម្អមុខរបរចិញ្ចឹមជីវិត និងសន្តិសុខស្បៀង ដោយផ្តោតលើភូមិនានានៅក្នុងសហគមន៍តំបន់ការពារធម្មជាតិ (P. Tola, 2015) ។ ក្រសួងបរិស្ថាននឹងធ្វើការតាមដានជិតស្និទ្ធនូវលទ្ធផល និងសមិទ្ធផលនៃគម្រោងនេះ។

អង្គការ ADF បច្ចុប្បន្ន កំពុងធ្វើការជាមួយកសិករក្នុងមូលដ្ឋានចំនួន៦០នាក់ ដើម្បីកាត់បន្ថយផលប៉ះពាល់របស់ខ្លួនមកលើព្រៃឈើនៅភ្នំគូលែន ដោយកែប្រែរបៀបធ្វើកសិកម្មពនេចរតាមប្រពៃណី ទៅរកសកម្មភាពដែលផ្តល់ទិន្នផលខ្ពស់ ដូចជាការផលិតផ្សិតអំបោះ ការចិញ្ចឹមត្រី ការចិញ្ចឹមមាន់ និងការដាំបន្លែតាមរដូវកាល។ ថ្មីៗនេះ អង្គការ ADF បានផ្តួចផ្តើមឱ្យមានសហគមន៍នៅក្នុងភូមិព្រះអង្គធំ ដែលមានតួនាទី

---

[4] *ករណីមួយនៃក្រុមហ៊ុនទឹកបរិសុទ្ធគូលែន ដែលប្រើប្រាស់ឈ្មោះគូលែនជា "ស្លាកឈ្មោះ"របស់ខ្លួន។ ជាអកុសល ក្រុមហ៊ុននេះ មកទល់ពេលនេះ បានត្រឹមតែទាញយកទឹកពីឧទ្យាននេះ និងពុំបានធ្វើការវិនិយោគណាមួយដើម្បីការថែរក្សាឧទ្យាននេះឡើយ។*




ជាកន្លែងប្រមូលផ្តុំផលិតផលដែលផលិត ឬដាំនៅក្នុងមូលដ្ឋាន។ ក្រសួងបរិស្ថាននឹងផ្តល់ការឧបត្ថម្ភចំពោះកិច្ចការនេះ និងធ្វើការកៀរគរមូលនិធិបន្ថែមពីម្ចាស់ជំនួយនានា ដើម្បីពង្រីកឱកាសដល់សហគមន៍ឱ្យបានច្រើនបន្ថែមទៀត នៅក្នុងសកម្មភាពប្រកបរបរចិញ្ចឹមជីវិតបែបនេះ។

ដើម្បីឱ្យប្រាកដថា សហគមន៍ទទួលផលដោយផ្ទាល់ពីវត្តមាននៃទីតាំងបុរាណស្ថាន ដែលនៅជុំវិញភូមិរបស់ពួកគាត់ អង្គការ ADF ក៏បានជួលអ្នកភូមិរហូតដល់ ៦០នាក់ ធ្វើជាកម្មករប្រចាំថ្ងៃ នៅក្នុងសកម្មភាពធ្វើ កំណាយបុរាណវិទ្យាប្រចាំឆ្នាំ ហើយអ្នកភូមិ៤៧នាក់បន្ថែមទៀតកំពុងធ្វើការជាមួយអាជ្ញាធរអប្សរា នៅក្នុងការងារថែទាំ និងការពារទីតាំងបុរាណស្ថាន។

ដូចគ្នានេះដែរ ក្រសួងបរិស្ថាននឹងធ្វើឱ្យសហគមន៍មូលដ្ឋានចូលរួមដោយផ្ទាល់នៅក្នុងសកម្មភាពដាំព្រៃឈើ និងស្តារព្រៃឈើឡើងវិញក្នុងឧទ្យានជាតិនេះ រួមទាំងការបង្កើតឱ្យមានថ្នាលបណ្តុះកូនឈើបន្ថែមទៀតផងដែរ។ ក្រោមកិច្ចសហការជាមួយក្រសួងទេសចរណ៍ អាជ្ញាធរអប្សរា និងប្រតិបត្តិករទេសចរណ៍ក្នុងមូលដ្ឋាន វគ្គបណ្តុះបណ្តាល និងការកសាងសមត្ថភាពនឹងត្រូវផ្តល់ជូនសហគមន៍មូលដ្ឋានដើម្បីឱ្យពួកគាត់ចូលរួមដោយផ្ទាល់ផងដែរនៅក្នុងការអភិវឌ្ឍទេសចរណ៍ក្នុងឧទ្យានជាតិ។



### អនុកម្មវិធី២.៣ លើកកម្ពស់ទេសចរណ៍មាននិរន្តរភាព និងអេកូទេសចរណ៍ដែលប្រតិបត្តិការដោយអ្នកមូលដ្ឋាន

ភ្ញៀវភាគច្រើនមកកាន់ឧទ្យានជាតិភ្នំគូលែនត្រូវធ្វើដំណើរតាមផ្លូវ និងតាមច្រកនានា ដែលបានកំណត់នៅក្នុងតំបន់ប្រើប្រាស់ដោយចីរភាព ដើម្បីកាត់បន្ថយផលប៉ះពាល់អវិជ្ជមានមកលើប្រព័ន្ធអេកូឡូស៊ីជិតខាង និងទីតាំងបុរាណស្ថាន ដែលងាយរងគ្រោះ។ ដោយសហការជាមួយសហគមន៍មូលដ្ឋាន អាជ្ញាធរអប្សរា រដ្ឋាបាលថ្នាក់ខេត្ត និងក្រសួងទេសចរណ៍ យុទ្ធសាស្ត្រគ្រប់គ្រងទេសចរណ៍នឹងត្រូវរៀបចំឡើងដើម្បីដោះស្រាយតម្រូវការអភិរក្ស និងការអភិវឌ្ឍ ដើម្បីបង្កើនបទពិសោធដល់ភ្ញៀវទេសចរ។ យុទ្ធសាស្ត្រនេះត្រូវគិតគូរទេសចរណ៍ពីរបែបដែលពាក់ព័ន្ធនឹងឧទ្យានជាតិនេះ គឺ ***ទេសចរណ៍ «ទូទៅ»*** ដែលផ្ដោតលើការទស្សនាទីតាំងវប្បធម៌សំខាន់ៗ (ប្រាសាទ និងទីតាំងបេតិកភណ្ឌដទៃទៀត) និង***អេកូទេសចរណ៍*** ដែលផ្ដោតលើការទទួលបានបទពិសោធពីភាពទាក់ទាញនៃវប្បធម៌ធម្មជាតិ ឬការចិញ្ចឹមជីវិតនៅមូលដ្ឋាន(ទស្សនាសត្វព្រៃ ការស្នាក់នៅតាមគ្រួសារ។ល។)។ ក្នុងឧទ្យានជាតិភ្នំគូលែន ទេសចរណ៍ទូទៅ អាចមានចំនួនច្រើន និង (អាច) បង្កការប៉ះពាល់ខ្លាំង ដែលទាមទារឱ្យមានការវិនិយោគយ៉ាងច្រើនលើហេដ្ឋារចនាសម្ព័ន្ធ និងការគ្រប់គ្រងភ្ញៀវទេសចរ ពីសំណាក់អាជ្ញាធរគ្រប់គ្រងឧទ្យានជាតិ។ ម្យ៉ាងវិញទៀត អេកូទេសចរណ៍ទំនងជា «មានភ្ញៀវតិចជាង-ផលប៉ះពាល់ទាបជាង» និងជាការល្អត្រូវគ្រប់គ្រងដោយសហគមន៍មូលដ្ឋាន និងអាជ្ញាធរមូលដ្ឋានណា ដែលទទួលបានការបណ្ដុះបណ្ដាល ដើម្បីបង្កើនឱកាសសម្រាប់ការងារអេកូទេសចរណ៍។

ការគិតគូរជាយុទ្ធសាស្ត្រនៅក្នុងអនុកម្មវិធីនេះ ក៏ផ្ដោតផងដែរលើ៖

- ការពិនិត្យកែសម្រួល និងក្នុងករណីចាំបាច់ ត្រូវដាក់កំហិតលើការធ្វើជំនួញដែលមានបច្ចុប្បន្ននៅកន្លែងទឹកធ្លាក់ព្រះអង្គធំ ដែលសម្បូរទៅដោយតូបលក់ទំនិញ និងកន្លែងលក់អាហារ។

- សហការជាមួយមជ្ឈមណ្ឌលសកម្មភាពកំចាត់មីនកម្ពុជា (CMAC) ដើម្បីបញ្ចប់ការដោះមីនក្នុងឧទ្យានជាតិ ដើម្បីជាប្រយោជន៍សម្រាប់សកម្មភាពអភិវឌ្ឍន៍វិស័យទេសចរណ៍ និងសហគមន៍មូលដ្ឋាន។
- ការបង្កើតផែនទី និងកូនសៀវភៅសម្រាប់ផ្តល់ព័ត៌មានអំពីសម្បទាឧទ្យានជាតិ ទិដ្ឋភាពនានានៃធម្មជាតិ និងទីតាំងដែលមានចំណាប់អារម្មណ៍ខាងបុរាណវិទ្យាក្នុងឧទ្យានជាតិនេះ ផែនទី និងកូនសៀវភៅផ្តល់ព័ត៌មាន ត្រូវផលិតឡើងដោយយកថវិកាពីកម្រៃដែលត្រូវបង់សម្រាប់ការចូលកម្សាន្តរបស់ភ្ញៀវទេសចរ មកទីតាំងព្រះអង្គធំ និងក្បាលស្ពាន។ ក្រុមហ៊ុនឯកជន (ដូចជា ក្រុមហ៊ុនទឹកបរិសុទ្ធទឹកធម្មជាតិភ្នំគូលែន) អាចនឹងត្រូវទាក់ទងដើម្បីឱ្យជួយផ្តល់ហិរញ្ញវត្ថុសម្រាប់ការរៀបចំផលិតកូនសៀវភៅផ្តល់ព័ត៌មាននេះ។
- ការសាងសង់មណ្ឌលព័ត៌មាននៅតាមទីតាំងសំខាន់ៗក្នុងឧទ្យានជាតិ ដូចជានៅមេណីយដ្ឋានក្បាលស្ពាន និងព្រះអង្គធំ ដោយបំពាក់សម្ភារៈគ្រប់គ្រាន់(បន្ទប់ទឹក) និងព័ត៌មានផ្សេងៗ ដើម្បីបង្កើនការយល់ដឹង និងចំណាប់អារម្មណ៍ដល់ភ្ញៀវទេសចរអំពីគុណតម្លៃនៃធនធានធម្មជាតិ និងបេតិកភណ្ឌវប្បធម៌ក្នុងឧទ្យានជាតិ
- ការដំឡើងស្លាកសញ្ញា (ជាភាសាខ្មែរ និងអង់គ្លេស) នៅទីតាំងព្រះអង្គធំ និងក្បាលស្ពាន ដែលបង្ហាញពីទីតាំងនៃបេតិកភណ្ឌពិភពលោកអង្គរ
- បើកវគ្គបណ្តុះបណ្តាលដល់អ្នកភូមិ និងមន្ត្រីល្បាត អំពីការងារគ្រប់គ្រងទេសចរណ៍
- កែលម្អទំនាក់ទំនង និងកិច្ចសហការរវាងក្រុមហ៊ុនទេសចរណ៍នៅក្នុងមូលដ្ឋាន និងមន្ត្រីល្បាត
- រៀបចំគោលការណ៍ណែនាំស្តីពី ការគ្រប់គ្រងទេចសរណ៍ក្នុងតំបន់នីមួយៗ ដើម្បីបង្ហាញឱ្យច្បាស់លាស់អំពីសកម្មភាពនានាដែលអាចអនុញ្ញាតនៅក្នុងតំបន់ការពារនីមួយៗ
- ឯកភាពលើហេដ្ឋារចនាសម្ព័ន្ធសម្រាប់ភ្ញៀវទេសចរ និងប្រព័ន្ធតម្លាភាពសម្រាប់បង្វែរផលចំណូលដើម្បីបម្រើឱ្យការងារការពារ និងការគ្រប់គ្រងឧទ្យានជាតិនេះវិញ
- កែលម្អផ្លូវថ្នល់និងចំណតរថយន្ត ក្នុងករណីចាំបាច់ត្រូវផ្តល់សម្បទា ដើម្បីសម្រួលដល់ការចេញចូលរបស់ភ្ញៀវទេសចរ។

អាទិភាពខ្ពស់នឹងត្រូវផ្តល់ជូនដល់ប្រជាពលរដ្ឋក្នុងមូលដ្ឋានណា ដែលបានរស់នៅរយៈពេលយូរក្នុងការផ្តល់សេវានៅក្នុងឧទ្យានជាតិនេះ (ដូចជា សេវាជូនភ្ញៀវ អ្នកលក់ចំណីអាហារ សិប្បកម្ម កន្លែងស្នាក់នៅ និងផ្ទះសំណាក់)។ ក្រុមហ៊ុនទេសចរណ៍ មគ្គុទេសក៍ និងប្រតិបត្តិករអាជីវកម្មនៅតាមកន្លែងដែលមានការកំណត់ក្នុងឧទ្យានជាតិនេះត្រូវតែបានចុះបញ្ជី និងទទួលបានអាជ្ញាប័ណ្ណពីក្រសួងទេសចរណ៍ និងទទួលបានការអនុញ្ញាតពីមន្ទីរបរិស្ថានខេត្ត។ ក្រុមហ៊ុនទេសចរណ៍ក្នុងស្រុក ដែលមានប្រវត្តិល្អក្នុងការផ្តល់សេវាអេកូទេសចរណ៍ប្រកបដោយការទទួលខុសត្រូវខាងផ្នែកសង្គម (ដូចជា Terre Cambodge) គួរតែចូលរួមជាអ្នកផ្តល់ការប្រឹក្សានៅក្នុងការរៀបចំ យុទ្ធសាស្ត្រគ្រប់គ្រងទេសចរណ៍។

### អនុកម្មវិធី២.៤. ការគ្រប់គ្រងសំណល់(រឹង និងរាវ)

បរិមាណសំណល់រឹង និងសំណល់រាវនាពេលបច្ចុប្បន្ន ដែលកើតឡើងដោយសារតែចំនួនភ្ញៀវដ៏ច្រើនមក ទស្សនាឧទ្យានជាតិនេះ (ជាពិសេស នៅព្រះអង្គធំ) មិនត្រឹមតែបង្កផលប៉ះពាល់ដល់ភ្ញៀវទេសចរប៉ុណ្ណោះទេ ប៉ុន្តែក៏បង្កការគំរាមកំហែងចំពោះគុណភាពទឹកផងដែរ។ ធុងសំរាមនឹងត្រូវដាក់នៅតាមទីកន្លែងនានាឱ្យបានគ្រប់គ្រាន់ ដើម្បីលុបបំបាត់សំរាមនៅតាមទីតាំងដែលមានទេសចរចេញចូល។ ការកែច្នៃកាកសំណល់ឡើងវិញត្រូវលើកទឹកចិត្ត ហើយក្នុងករណីដែលអាចធ្វើបាន ត្រូវដាក់កំហិតលើការប្រើប្រាស់ថង់ប្លាស្ទិក និងដបទឹក ដោយត្រូវប្រើប្រាស់សម្ភារៈដែលអាចកែច្នៃឡើងវិញបានជាជំនួសដែលផលិតក្នុងស្រុក (រួមទាំងធុងសិប្បកម្ម និងផលិតផលពីស្លឹកឈើ)។ ប្រតិបត្តិករទេសចរណ៍ និងភ្ញៀវទេសចរនឹងត្រូវបានលើកទឹកចិត្តមិនឱ្យនាំយកប្លាស្ទិកចូលក្នុងឧទ្យានជាតិ។ ការចោលសំរាម និងសំណល់រាវតាមប្រភពទឹកនឹងត្រូវហាមឃាត់យ៉ាងតឹងរ៉ឹង បើអាចត្រូវមានការផាកពិន័យ។

តាមធម្មតា សំណល់ដែលបង្កើតឡើងនៅក្នុងឧទ្យានជាតិនេះ ត្រូវតែយកចេញទៅរក្សាទុកនៅតាមកន្លែងគ្រប់គ្រងសំណល់ ដែលស្ថិតនៅក្រៅឧទ្យានជាតិ។ ទោះជាយ៉ាងណាក៏ដោយ ដោយសារតែថ្លៃចំណាយលើការដឹកជញ្ជូនមានកម្រិតខ្ពស់ ជម្រើសផ្សេងទៀតក៏នឹងត្រូវសិក្សាផងដែរ ដូចជាការដុតសំរាមដែលមិនបង្កគ្រោះថ្នាក់នៅកន្លែងណាមួយក្នុងឧទ្យានជាតិ។

## កម្មវិធីទី៣៖ ពង្រឹងសមត្ថភាពស្ថាប័ន និងកិច្ចសហការ

បញ្ហាជាច្រើន ដែលកំពុងប្រឈមចំពោះឧទ្យានជាតិភ្នំគូលែននាពេលបច្ចុប្បន្ន គឺទាក់ទងនឹងយុត្តាធិការត្រួតគ្នា និងសមត្ថភាពគ្រប់គ្រង ព្រមទាំងធនធានមានកម្រិត (ធនធានមនុស្ស និងហិរញ្ញវត្ថុ) ដែលក្រសួងបរិស្ថាន មានកាតព្វកិច្ចការពារ និងគ្រប់គ្រងឧទ្យាននេះឱ្យមានប្រសិទ្ធភាព។ ដោយសារតែឧទ្យានជាតិនេះមានសារៈសំខាន់ចំពោះខេត្តសៀមរាប និងជាប្រយោជន៍សម្រាប់ប្រជាពលរដ្ឋកម្ពុជាទាំងមូល រាជរដ្ឋាភិបាលកម្ពុជានឹងត្រូវថែរក្សាធនធានក្នុងឧទ្យានជាតិ ឱ្យប្រាកដថា មនុស្សគ្រប់ជំនាន់នឹងមានមោទនភាពចំពោះបេតិកភណ្ឌធម្មជាតិ និងវប្បធម៌ដែលមានក្នុងឧទ្យាននេះ។ ប្រសិទ្ធភាពនៃការគ្រប់គ្រងត្រូវពង្រីក តាមរយៈការបង្កើនកិច្ចសហការឱ្យកាន់តែប្រសើរជាងមុន ជាមួយស្ថាប័ននានា និងតាមរយៈការចងក្រងជាឯកសារអំពីតម្លៃសេដ្ឋកិច្ចនៃឧទ្យានជាតិ ក្នុងមុខងារជាអាងស្តុកទឹកភ្លៀង និងសក្តានុពលខាងទេសចរណ៍។ កម្មវិធីទី៣ មាន ៣អនុកម្មវិធីដូចខាងក្រោម៖

### អនុកម្មវិធី៣.១ កំណត់តួនាទី និងការទទួលខុសត្រូវរបស់ស្ថាប័ន

ក្នុងនាមស្ថាប័នគ្រប់គ្រងលើតំបន់ការពារធម្មជាតិ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ក្រសួងបរិស្ថានមានសមត្ថកិច្ចអភិរក្ស និងការពារឧទ្យានជាតិភ្នំគូលែន។ សមត្ថកិច្ចនេះរាប់បញ្ចូលទាំងការអនុញ្ញាតលើការចេញចូលឧទ្យាន និងការលើកកម្ពស់មុខរបរចិញ្ចឹមជីវិតដែលធ្វើឱ្យបរិស្ថានមាននិរន្តរភាព (រួមទាំងអេកូទេសចរណ៍)។ អាជ្ញាធរអប្សរា មានភារៈកិច្ចទទួលខុសត្រូវលើការងារថែរក្សា និងការពារបុរាណស្ថានដែលមានក្នុងតំបន់បេតិកភណ្ឌពិភពលោកអង្គរ ក៏ដូចជា ក្នុងខេត្តសៀមរាបទាំងមូល (រួមបញ្ចូលទាំង

ឧទ្យានជាតិនេះផងដែរ)។ ទោះបីជាមាន ភាពត្រួតគ្នានៃទីតាំងភូមិសាស្ត្រក៏ដោយ ក៏តួនាទីនិងភារកិច្ចរបស់ស្ថាប័នពាក់ព័ន្ធគឺជាច់គ្នា និងបំពេញឱ្យគ្នាទៅវិញទៅមក។

### អនុកម្មវិធី៣.២ ធានាឱ្យមានបុគ្គលិកគ្រប់គ្រាន់ ប្រកបដោយសមត្ថភាព និងធនធានសមស្រប

សមត្ថភាព និងធនធានជាកត្តាចាំបាច់សម្រាប់ការអនុវត្តច្បាប់ឱ្យមានប្រសិទ្ធភាព ដូចមានបញ្ជាក់នៅត្រង់ចំណុចអនុកម្មវិធី១.៣។ លើសពីនេះ ទាំងមន្ត្រីល្បាត និងអាជ្ញាធរថ្នាក់ក្រោមជាតិ (នៅថ្នាក់ខេត្ត ស្រុក និងឃុំ) ត្រូវឆ្លងកាត់វគ្គបណ្តុះបណ្តាល ដែលផ្តោតគោលដៅលើវិធីសាស្ត្រនៃការចូលរួមរបស់សហគមន៍មូលដ្ឋានក្នុងការរៀបចំផែនការ និងការគ្រប់គ្រងតំបន់ការពារធម្មជាតិ (រួមទាំង ការពង្រឹកមុខរបរចិញ្ចឹមជីវិតផងដែរ)។ វគ្គបណ្តុះបណ្តាលនេះ គួរតែរៀបចំដោយអង្គភាពជំនាញនៃក្រសួងបរិស្ថានគ្រប់គ្រងវគ្គដោយមន្ត្រីនៃអគ្គនាយកដ្ឋានរដ្ឋបាលការពារ និងអភិរក្សធម្មជាតិ និងអគ្គនាយកដ្ឋានសហគមន៍មូលដ្ឋាន និងមានការចូលរួមជួយឧបត្ថម្ភពីអង្គការមិនមែនរដ្ឋាភិបាល ដែលមានបទពិសោធការងារជាមួយសហគមន៍មូលដ្ឋានដោយផ្ទាល់ (សូមអានកម្មវិធី២.១)។

នៅកម្រិតមន្ទីរបរិស្ថានខេត្តត្រូវមានការពង្រឹងសមត្ថភាពបច្ចេកទេសបន្ថែមទៀត ដើម្បីអាចដឹកនាំ និងគាំទ្រការអនុវត្តកម្មវិធីគ្រប់គ្រងឧទ្យានជាតិនេះ។ ប្រការសំខាន់គឺត្រូវធានាថា មន្ត្រីនៃមន្ទីរបរិស្ថានខេត្តត្រូវបានបញ្ជូនឱ្យចូលរួមក្នុងគ្រប់វគ្គបណ្តុះបណ្តាលលើការងារបច្ចេកទេស ឬក្នុងសិក្ខាសាលានានា ដែលរៀបចំនៅថ្នាក់កណ្តាល ដោយ អគ្គនាយកដ្ឋានរដ្ឋបាលការពារនិងអភិរក្សធម្មជាតិ និង/ឬអគ្គនាយកដ្ឋានសហគមន៍មូលដ្ឋាន។ លើសពីនេះទៀត ការបញ្ជូនមន្ត្រី ឬផ្ទេរមន្ត្រីពីក្រសួងបរិស្ថាន (អគ្គនាយកដ្ឋានរដ្ឋបាលការពារ និងអភិរក្សធម្មជាតិ /អគ្គនាយកដ្ឋានសហគមន៍មូលដ្ឋាន) គួរពិចារណាផងដែរលើការបង្កើនសមត្ថភាពបច្ចេកទេសនៅថ្នាក់ខេត្ត។ តម្រូវការជាបន្ទាន់មួយដែលប្រធានមន្ទីរបរិស្ថានបានលើកឡើងគឺ ត្រូវមានបុគ្គលិកដែលអាចរៀបចំសំណើងាយៗដើម្បីសុំមូលនិធិគាំទ្រ។ ប្រធានមន្ទីរបរិស្ថានខេត្តគួរកំណត់ថវិកាប្រតិបត្តិការប្រចាំឆ្នាំសម្រាប់ឧទ្យានជាតិ «ភ្នំគូលែន» ទៅក្នុងកញ្ចប់ថវិការបស់ក្រសួងបរិស្ថាន ដើម្បីធានាចំណាយសំខាន់ៗពាក់ព័ន្ធនឹង ការធ្វើដំណើរ ការរៀបចំសិក្ខាសាលា វគ្គបណ្តុះបណ្តាល រួមទាំង សម្ភារៈបរិក្ខារ និងការថែទាំហេដ្ឋារចនាសម្ព័ន្ធផងដែរ។

ការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធ (កែលម្អស្នាក់ការកណ្តាលនៃឧទ្យានជាតិ និងការប្តូរទីតាំងប៉ុស្តិ៍យាមវេងមួយចំនួន) រថយន្តថ្មីៗ (4WD មួយគ្រឿង និងទោចក្រយានយន្តសម្រាប់ចូលព្រៃ ១០គ្រឿង) និងបរិក្ខារថ្មីៗ (វិទ្យុទាក់ទង, GPS, អាវុធ និងម៉ាស៊ីនថតពីចម្ងាយ) គឺជាការចាំបាច់ ដោយត្រូវស្វែងរកថវិកាពីប្រភពជំនួយនានាៗ របស់រាជរដ្ឋាភិបាល និងស្ថាប័នអភិវឌ្ឍន៍អន្តរជាតិ។

### អនុកម្មវិធី៣.៣ ពង្រឹកកិច្ចសហការដើម្បីការពារ និងគ្រប់គ្រង

ការពង្រឹកកិច្ចសហការរវាងក្រសួងបរិស្ថាន និងក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ តាមរយៈអាជ្ញាធរអប្សរា គឺជាការចាំបាច់ ក្នុងការអនុវត្តកម្មវិធីគ្រប់គ្រងនេះ ដោយសារពាក់ព័ន្ធនឹងការងារអភិរក្ស និងកិច្ចការពារទីតាំងបេតិកភណ្ឌវប្បធម៌។ ប្រសិនបើឧទ្យានជាតិនេះត្រូវបានបញ្ចូលជាផ្នែកមួយនៃតំបន់បេតិកភណ្ឌពិភពលោកអង្គរ ចាំបាច់ត្រូវគូសបញ្ជាក់អំពីតួនាទីនិងភារកិច្ចក្នុងកិច្ចការពារ និងគ្រប់គ្រងឧទ្យានជាតិ «ភ្នំគូលែន»។

ដោយសារឧទ្យានជាតិភ្នំគូលែនគឺជាទីកន្លែងគោរពបូជា ក្រសួងធម្មការនិងសាសនា នឹងត្រូវចូលរួមនៅក្នុងសកម្មភាពបង្កើតការយល់ដឹង ជាពិសេស ក្នុងការផលិតសម្ភារៈផ្សព្វផ្សាយដល់ភ្ញៀវទេសចរដែលចូលមកទស្សនា។

រដ្ឋបាលព្រៃឈើមានតួនាទីសំខាន់មួយក្នុងការជួយគាំទ្រ និងផ្តល់យោបល់ណែនាំបច្ចេកទេសអំពីការស្តារព្រៃឈើឡើងវិញ។ លើសពីនេះ ព្រៃឈើដែលនៅជាប់នឹងឧទ្យានជាតិ ក្រោមការគ្រប់គ្រងរបស់រដ្ឋបាលព្រៃឈើបច្ចុប្បន្ន ត្រូវបានផ្ទេរមកក្រសួងបរិស្ថាន ដែលអាចផ្តល់កិច្ចការពារបន្ថែមសម្រាប់តំបន់ស្នូលនៅលើខ្ពង់រាបខាងលិចនៃឧទ្យានជាតិ។ កិច្ចសហការជិតស្និទ្ធជាមួយរដ្ឋបាលព្រៃឈើលើការវាយតម្លៃធនធានធម្មជាតិ និងយុទ្ធសាស្ត្រគ្រប់គ្រងទីកន្លែងថ្មីនេះ មានសារៈសំខាន់។

អង្គការអន្តរជាតិចំនួនពីរដែលបាន និងកំពុងធ្វើការក្នុងឧទ្យានជាតិនេះ អស់រយៈពេលជាច្រើនឆ្នាំមកនោះ(ACCB និងADF) អាចផ្តល់ជាយោបល់បច្ចេកទេស និងការគាំទ្រសម្រាប់ការអនុវត្តកម្មវិធីគ្រប់គ្រងឧទ្យានជាតិនេះ។ ក្រសួងបរិស្ថានគួរទទួលស្គាល់នូវការចូលរួមរបស់អង្គការទាំងពីរខាងលើនេះ និងត្រូវបង្កើតទំនាក់ទំនងជាផ្លូវការតាមរយៈអនុស្សរណៈនៃការយោគយល់ជាមួយអង្គការទាំងនេះ។[5]

## កម្មវិធីទី៤៖ ជានានិរន្តរភាពហិរញ្ញប្បទាន

ចំណុចជាយុទ្ធសាស្ត្រនៃកម្មវិធីនេះ គឺការកំណត់ថវិកាសម្រាប់ចំណាយលើកិច្ចប្រតិបត្តិការកម្មវិធីដែលចាំបាច់សម្រាប់ការអនុវត្តនៅដំណាក់កាលដំបូងៗនៃកម្មវិធីគ្រប់គ្រងឧទ្យានជាតិភ្នំគូលែន និងការលើកស្ទួយប្រភពហិរញ្ញប្បទាន ដែលមានក្នុងមូលដ្ឋាន សម្រាប់ការទ្រទ្រង់លើការងារអន្តរាគមន៍ផ្សេងៗ។ កម្មវិធីទី៤ មាន ២អនុកម្មវិធី ដូចខាងក្រោម៖

### អនុកម្មវិធី៤.១. ពង្រីកកិច្ចសហការដើម្បីការពារ និងគ្រប់គ្រង

ចំណាយប៉ាន់ស្មាន ក្នុងការអនុវត្តកម្មវិធីគ្រប់គ្រងឧទ្យានជាតិភ្នំគូលែន សម្រាប់រយៈពេល ៥ឆ្នាំខាងមុខ (២០១៨-២០២២) មានប្រមាណ ២.៨លានដុល្លារអាមេរិក (**ឧបសម្ព័ន្ធ៤**) បន្ថែមលើថវិកាដែលមានបច្ចុប្បន្នពី រដ្ឋាភិបាលសម្រាប់ការងារគ្រប់គ្រងឧទ្យានជាតិនេះ ដូចជាការចំណាយលើប្រាក់បៀវត្សរ៍មន្ត្រីល្បាត និងការចំណាយលើប្រតិបត្តិការសំខាន់ៗដទៃទៀត (**ឧបសម្ព័ន្ធ៥**)។ ថវិកាចំណាយខាងលើនេះមិនរាប់បញ្ចូលថវិកាដែលអាចត្រូវបានចូលរួមដោយអាជ្ញាធរអប្សរាសម្រាប់ការគ្រប់គ្រង និងការការពារបេតិកភណ្ឌវប្បធម៌ក្នុងឧទ្យានជាតិនេះឡើយ។

ជាង ៥០% នៃការចំណាយសម្រាប់កម្មវិធីនេះត្រូវបានវិភាជន៍សម្រាប់សកម្មភាពជាំស្តារព្រៃឈើឡើងវិញ ដើម្បីស្តារគម្របព្រៃឈើធម្មជាតិជាបន្តបន្ទាប់ ក្នុងគោលដៅលើផ្ទៃដីយ៉ាងហោចណាស់ ១.០០០ ហិកតា ត្រូវបានស្តារនៅមុនឆ្នាំ២០២២។ ការវិនិយោគធំៗដទៃទៀតនឹងត្រូវធ្វើនៅក្នុងវិស័យនានានៃការពង្រីកសមត្ថភាព និងបង្កើតមុខរបរចិញ្ចឹមជីវិតដែលមាននិរន្តរភាព ការកែលម្អសម្បទា និងហេដ្ឋារចនាសម្ព័ន្ធ

---

[5] *ACCB មានកិច្ចព្រមព្រៀងមួយជាមួយក្រសួងបរិស្ថាន ប៉ុន្តែនៅត្រូវធ្វើបច្ចុប្បន្នភាព និងចុះហត្ថលេខាឡើងវិញ។ អង្គការ ADF កំពុងចាប់ផ្តើមធ្វើការចរចាឡើងវិញដើម្បីឲ្យមានអនុស្សរណៈនៃការយោគយល់មួយជាមួយក្រសួងបរិស្ថាន។*

ដើម្បីអាចគ្រប់គ្រងភ្ញៀវទេសចរដែលមានចំនួនកាន់តែច្រើនឡើង ឱ្យមានប្រសិទ្ធភាព។

ស្ថាប័នទទួលខុសត្រូវនាំមុខ និងគាំទ្រត្រូវបានកំណត់សម្រាប់សកម្មភាព ក្នុងកម្មវិធីនីមួយៗ (ឧបសម្ព័ន្ធ៤)។ ការវិភាគថវិកាប្រចាំឆ្នាំឱ្យបានលម្អិត យើងអាចមើលឃើញថា សកម្មភាព និងការចំណាយភាគច្រើននឹងកើតមាននៅឆ្នាំទី២ និងទី៣ (២០១៩-២០២០) ដោយសន្មត់ថា ថវិកាសម្រាប់អនុវត្តនឹងអាចអនុម័ត នៅដើមឆ្នាំ២០១៨ (ឧបសម្ព័ន្ធ៥)។

ការអនុវត្តកម្មវិធីគ្រប់គ្រងឧទ្យានជាតិភ្នំគូលែននឹងត្រូវដឹកនាំ និងសម្របសម្រួលដោយក្រុមការងារភ្នំគូលែន ដោយមានតំណាងមកពីគ្រប់អាជ្ញាធរពាក់ព័ន្ធ។ គណៈកម្មការគ្រប់គ្រងឧទ្យានជាតិនៅមូលដ្ឋាននឹងមានភារៈកិច្ចទទួលខុសត្រូវលើការអនុវត្តសកម្មភាពនានាដោយផ្ទាល់។

### អនុកម្មវិធី៤.២. កំណត់រក និងធានាឱ្យមានប្រភពហិរញ្ញប្បទានដែលមាននិរន្តរភាព

បច្ចុប្បន្ន ឧទ្យានជាតិភ្នំគូលែនពុំមានថវិកាដោយឡែកសម្រាប់ប្រើប្រាស់ឡើយ។ ប្រាក់បៀវត្សរ៍សម្រាប់មន្ត្រីល្បាត និងមន្ត្រីនៃមន្ទីរបរិស្ថានខេត្តត្រូវផ្តល់ដោយក្រសួងបរិស្ថានដោយផ្ទាល់ ជាមួយនឹងប្រាក់ឧបត្ថម្ភបន្ថែមតិចតួចសម្រាប់ការចុះប្រតិបត្តិការ ឬល្បាតប្រចាំថ្ងៃ។ លទ្ធកម្មបរិក្ខារសំខាន់ៗសម្រាប់ឧទ្យានជាតិនេះ (មានដូចជា បង្គោលព្រំប្រទល់) ត្រូវបានចាត់ចែងដោយផ្ទាល់ពីភ្នំពេញ ចំណែកមន្ទីរបរិស្ថានខេត្តមានថវិកាតិចតួចសម្រាប់ចំណាយទូទៅ (មិនបានបម្រុងទុកសម្រាប់តំបន់ការពារធម្មជាតិនេះឡើយ)។

មូលនិធិរបស់រាជរដ្ឋាភិបាល ដែលជាប្រភពហិរញ្ញប្បទានអាចទុកចិត្តបានសម្រាប់រយៈពេលវែង (មិនដូចគម្រោង) មានកម្រិតកំណត់នៅឡើយ និងមិនគ្រប់គ្រាន់សម្រាប់ការចំណាយចាំបាច់លើការកែលម្អហេដ្ឋារចនាសម្ព័ន្ធ និងបរិក្ខារផ្សេងៗក្នុងឧទ្យានជាតិឡើយ។ ដូច្នេះ ត្រូវកំណត់រកថវិកាពីប្រភពផ្សេងៗដើម្បីយកមកអនុវត្ត កម្មវិធីគ្រប់គ្រងឧទ្យានជាតិភ្នំគូលែននេះ។

កម្រៃបានមកពីភ្ញៀវចូលទស្សនាឧទ្យានជាតិ គឺជាប្រភពប្រកបដោយសក្តានុពលល្អបំផុត និងជាយន្តការ ហិរញ្ញប្បទានដែលមាននិរន្តរភាព និងអាចប្រើប្រាស់សម្រាប់ការចំណាយលើកិច្ចការពារ ការស្តារ និងការគ្រប់គ្រងធនធានក្នុងឧទ្យានជាតិបាន។ ផលចំណូល ដែលប្រមូលបានដោយក្រុមហ៊ុនឯកជននៅច្រកចូលឧទ្យានជាតិ (ពុំត្រូវបានប្រកាសឱ្យដឹងជាសាធារណៈ) អាចជាវិភាគទានយ៉ាងសំខាន់មួយសម្រាប់បម្រើឱ្យកិច្ចការពារ និងការគ្រប់គ្រងឧទ្យានជាតិនេះ។ ជំហានជាបន្ទាន់ទៀតត្រូវតែយកមកអនុវត្ត ដើម្បីបង្កើតយន្តការហិរញ្ញប្បទាននេះ គួរតែ៖

- រាជរដ្ឋាភិបាលកម្ពុជាត្រូវលុបចោលសម្បទានឯកជន និងផ្ទេរកម្មសិទ្ធិនេះមកឱ្យក្រសួងបរិស្ថាន ដែលជាស្ថាប័នទទួលខុសត្រូវលើការគ្រប់គ្រងឧទ្យានជាតិភ្នំគូលែន
- ក្រសួងបរិស្ថានត្រូវចុះកិច្ចព្រមព្រៀងជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីក្រសួងបរិស្ថានអាចធ្វើការ វិនិយោគឡើងវិញនូវផលចំណូលដែលប្រមូលបានទាំងនោះសម្រាប់បម្រើឱ្យការងារគ្រប់គ្រងឧទ្យាននេះ។
- សហការជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្នុងការអភិវឌ្ឍនីតិវិធីប្រតិបត្តិការយ៉ាងច្បាស់លាស់សម្រាប់ការប្រមូលនិងការប្រើប្រាស់ចំណូល ដើម្បីធានាតម្លាភាពនិងសមត្ថភាពគ្រប់គ្រាន់

ក្នុងការគ្រប់គ្រងឧទ្យាន។

ប្រភពហិរញ្ញប្បទានដទៃទៀតត្រូវគិតគូផងដែរ ដូចជា៖ ការទូទាត់សេវាកម្មបរិស្ថាន (PES) ដោយផ្អែកលើគុណតម្លៃនៃអាងស្តុកទឹកភ្លៀង ជាពិសេស សម្រាប់សណ្ឋាគារ និងឧស្សាហកម្មទេសចរណ៍ព្រមទាំងវិស័យឯកជននានា (ដូចជាក្រុមហ៊ុនទឹករ៉ែធម្មជាតិ អ៊ូគូលែន)។ គុណតម្លៃនៃព្រៃឈើ និងថ្លៃចំណាយពាក់ព័ន្ធសម្រាប់ការងារការពារ និងការស្តារព្រៃឈើទាំងនោះឡើងវិញក្នុងឧទ្យានជាតិអាចយកមកប្រើប្រាស់ដើម្បីទទួលបានហិរញ្ញវត្ថុពីមូលនិធិអាកាសធាតុបៃតងឬកម្មវិធីវិនិយោគព្រៃឈើ។ កិច្ចប្រជុំក្រុមប្រឹក្សាភិបាលនៃមូលនិធិអាកាសធាតុបៃតងកន្លងទៅបានអនុម័តថា មូលនិធិបន្សាំការប្រែប្រួលអាកាសធាតុបច្ចុប្បន្ននៅភ្នំគូលែននឹងត្រូវពង្រីក ដោយរួមបញ្ចូលការអនុវត្តសកម្មភាពនៅក្នុងភូមិចាស់ទាំងប្រាំ។ នៅពេលដែលកម្មវិធីគ្រប់គ្រងនេះត្រូវបានគាំទ្រដោយរដ្ឋមន្ត្រីក្រសួងបរិស្ថាន ក្រសួងអាចប្រើកម្មវិធីគ្រប់គ្រងនេះជាមូលដ្ឋានសម្រាប់ដាក់ពាក្យស្នើសុំថវិកាពីមូលនិធិអាកាសធាតុបៃតង ដំណាក់កាលទី៧។

ប្រការសំខាន់មួយផងដែរគឺត្រូវលើកគម្រោងស្នើសុំមូលនិធិពីម្ចាស់ជំនួយដទៃៗទៀត ដែលឆ្លើយតបទៅនឹងតម្រូវការនៃការគ្រប់គ្រង និងចូលរួមចំណែកក្នុងការអនុវត្តកម្មវិធីគ្រប់គ្រងឧទ្យានជាតិភ្នំគូលែននេះ។

## ៥. ការស្រាវជ្រាវ ពិនិត្យ និងតាមដាន

ការវាយតម្លៃពេញលេញមួយអំពីគុណតម្លៃនៃទីជម្រាលនៃឧទ្យានជាតិជាតិ និងគុណតម្លៃសេដ្ឋកិច្ចចំពោះខេត្តសៀមរាប គួរតែបានធ្វើឡើងដើម្បីស្វែងយល់ឱ្យបានច្បាស់អំពីគុណតម្លៃនៃធនធានធម្មជាតិក៏ដូចជា ផលវិបាក និងការខាតបង់នៃការមិនបានការពារធនធាន ដែលមានសារៈសំខាន់សម្រាប់បរិស្ថានជីវិត។ ឧទ្យានជាតិភ្នំគូលែនផ្តល់នូវឱកាសល្អបំផុតក្នុងការរៀបចំ និងអនុវត្តគម្រោងបង់កម្រៃលើសេវាកម្មធនធានធម្មជាតិ(PES) ក្នុងគោលបំណងបង្កើនសក្តានុពលប្រាក់ចំណូល ដែលអាចជាប្រភពហិរញ្ញវត្ថុសម្រាប់បម្រើឱ្យកិច្ចការពារធនធានធម្មជាតិ និងបេតិកភណ្ឌវប្បធម៌ និងចូលរួមចំណែកក្នុងការអភិវឌ្ឍជីវភាពសហគមន៍មូលដ្ឋានប្រកបដោយនិរន្តរភាព។

ការសិក្សាស្រាវជ្រាវជីវៈចម្រុះបន្ថែមទៀត គួរទទួលបាននូវការលើកទឹកចិត្តផងដែរ ដែលធ្វើឡើងនៅក្នុងតំបន់ស្នូលនិងតំបន់អភិរក្ស ដើម្បីយកលទ្ធផលមកប្រៀបធៀបជាមួយទិន្នន័យគោល ដែលបានកត់ត្រានៅក្នុងការអង្កេតកាលពីឆ្នាំ២០១៣ (Hayes et al., 2013)។ ការអង្កេតនានាបន្ថែមទៀត ស្តីពីគម្របព្រៃឈើ និងជីវៈចម្រុះ គួរត្រូវបានធ្វើឡើងនៅក្នុងតំបន់ព្រៃភាគពាយ័ព្យ នៃព្រំប្រទល់ឧទ្យានជាតិនេះ ដើម្បីទទួលបានព័ត៌មានសម្រាប់ធ្វើបច្ចុប្បន្នភាពមូលដ្ឋាន (Mould et al., 2013) និងសកម្មភាពគ្រប់គ្រងទៅអនាគត។ ការស្រាវជ្រាវបន្ថែមអំពីការគ្រប់គ្រង និងការអភិរក្សទីតាំងបេតិកភណ្ឌ/បុរាណស្ថាន គួរទទួលបានការឧបត្ថម្ភ និងអនុវត្តតាមរយៈកិច្ចសហការជាមួយក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ជាពិសេសជាមួយអាជ្ញាធរអប្សរា។

ការតាមដានវឌ្ឍនភាពនៃការអនុវត្តកម្មវិធីគ្រប់គ្រងឧទ្យានជាតិនេះ ត្រូវធ្វើឡើងប្រចាំឆ្នាំដោយមន្ទីរបរិស្ថានខេត្ត និងរាយការណ៍មកក្រសួងបរិស្ថាន។ ការចុះត្រួតពិនិត្យនិងវាយតម្លៃពេញលេញមួយនឹង

ត្រូវធ្វើឡើងក្រោយរយៈពេលប្រាំឆ្នាំ (២០២២) ដែលនៅពេលនោះកម្មវិធីនេះនឹងត្រូវកែសម្រួល តាមការចាំបាច់ និងដាក់ឱ្យអនុវត្តសម្រាប់រយៈពេល៥ឆ្នាំបន្តទៀត។



## ៦.ឯកសារយោង


Archaeology and Development Foundation. 2015. ADF Annual Report. 8 pp.

Bonheur, N., K.E. Hourt and T. Phy. (2008). Preliminary study of Kulen National Park for development of Botanical Garden. Report prepared for Ministry of Environment. 32 pp.

Hayes, B., A. Mould, E.H. Khou, T. Hartmann, K. Hoa, T. Calame, K. Boughey and T. Yon. (2013). A biodiversity assessment of Phnom Kulen National Park with recommendations for management. Report prepared for Rufford Foundation. 95 pp.

Evans, D. H., R.J. Fletcher, C. Pottier, J-B. Chevance, D. Soutif, B. S. Tan, S. Im, D. Ea, T. Tin, S. Kim, C. Cromarty, S. De Greef, K. Hanus, P. Bâty, R. Kuszinger, I. Shimoda, and G. Boornazian (2013). Uncovering archaeological landscapes at Angkor using lidar. Proceedings of the National Academy of Sciences, PNAS Vol. 110 (31): 12595-12600.

Kalyan Hou, K.S. Rotha, L. Ung and S. Mao. (2004). Management of Pilot Watershed Areas in Cambodia. Working Paper 12a. MRC-GTZ Cooperation Programme.

Motzke, I., T.C. Wagner, E. Zanre, T. Tscharntke and J. Barkmann. (2012). Socio-economic context of forest biodiversity use along a town-forest gradient in Cambodia. Raffle Bull. Zoology 25: 37-53.

Mould, A., B. Hayes, E.S. Un and K. Sherchan. (2014). A Rapid Biodiversity Assessment of Changkran Roy Forest, Varin District, Siem Reap Province, with Recommendations for Management. Report prepared by FFI and ISAC. 64 pp.

Peou, H., I. Natarajan, H. Tianhua and D. Philippe. (2016). From conservation to sustainable development – a case study of Angkor Wat World Heritage Site, Cambodia. J. Env. Science and Engineering. Vol. 5: 141-155.

Tola, P. (2015). BBP-VC-Gap Analysis of Phnom Kulen National Park (Cambodia). Report prepared for the GIZ-funded Biodiversity-based Products Project. 84 pp.

Wildlife Alliance. (2013). Phnom Kulen National Park: Forest cover, land use and threat assessment. Report prepared for Ministry of Environment. 43 pp.

## ឧបសម្ព័ន្ធ១. ផែនទីឧទ្យានជាតិភ្នំគូលែន



## ឧបសម្ព័ន្ធ២. សំណើតំបន់គ្រប់គ្រងសម្រាប់ឧទ្យានជាតិភ្នំគូលែន



## ឧបសម្ព័ន្ធ៣. សកម្មភាពដែលអាចអនុញ្ញាត និងសម្បទាសម្រាប់តំបន់គ្រប់គ្រងនីមួយៗ

| សកម្មភាព និងសម្បទា | តំបន់គ្រប់គ្រង | | | |
|---|---|---|---|---|
| | តំបន់ស្នូល | តំបន់អភិរក្ស | តំបន់សហគមន៍ | តំបន់ប្រើប្រាស់ដោយនិរន្តរភាព |
| ប្រតិបត្តិការតំបន់ការពារធម្មជាតិ (ល្បាត។ល។) | ✓ | ✓ | ✓ | ✓ |
| ផ្លូវលំ | ✓ | ✓ | ✓ | ✓ |
| ស្រាវជ្រាវ និងតាមដាន (អាជ្ញាប័ណ្ណក្នុងតំបន់ស្នូល) | ✓ | ✓ | ✓ | ✓ |
| អេកូទេសចរណ៍-ការដើរព្រៃ ឬ ជិះកង់ជាក្រុម (អាជ្ញាប័ណ្ណ និងមានមន្ត្រីល្បាតរួមដំណើរក្នុងតំបន់ស្នូល ដែលអាចអនុញ្ញាតតែការដើរព្រៃប៉ុណ្ណោះ) | | ✓ | | |
| កន្លែងបោះជំរុំអេចិន្ត្រៃយ៍ | | ✓ | | |
| កន្លែងចោលសំរាម | | ✓ | ✓ | ✓ |
| ផ្លូវដែលមានការថែទាំ | | | ✓ | ✓ |
| សម្បទាទេសចរណ៍ (មណ្ឌលព័ត៌មាននិងស្លាកសញ្ញា បន្ទប់ទឹក អ្នកលក់វេចនាសម្ព័ន្ធអចិន្ត្រៃយ៍។ល។) | | | | ✓ |
| ការប្រមូលផលពីធនធានតាមលិខិតអនុញ្ញាត (អ្នករស់ក្នុងមូលដ្ឋានប៉ុណ្ណោះ) | | ✓ | ✓ | ✓ |
| ការប្រមូលផលពីធនធានតាមលិខិតអនុញ្ញាត (បែបពាណិជ្ជកម្មខ្នាតតូច) | | | ✓ | ✓ |
| សហគ្រប់គ្រង | | ✓ | ✓ | ✓ |
| ការដាំដំណាំ និងកសិកម្ម | | | ✓ | ✓ |
| ចំការស្វាយចន្ទី តាមលិខិតអនុអញ្ញាត (អ្នករស់ក្នុងមូលដ្ឋានប៉ុណ្ណោះ) | | | | ✓ |
| ផ្សេងទៀតៗ | | | | |

## ឧបសម្ព័ន្ធ ៤. សង្ខេបសន្ទស្សន៍ថវិកាសម្រាប់កម្មវិធីរយៈពេល ៥ ឆ្នាំ (២០១៨-២០២២)

សំគាល់៖ ថវិកាកម្មវិធី (គិតជាដុល្លាអាមេរិក) ជាចំនួនបន្ថែមលើថ្លៃចំណាយលើបុគ្គលិក និងថ្លៃប្រតិបត្តិការបច្ចុប្បន្ន ដែលផ្តល់ដោយក្រសួងបរិស្ថាន (សូមអានឧបសម្ព័ន្ធ៥)

| កម្មវិធីជាយុទ្ធសាស្ត្រ | សកម្មភាពកម្មវិធី | នាំមុខលើការទទួលខុសត្រូវ (និងការគាំទ្រ) | សន្ទស្សន៍ថវិកា | កំណត់សំគាល់ថវិកា (បញ្ចូលថ្លៃចំណាយ) |
|---|---|---|---|---|
| កម្មវិធីទី១: ពង្រឹងកិច្ចការពារ និងអភិរក្សធនធានធម្មជាតិ និងវប្បធម៌ | | | | |
| អនុកម្មវិធី១.១ បង្កើតឱ្យមានព្រំប្រទល់ឧទ្យាន និងតំបន់គ្រប់គ្រង | ក) ដាក់ព្រំប្រទល់ឧទ្យានឱ្យរួចស្រេច (បង្គោល ៤០ដើម ក្នុងចំណោម ៨១ ដើម ត្រូវបានដាំរួចហើយ) | បុគ្គលិកឧទ្យានជាមួយការគាំទ្រពីមន្ទីរបរិស្ថានខេត្ត | ៥.000 | ការដឹកជញ្ជូន ការជីកនិងដាំបង្គោល (ក្នុងថវិការបស់ក្រសួងបរិស្ថាន) |
| | ខ) ដាក់ស្លាកសញ្ញាធំ (ជាភាសាខ្មែរ និងអង់គ្លេស)ត្រង់ច្រកចូល | បុគ្គលិកមន្ទីរបរិស្ថានខេត្ត ជាមួយការគាំទ្រពីអគ្គនាយកដ្ឋានរដ្ឋបាលការពារ និងអភិរក្សធម្មជាតិ និងបុគ្គលិកឧទ្យាន | ១0.000 | គូរប្លង់ សាងសង់ និងដាក់ស្លាកសញ្ញាធំ ៤ ផ្ទាំង តាមផ្លូវលេខ ៦៧ (២), ព្រះអង្គធំ (១) & ច្រកចូលស្វាយលើ (១) |
| | គ) កំណត់តំបន់គ្រប់គ្រងឱ្យរួចស្រេច | អគ្គនាយកដ្ឋានរដ្ឋបាលការពារនិងអភិរក្សធម្មជាតិ និងអគ្គនាយកដ្ឋានសហគមន៍មូលដ្ឋាន គាំទ្រដោយមន្ទីរ បរិស្ថានខេត្ត និងបុគ្គលិកឧទ្យាន | ១0.000 | ពិគ្រោះយោបល់ជាមួយសហគមន៍ ធ្វើផែនទី និងរៀបចំអនុក្រឹត្យ (ថវិការបស់ក្រសួងបរិស្ថាន) |
| អនុកម្មវិធី១.២ បង្កើតបរិវេណការពារប្រាសាទបុរាណ និងបុរាណ | ក) បោះបង្គោលកំណត់ព្រំប្រទល់<br>ខ) ដាក់ស្លាកសញ្ញាសំគាល់ | អគ្គនាយកដ្ឋានសហគមន៍មូលដ្ឋាន សហការជាមួយ អាជ្ញាធរជាតិអប្សរា និងអង្គការ ADF | ៥0,000 | ធ្វើផែនទី ចាក់បង្គោលព្រំ ដឹកជញ្ជូន និងដាំបង្គោល រៀបចំរចនាស្លាកសញ្ញា ផលិត និងតម្លើងស្លាកសញ្ញានៅតាមទីតាំង |

| | | | | |
|---|---|---|---|---|
| ស្ថាន | | | | |
| **អនុកម្មវិធី១.៣ សម្រួលការអភិរក្ស ការស្តារព្រៃឡើងវិញ និងការថែទាំ** | ក)កំណត់អត្តសញ្ញាណកន្លែងសមស្របសម្រាប់ដំណុះតាមធម្មជាតិ និងកន្លែងជាអាទិភាពសម្រាប់ការដាំព្រៃឡើងវិញ | អគ្គនាយកដ្ឋានរដ្ឋបាលការពារនិងអភិរក្សធម្មជាតិ ជាមួយការជួយគាំទ្រពីរដ្ឋបាលព្រៃឈើ | ២0.000 | ការងារនៅមូលដ្ឋាន ថ្លៃធ្វើដំណើរ និងការរៀបចំផែនការដាំព្រៃឡើងវិញ សម្រាប់ការអនុវត្តក្នុងរយៈពេល ៥ ឆ្នាំ |
| | ខ) ផ្តួចផ្តើមការដាំព្រៃនៅទីតាំងអាទិភាព ក្នុងគោលដៅសម្រេចឱ្យបាន ១.000 ហ.ត នៅមុនឆ្នាំ ២០២២ | អគ្គនាយកដ្ឋានរដ្ឋបាលការពារនិងអភិរក្សធម្មជាតិ និងការគាំទ្រពីរដ្ឋបាលព្រៃឈើ បុគ្គលិកឧទ្យាន និងសហគមន៍មូលដ្ឋាន | ១.៦00.000 | ផ្អែកតាមថ្លៃប៉ាន់ស្មាន ១.៦០០ ដុល្លា/ហ.ត ( FA ) |
| **អនុកម្មវិធី១.៤ ពង្រឹការអនុវត្តច្បាប់** | ក) វិនិយោគលើបរិក្ខារទំនើបសម្រាប់ល្បាត និងពង្រឹងការអនុវត្តច្បាប់នៅក្នុងឧទ្យានជាតិនេះ | អគ្គនាយកដ្ឋានរដ្ឋបាលការពារនិងអភិរក្សធម្មជាតិ និងមន្ទីរបរិស្ថានខេត្ត | ១១៥.000 | តួលេខសរុប រួមមាន ថ្លៃរថយន្ត 4WD មួយគ្រឿង, ទោចក្រយានយន្ត បើកក្នុងព្រៃ ១០គ្រឿង វិទ្យុទាក់ទង , GPS ១០គ្រឿង, កាមេរ៉ាឌីជីតាល់ ១០គ្រឿង និងកាំភ្លើងទំនើប ១០ដើម |
| | ខ) ធ្វើឱ្យសហគមន៍មូលដ្ឋានចូលរួមក្នុងការល្បាតនិងការតាមដាន | បុគ្គលិកឧទ្យានជាតិ ជាមួយការគាំទ្រពី អគ្គនាយកដ្ឋានសហគមន៍មូលដ្ឋាន | ២៥.000 | ការពិគ្រោះយោបល់ ការធ្វើដំណើរ និងថ្លៃចំណាយនៅមូលដ្ឋាន សម្រាប់ ៥ ឆ្នាំ (បានពីថវិការបស់ក្រសួងបរិស្ថាន) |
| | | សរុបរង | **១.៨៣៥.000** | |
| កម្មវិធីទី២. ពង្រឹកការចូលរួម និងផលប្រយោជន៍របស់សហគមន៍ | | | | |
| **អនុកម្មវិធី២.១ ចាត់ជាអាទិភាព ការចូលរួមនៅមូល** | ក) ផ្តល់ការគាំទ្រជាប្រចាំដល់គណៈកម្មការគ្រប់គ្រង សហគមន៍តំបន់ការពារធម្មជាតិ | អគ្គនាយកដ្ឋានសហគមន៍មូលដ្ឋាន ជាមួយការគាំទ្រពីមន្ទីរបរិស្ថានខេត្ត បុគ្គលិកឧទ្យាន និង ADF | ៧៥.000 | ការរៀបចំផែនការគ្រប់គ្រងសហគមន៍តំបន់ការពារធម្មជាតិ, ការល្បាត, និងការពង្រឹករបរចិញ្ចឹមជីវិត។ ថ្លៃចំណាយប្រតិបត្តិការប៉ាន់ស្មាន |

| | | | | |
|---|---|---|---|---|
| ដ្ឋានក្នុងការគ្រប់គ្រងឧទ្យាន | | | | ត្រឹម ២.០០០ដុល្លា/សហគមន៍/ឆ្នាំ បន្ថែមលើ ៥.០០០ ដុល្លា សម្រាប់រៀបចំផែនការគ្រប់គ្រងនីមួយៗ |
| អនុកម្មវិធី២.២ ពង្រីកឱកាសសម្រាប់បរបេចិញ្ចឹមជីវិតដែលមាននិរន្តរភាព | ក) ផ្តល់ការគាំទ្រសម្រាប់ការបង្កើតជម្រើសជំនួសក្នុងរបរចិញ្ចឹមជីវិត | អគ្គនាយកដ្ឋានសហគមន៍មូលដ្ឋាន ជាមួយការគាំទ្រពីមន្ទីរបរិស្ថានខេត្ត បុគ្គលិកឧទ្យាន និងអង្គការ ADF | ២៥០.០០០ | សាកល្បង និងបង្កើតផលិតផលកសិកម្មថ្មីដែលមានមេត្រីភាពជាមួយបរិស្ថាន និងអនុផលព្រៃឈើដោយអ្នកភូមិក្នុងមូលដ្ឋាន។ ថ្លៃចំណាយរាប់បញ្ចូល យោបល់បច្ចេកទេស សម្ភារៈ និងការផ្គត់ផ្គង់នានា |
| | ខ) បង្កើត និងថែរក្សាថ្នាលបណ្តុះកូនឈើប្រភេទពូជក្នុងស្រុកដែលអាចប្រើប្រាស់សម្រាប់ដាំនៅក្នុងឧទ្យាននេះ | អគ្គនាយកដ្ឋានរដ្ឋបាលការពារអភិរក្សធម្មជាតិ ជាមួយការគាំទ្រពីរដ្ឋបាលព្រៃឈើ, បុគ្គលិកឧទ្យាន និងសហគមន៍មូលដ្ឋាន | ២០០.០០០ | ថ្លៃចំណាយប៉ាន់ស្មានសម្រាប់ការបង្កើត និងថែរក្សាថ្នាក់បណ្តុះកូនឈើ យ៉ាងហោចណាស់ ៥ កន្លែង នៅក្នុងឧទ្យាននេះ |
| អនុកម្មវិធី២.៣ លើកកម្ពស់ទេសចរណ៍ដែលមាននិរន្តរភាព | ក) រៀបចំយុទ្ធសាស្ត្រគ្រប់គ្រងទេសចរណ៍ | អគ្គនាយកដ្ឋានសហគមន៍មូលដ្ឋាន និងអគ្គនាយកដ្ឋានរដ្ឋបាលការពារអភិរក្សធម្មជាតិ ជាមួយការគាំទ្រពីមន្ទីរបរិស្ថានខេត្ត ក្រសួងទេសចរណ៍ និងអាជ្ញាធរអប្សរា | ៣០.០០០ | ការពិគ្រោះយោបល់ ការធ្វើដំណើរ ការរៀបចំ និងអនុម័តផែនការ |
| | ខ) រៀបចំកូនសៀវភៅអំពីឧទ្យានជាតិភ្នំគូលែន (ជាមួយផែនទី) និងស្លាកសញ្ញានៅកន្លែងប្រើ | អគ្គនាយកដ្ឋានសហគមន៍មូលដ្ឋាន និងអគ្គនាយកដ្ឋានរដ្ឋបាលការពារអភិរក្សធម្មជាតិ ជាមួយការគាំទ្រពី | ២០.០០០ | ការចាត់ចែង រៀបចំ និងផលិតកូនសៀវភៅ និងស្លាកសញ្ញា |

| | | | | |
|---|---|---|---|---|
| | ប្រាស់ច្រើន | មន្ទីរបរិស្ថានខេត្ត ក្រសួងទេសចរណ៍ និងអាជ្ញាធរអប្សរា | | |
| | គ) កែលម្អសម្បទា និងបង្កើតមណ្ឌលព័ត៌មាននៅស្ថានីយ៍ឧទ្យានក្បាលស្ពាន | មន្ទីរបរិស្ថានខេត្តជាមួយការគាំទ្រពីអគ្គនាយកដ្ឋានរដ្ឋបាលការពារនិងអភិរក្សធម្មជាតិ និងអគ្គនាយកដ្ឋានសហគមន៍មូលដ្ឋាន អគ្គនាយកដ្ឋានចំណេះដឹងនិងព័ត៌មានបរិស្ថាន និងACCB | ៧៥.០០០ | ថ្លៃសរុបសម្រាប់កែលម្អមធ្យោបាយ និងបង្កើតមជ្ឈមណ្ឌលព័ត៌មាន |
| **អនុកម្មវិធី២.៤ ដោះស្រាយការគ្រប់គ្រងសំណល់** | ក) កែលម្អមធ្យោបាយគ្រប់គ្រងនិងកែច្នៃសំណល់រឹង | មន្ទីរបរិស្ថានខេត្តជាមួយការគាំទ្រពីរដ្ឋាភិបាលថ្នាក់ខេត្តនិងបុគ្គលិកឧទ្យានជាតិ | ១០០.០០០ | ការរៀបចំមធ្យោបាយគ្រប់គ្រងនិងកែច្នៃសំណល់, ការទិញ និងការដាក់ធុងសម្រាម និងកែច្នៃ |
| | | សរុបរង | **៧៥០.០០០** | |
| កម្មវិធីទី៣: ពង្រឹងសមត្ថភាពស្ថាប័ន និងកិច្ចសហការ | | | | |
| **អនុកម្មវិធី៣.១ ធានាឱ្យមានបុគ្គលិកគ្រប់គ្រាន់ និងសមត្ថភាពនិងធនធានសមស្រប** | ក) បើកវគ្គបណ្តុះបណ្តាលអំពីការអនុវត្តច្បាប់សម្រាប់បុគ្គលិកល្បាតទាំងអស់ក្នុងឧទ្យាន និងវគ្គរម្លឹកឡើងវិញប្រចាំឆ្នាំ | អគ្គនាយកដ្ឋានរដ្ឋបាលការពារអភិរក្សធម្មជាតិ ជាមួយការគាំទ្រពីគណៈបញ្ជាការឯកភាព | ៥០.០០០ | ថ្លៃចំណាយសម្រាប់វគ្គបណ្តុះបណ្តាលឯកទេស (ឆ្នាំទី១) ប៉ាន់ស្មាន ៥០០ដុល្លា/មន្ត្រីល្បាតម្នាក់ៗ ដោយថ្លៃចំណាយសម្រាប់បណ្តុះបណ្តាល ក្នុងមួយឆ្នាំៗមាន ១០០ដុល្លា/មន្ត្រីល្បាតម្នាក់ៗ |
| | ខ) ផ្តល់វគ្គបណ្តុះបណ្តាលអំពីការរៀបចំផែនការ និងការគ្រប់គ្រងតាមបែបចូលរួម ដល់បុគ្គលិក | អគ្គនាយកដ្ឋានរដ្ឋបាលការពារអភិរក្សធម្មជាតិ និងអគ្គនាយកដ្ឋានសហគមន៍មូលដ្ឋាន | ២៥.០០០ | ការរៀបចំ និងអនុវត្តកម្មវិធីបណ្តុះបណ្តាលសម្រាប់បុគ្គលិកមន្ទីរបរិស្ថានខេត្ត ១៥ នាក់ មន្ត្រីល្បាត ៥០នាក់ និងសមាជិកក្រុមប្រឹក្សាឃុំ ១៥ |

| | | | | |
|---|---|---|---|---|
| | PDoE បុគ្គលិកឧទ្យាន និងក្រុមប្រឹក្សាឃុំ | | | នាក់ |
| | គ) ផ្តល់វគ្គបណ្តុះបណ្តាលដល់មន្ត្រីល្បាត និងសហគមន៍មូលដ្ឋាន អំពីការគ្រប់គ្រងទេសចរណ៍ | អគ្គនាយកដ្ឋានសហគមន៍មូលដ្ឋាន និងមន្ទីរបរិស្ថានខេត្តជាមួយការគាំទ្រពីក្រសួងទេសចរណ៍ អាផ្វាធរ អប្សរានិងADF | ៣០.០០០ | ការរៀបចំ និងការអនុវត្តកម្មវិធីបណ្តុះបណ្តាលសម្រាប់មន្ត្រីល្បាត ៥០នាក់ និងតំណាងសហគមន៍ ៥០នាក់ |
| | ឃ) ពង្រឹកសមត្ថភាពបច្ចេកទេសក្នុងមន្ទីរបរិស្ថានខេត្ត សម្រាប់ការគ្រប់គ្រង និងតាមដានតំបន់ការពារធម្មជាតិ (រួមទាំង ការសរសេរសំណើគម្រោង) | អគ្គនាយកដ្ឋានរដ្ឋបាលការពារអភិរក្សធម្មជាតិ និងអគ្គនាយកដ្ឋានសហគមន៍មូលដ្ឋាន | ២៥.០០០ | ថ្លៃចំណាយសម្រាប់បុគ្គលិកមន្ទីរបរិស្ថានចូលរួមក្នុងសិក្ខាសាលាបច្ចេកទេស និងវគ្គបណ្តុះបណ្តាលរៀបចំដោយ អគ្គនាយកដ្ឋានរដ្ឋបាលការពារអភិរក្សធម្មជាតិ និងអគ្គនាយកដ្ឋានសហគមន៍មូលដ្ឋាន (រយៈពេល ៥ ឆ្នាំ) |
| | | សរុបរង | ១៣០.០០០ | |
| **កម្មវិធីទី៤: ធានាឱ្យមានហិរញ្ញប្បទានដែលមាននិរន្តរភាពសម្រាប់ឧទ្យានជាតិភ្នំគូលែន** | | | | |
| **អនុកម្មវិធី៤.១ កំណត់រកនិងធានាឱ្យមានប្រភពហិរញ្ញប្បទានដែលមាននិរន្តរភាព** | ក) រៀបចំយុទ្ធសាស្ត្រកៀរគរធនធានដែលរួមទាំង កម្រៃពីភ្ញៀវទេសចរ និងប្រភពមូលនិធិថ្វៃប្រឌិតដទៃទៀត | អគ្គនាយកដ្ឋានរដ្ឋបាលការពារអភិរក្សធម្មជាតិ និងអគ្គនាយកដ្ឋានសហគមន៍មូលដ្ឋាន ជាមួយការគាំទ្រពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ៥០.០០០ | ការរៀបចំ និងអនុវត្តយុទ្ធសាស្ត្រកៀរគរធនធាន |
| | | សរុបរង | ៥០.០០០ | |
| ការតាមដាន និងវាយតម្លៃ | | | | |

| | | | | |
|---|---|---|---|---|
| | ក) ធ្វើការសិក្សាវាយតម្លៃទីជម្រាលនៃឧទ្យាន | អគ្គនាយកដ្ឋានរដ្ឋបាលការពារអភិរក្សធម្មជាតិ ជាមួយការគាំទ្រពីនាយកដ្ឋានជីវចម្រុះ (ក.ជ.អ.ច) | ៥០.000 | រៀបចំការសិក្សា ការប្រមូលទិន្នន័យ ការពិគ្រោះយោបល់ និងការរៀបចំរបាយការណ៍ |
| | ខ) ធ្វើការវាយតម្លៃធនធានសម្រាប់ផ្នែកពាយព្យនៃឧទ្យាន (ដែលថ្មីៗនេះបានកំណត់ជារបៀងអភិរក្សជីវចម្រុះ) | អគ្គនាយកដ្ឋានរដ្ឋបាលការពារអភិរក្សធម្មជាតិ ជាមួយការគាំទ្រពីរដ្ឋបាលព្រៃឈើ | ២៥.000 | ការងារតាមមូលដ្ឋាន រៀបចំផែនទី ពិគ្រោះយោបល់ និងរៀបចំរបាយការណ៍ |
| | គ) តាមដានវឌ្ឍនភាពនៃការអនុវត្តផែនការគ្រប់គ្រងឧទ្យានជាតិ | អគ្គនាយកដ្ឋានរដ្ឋបាលការពារអភិរក្សធម្មជាតិ, អគ្គនាយកដ្ឋានសហគមន៍មូលដ្ឋាន និងមន្ទីរបរិស្ថានខេត្ត | ២0.000 | របាយការណ៍តាមដានប្រចាំឆ្នាំ និងការវាយតម្លៃប្រសិទ្ធភាពនៃការគ្រប់គ្រងនៅឆ្នាំទី ៥ (២0២២) |
| | | សរុបរង | ៩៥.000 | |
| | | សរុប | **២.៨១0.000 ដុល្លា** | ថ្លៃប៉ាន់ស្មានសម្រាប់រយៈពេល ៥ ឆ្នាំ (២០១៨-២០២២) |

## **ឧបសម្ព័ន្ធ ៥. សង្ខេបគ្រោងថ្លៃចំណាយលើប្រតិបត្តិការ និងកម្មវិធីប្រចាំឆ្នាំ** (២០១៨-២០២២)

ថវិកាគិតជាដុល្លាអាមេរិក និងអនុវត្តចំពោះតែការចំណាយក្នុងឧទ្យានជាតិភ្នំគូលែនប៉ុណ្ណោះ

| | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២ | សរុប (២០១៨-២០២២) |
|---|---|---|---|---|---|---|
| ១. ថវិកាប្រតិបត្តិការជាមូលដ្ឋាន (ត្រូវផ្តល់ដោយក្រសួងបរិស្ថាន) | | | | | | |
| ប្រាក់បៀវត្សរ៍ (នាយកឧទ្យាន ១ និងបុគ្គលិកល្បាត ៤៨នាក់) | ៦២.៤០០ | ៦២.៤០០ | ៦២.៤០០ | ៦២.៤០០ | ៦២.៤០០ | ៣១២.០០០ |
| ថ្លៃធ្វើដំណើរ (ល្បាត) | ១២.០០០ | ១២.០០០ | ១២.០០០ | ១២.០០០ | ១២.០០០ | ៦០.០០០ |
| ការចំណាយជាមូលដ្ឋានសម្រាប់ស្ថានីយ៍ (ស្ថានីយ៍ ១ និងស្ថានីយ៍រង ៧) – ស្ថានីយ៍រងខ្លះនឹងត្រូវប្តូរទីតាំងនៅឆ្នាំ ២០១៨ | ១០.០០០ | ២៥.០០០ | ១៥.០០០ | ១៥.០០០ | ១៥.០០០ | ៨០.០០០ |
| ជួសជុល និងការថែទាំ | ១៥.០០០ | ១៥.០០០ | ១៥.០០០ | ១៥.០០០ | ១៥.០០០ | ៧៥.០០០ |
| ឯកសណ្ឋាន និងសម្ភារៈផ្គត់ផ្គង់ផ្សេងទៀត | ២.០០០ | ២.០០០ | ២.០០០ | ២.០០០ | ២.០០០ | ១០.០០០ |
| សរុបរង | ***១០១.៤០០*** | ***១១៦.៤០០*** | ***១០៦.៤០០*** | ***១០៦.៤០០*** | ***១០៦.៤០០*** | ***៥៣៧.០០០*** |
| ២. បរិក្ខារ និងលទ្ធកម្មធំៗ (មូលនិធិថ្មីបន្ថែម) | | | | | | |
| រថយន្ត (4WD មួយគ្រឿង និងទោចក្រយានយន្តចូលព្រៃ ១០ គ្រឿង) | ២០.០០០ | ៥០.០០០ | ២០.០០០ | - | - | ៩០.០០០ |
| បរិក្ខារល្បាត (វិទ្យុទាក់ទង, GPS, ម៉ាស៊ីនថតឌីជីតាល់, អាវុធ) | ១៥.០០០ | ៥.០០០ | ៥.០០០ | - | - | ២៥.០០០ |
| សរុបរង | ***៣៥.០០០*** | ***៥៥.០០០*** | ***២៥.០០០*** | - | - | ***១១៥.០០០*** |
| ៣. ការវិនិយោគលើកម្មវិធី (មូលនិធិថ្មីបន្ថែម) | | | | | | |
| ដាំព្រៃឡើងវិញ (ដែលរួមទាំង ការបង្កើតថ្នាលបណ្តុះកូនឈើ) | ៣៦៤.០០០ | ៣៦៤.០០០ | ៣៦៤.០០០ | ៣៦៤.០០០ | ៣៦៤.០០០ | ១.៨២០.០០០ |
| ការអភិវឌ្ឍរបរចិញ្ចឹមជីវិត និងការគាំទ្រដល់សហគមន៍តំបន់ | ៥០.០០០ | ១២៥.០០០ | ១០០.០០០ | ២៥.០០០ | ២៥.០០០ | ៣២៥.០០០ |

| | | | | | | |
|---|---|---|---|---|---|---|
| ការពារធម្មជាតិ | | | | | | |
| ការអភិវឌ្ឍទេសចរណ៍ (រួមទាំង កែលម្អហេដ្ឋារចនាសម្ព័ន្ធនិងស្លាកសញ្ញា) | ៨៥.០០០ | ១០០.០០០ | ២៥.០០០ | ១៥.០០០ | ១០.០០០ | ២៣៥.០០០ |
| បណ្ដុះបណ្ដាលផ្ដោតលើមន្ត្រីល្បាត បុគ្គលិកមន្ទីរបរិស្ថាននិងសហគមន៍មូលដ្ឋាន | ៣០.០០០ | ៥០.០០០ | ៣០.០០០ | ១៥.០០០ | ៥.០០០ | ១៣០.០០០ |
| យុទ្ធសាស្ត្រកៀរគរធនធាន | ៥០.០០០ | | | | | ៥០.០០០ |
| ការស្រាវជ្រាវ និងតាមដាន | ១៥.០០០ | ៥០.០០០ | ១៥.០០០ | ១០.០០០ | ៥.០០០ | ៩៥.០០០ |
| សរុបរង | *៥៩៤.០០០* | *៦៨៩០០០* | *៥៣៤០០០* | *៤២៩.០០០* | *៤០៩.០០០* | *២.៦៦៥.០០០* |
| សរុបរង (គិតតាមឆ្នាំ) | ៧៣០.៤០០ | ៨៦០.៤០០ | | ៥៣៥.៤០០ | ៥១៥.៤០០ | ៣.៣០៧.០០០ |